ខ. អ្នកនិពន្ធបង្ហាញពីការធ្វើសង្គ្រាម ការប្រយុទ្ធគ្នារវាងសភាវៈល្អនិងសភាវៈអាក្រក់។

ក. អ្នកនិពន្ធបានដំណើរជីវិតរបស់ព្រះពុទ្ធក្នុងអតីតជាតិណាមួយ។

ឃ. អ្នកនិពន្ធបានបង្ហាញពីស្ថានភាពសង្គមដែលមនុស្សបានជួបប្រទះ។

៩. តើចំណុចមួយណាដែលជាពាក្យសម្រាប់ធ្វើការផ្តើមរឿងក្នុងរឿងព្រេងនិទាន?

ក. សម័យថ្ងៃមួយ..... ខ. កាលពីព្រេងនាយ.....

គ. មានដំណាលថា..... ឃ. ចម្លើយទាំង៣

១០. តើក្នុងរឿងព្រេងអ្នកនិពន្ធបានបញ្ចប់រឿងយ៉ាងដូចម្តេច?

ក. បញ្ចប់ដោយបង្ហាញពីបញ្ហាស្នេហា កំហឹង។

ខ. បញ្ចប់ដោយបង្ហាញពីសមិទ្ធផល ឬប្រាប់ពីមូលហេតុ។

គ. បញ្ចប់រឿងដោយលើកតួអង្គណាមួយក្នុងសង្គម។

ឃ. បញ្ចប់ដោយមិនបង្ហាញពីភាពយុត្តិធម៌ក្នុងសង្គម។

១១. តើធាតុសំខាន់ៗនៃរឿងមានអ្វីខ្លះ?

ក. ផ្តើមរឿង ខ. តួរឿង ឬ ដំណើររឿង

គ. បញ្ចប់រឿង ឃ. ទាំង៣ខាងលើ

១២. តើមួយណាជាវិធីក្នុងការផ្តើមរឿងរបស់ចលនាអក្សរសិល្ប៍ខេមរនិយម?

ក. ផ្តើមឡើងដោយមិនមានលក្ខណៈឯកភាពគ្នា អាស្រ័យលើទេពកោសល្យរបស់អ្នកនិពន្ធម្នាក់ៗ។

ខ. ផ្តើមឡើងដោយការបង្ហាញឈ្មោះរបស់អាទិទេពធំៗទាំង៣ ព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ...។

គ. ផ្តើមឡើងដោយបទនមស្ការហើយផ្តើមដោយតំណាលថា ព្រះពុទ្ធគង់នៅអារាមណាមួយ ត្រូវបានក្រុមកិក្ខុសង្ឃ អារធនាឱ្យសម្តែងរឿង...។

ឃ. គ្មានចម្លើយ

១៣. តួអង្គសំខាន់នៅក្នុងចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយមគឺ

ក. ទេវតា ខ. អារក្ស

គ. អាទិទេព ឬអវតារនៃព្រះវិស្ណុ ឃ. អ្នកតា

១៤. នៅក្នុងចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយមគេច្រើនបង្ហាញទីកន្លែងនៅ

ក. ព្រៃហេមពាន្ត ខ. ស្ថានបាតាល

គ. ស្ថានសិម្ពលី ឃ. ត្រូវទាំងអស់

១៥. នៅក្នុងរឿងអក្សរសិល្ប៍ខេមរនិយមគេច្រើនបង្ហាញទីកន្លែង

ក. ស្ថាននរក ខ. ស្ថានសួគ៌

គ. សង្គមជាក់ស្តែង ឃ. សុបិន

II. ចូរប្អូនបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. ការបញ្ចប់រឿងដោយមិនមានការឯកភាព អាស្រ័យលើទេពកោសល្យរបស់អ្នកនិពន្ធជាការបញ្ចប់រឿងរបស់.....។

២. ដំណើររឿងដែលបង្ហាញពីប្រវត្តិនៃឈ្មោះ ភូមិ ស្រុក ទីកន្លែងនានា បុរាណដ្ឋាន ប្រពៃណី ទំនៀមទម្លាប់ ទំនាស់វិបត្តិផ្សេងៗក្នុងសង្គមជាដំណើររបស់.....។

៣. ការអប់រំឱ្យមនុស្សជឿតែលើអាទិទេព ឱ្យមានជំនឿទុក្ខសោក ល្អ អាក្រក់ទាំងឡាយពឹងលើកម្លាំងក្រៅខ្លួនជាឧត្តមគតិរបស់.....។

៤. បញ្ហាចោទទំនាស់វិបត្តិសភាវៈល្អនិងសភាវៈអាក្រក់ ស្ថិតក្នុងចលនាអក្សរសិល្ប៍.....។

៥. ការបង្ហាញពីសេចក្តីស្នេហាបរិសុទ្ធ និងការកសាងបារមីរបស់ព្រះពោធិសត្វ និងកន្សែសារពេជ្ជស្ថិតក្នុងចលនាអក្សរសិល្ប៍.....។

III. ចូរប្អូនអានអត្ថបទខាងក្រោម រួចបង្ហាញពីការផ្តើមរឿង តួរឿង បញ្ចប់រឿងឱ្យបានត្រឹមត្រូវ

<u>រឿង ដើមកំណើតសត្វឆ្មា</u>

ក្នុងកាលនោះមានមហាឥសីមួយអង្គគង់នៅព្រៃភ្នំមួយឈ្មោះ វុឌ្ឍីបព៌ត តាំងចង្រ្កមភាវនាក្នុងទីភ្នំនោះជាអង្វែងឆ្នាំមក។ នៅកន្លែងនោះមានស្រះបួនគឺ ទិសបូព៌ា១ ទក្សិណ១ បស្ចិម១ និង ឧត្តរ១។ ស្រះនោះមានទឹករងថ្លាមានដុះឈូកក្រហម ឈូកស និង បុប្ផាផងទាំងពួងជាទីសប្បាយនៃមច្ឆាគ្រប់បែបឯមាត់ច្រាំងក៏ជ្រោល មុខគួរឱ្យសប្បាយពេកណាស់។ ស្រះទាំងបួននៅឆ្ងាយពីអាស្រមប្រហែលមួយយោជន៍ព្រះឥសីក៏ធ្លាប់តែទៅស្រង់ទឹករាល់ដងផង។ មានសម័យថ្ងៃមួយព្រះឥសីគង់ចម្រើនមេត្តាភាវនាដោយញាណឈានលោកិយសព្វគ្រប់ទៅឃើញថា ឱ!មានទេពធីតាមកចាប់កំណើតក្នុងផ្កាឧត្បលដែលដុះក្នុងស្រះខាងឧត្តរបានអាយុ៩ថ្ងៃ ហើយតើអាត្មាអញក៏ខានទៅស្រង់ទឹកឯស្រះនោះ៩ថ្ងៃហើយដែរ។ ព្រះឥសីក៏ជាក់ស្តឹងស្មាធ៏គិតថា អាត្មាអញគួរទៅយកមកចិញ្ចឹមបីបាច់ថែរក្សាចុះ គិតហើយក៏រៀបអង្គផ្ងង់ដំណើរតម្រង់ទៅទិសឧត្តរដល់ស្រះហើយព្រះឥសីឈរសម្លឹងមើលគ្រប់ផ្កា ឃើញផ្កាឧត្បលមួយធំខ្ពស់ឃើញនាងទេពធីតាអង្គុយក្នុងផ្កានោះ ព្រះឥសីក៏ចុះទៅកាច់យកផ្កានោះមកហើយនិមន្តត្រឡប់មកកាន់អាស្រមវិញ។ ចិញ្ចឹមថែរក្សាជាសុខសប្បាយ លុះដល់នាងធំក៏ឱ្យឈ្មោះថា"ឧត្តរបុប្ផា" លុះបានអាយុ១៥វស្សាលោកតាក៏ភ្នកព្រះទ័យនឹកអាណិតចៅស្រី ព្រោះពេញរូបរាងទៅហើយនៅកំព្រាឥតគ្នីគ្នា នឹងលេងប្រឡែងឯកឯងអផ្សុកវិតក្កចិត្ត។ ដូច្នេះគួរអញយកបុប្ផាមួយទៀតមកជប់ឱ្យកើតជាគ្នាគ្រាន់បានជាពីរនាក់ ព្រះឥសីគិតហើយ

ឈ្វេងយល់ថាឥឡូវ បើយកផ្កាដទៃផ្សេងមក ជបជាមនុស្សទៅឃើញថា ជាជាតិផ្កាដូចគ្នាដូច្នេះចាំយកជាតិពីនាងផ្ទាល់ឥសីគិតហើយក៏ហៅនាងឧត្តរបុប្ផាមកផ្តាំថា បើកាលណានាងធំពេញរូបរាងហើយមានរដូវចូរនាងផ្តិតសំឡីទុកឱ្យតាៗនឹងជបឱ្យបានគ្នាគ្រាន់នឹងលេងពីរនាក់។ នាងឧត្តរបុប្ផាបានឮលោកតាមានពុទ្ធដីកាហើយក៏ត្រេកអរពន់ពេក លុះដល់គម្រប់ពេលមានរដូវកាលណាហើយនាងក៏យកទៅថ្វាយលោកតាតាមបណ្តាំ ។

លោកតាប្រាប់ទៅនាងថា៖ អើចៅ!ថ្ងៃស្អែកនេះចៅនឹងបានគ្នាពីរនាក់ គ្រាន់បាននិយាយលេងសោះអផ្សុកហើយ។ វេលាយប់នោះនាងដេកពុំលក់សោះ ទន្ទឹងចាំតែព្រឹកឆាប់នឹងអាលបានគ្នាជាពីរនាក់។ លុះព្រឹកឡើងលោកតាក៏បិទទ្វារកុដិ តាំងវាយភ្នែនសង្រួមការនាវេទមន្តជបបានឆ្នាញីមួយសម្បុរបើ អំពីលោហិតរដូវដែលនាងផ្តិតឱ្យទៅនោះ។ រួចស្រេចហើយឥសីហៅ នាងឧត្តរបុប្ផាមកហើយលើកឆ្នាហុចមកឱ្យនាងប្រាប់នាងថា"ជាគ្នារបស់នាង ហើយសត្វនេះឈ្មោះថា ឆាម៉ា" ។ សត្វនោះចេះនិយាយគួរសមជាមួយនាង នាងក៏ទទួលយកមកថែរក្សាដោយសេចក្តីស្រឡាញ់ពេញចិត្តទុកដូចជាកូន ឬ ប្អូនឱបដល់ឱរាបីយកទៅក្នុងបន្ទប់ទៅណាមកណាតែងយកទៅតាមនិយាយគ្នាបីដូចមនុស្សដូច្នោះ។ លុះដល់នាងអាយុបាន១៧ឆ្នាំទើបឥសីដាក់កំណត់ច្បាប់មាត្រាឱ្យនាងកាន់កុំឱ្យកាន់ច្រឡំ សម្រាប់ជាច្បាប់តទៅកូនចៅស្រីៗឯក្រោយទៀតគឺថាជាតិជាស្រីទាំងអម្បាលម៉ាន មិនត្រូវទាត់សត្វធាមួយនេះនឹងជើង ឬ វាយនឹងអំបោស ឬមួយនឹងតម្បាតត្រីអាំង។ កុំថាតែទាត់ធាក់សូម្បីតែជើរកន្លង ក៏មិនបានដែរត្បិតសត្វនេះកើតឡើងដោយលក្ខណ៍ស្រី។ បើស្រីណាទាត់ធាក់ ឬជើរកន្លងសត្វនេះហៅថា ស្រីហិនលក្ខណ៍ហើយ បើប្រព្រឹត្តិច្រើនដងទៅហៅថាស្រីខាតលក្ខណ៍។ តមកប្រមាណ១៤ខែ សត្វធាម៉ាក៏កើតបានកូនឈ្មោលមួយឡើងទៀត។ គឺជាធាម៉ាទាំងពីរនេះហើយជាកំណើតធ្មាទាំងអស់។

និយាយពីស្តេចមួយអង្គនាមសោទត្តព្រះរាជបិតាលើករាជសម្បត្តិឱ្យកូននេះសោយរាជ្យសម្បត្តិព្រះជន្មបាន២១ព្រះវស្សានៅនគរឈ្មោះតក្កសីលា។ ស្តេចថ្មីនោះសោយរាជ្យឡើងពុំមានមហេសីទេត្រអាលក្រសាលតែនឹងស្រីស្នំបរិពារ។ លុះអង្វែងទៅស្តេចទ្រង់ផ្ងំវេលាយប់មួយលោកនឹកក្អកព្រះទ័យចង់ចេញទៅលេងព្រៃ។ លុះភ្លឺស្វាងកាលណាស្តេចក៏ចេញចុងព្រះរាជរោងឱ្យនាម៉ឺន មុខមន្ត្រីគាល់ដូចសព្វដង លុះជួបជុំមន្ត្រីអស់ហើយស្តេចក៏មានបន្ទូលប្រាប់ថា"យើងចង់ទៅលេងព្រៃនៅថ្ងៃខានស្អែកចូររៀបចំពលថ្មើរជើងនិងសេះ ដំរី រៀបចំស្បៀងអាហារក្រយាស្ងោយគ្រាន់គ្រប់គ្នាកុំឱ្យខ្វះ" ។ នាម៉ឺនទទួលព្រះរាជឱង្ការកាលណាក៏រៀបចំប្រដាប់ឥតមានខ្វះពលថ្មើរជើងពលសេះ ដំរី រួចស្រេចហើយក៏ចូលក្រាបបង្គំទូលព្រះអង្គជ្រាបលុះដល់កំណត់ថ្ងៃហើយ វេលាព្រឹកស្តេចក៏យាងចេញទៅដោយមាន នាម៉ឺន សេនា ទាហាន ហែតាមលុះបានបួនថ្ងៃ ក៏បានទៅដល់ព្រៃហេមវនស្តេចក៏មាន ព្រះឱង្ការឱ្យបោះព្រះពន្លាមួយនៅទីនោះ ។ អស់ទាំងសេនាទាហានក៏ធ្វើជំរំគ្រប់ៗ តាមមុខរបស់ខ្លួនស្រេចហើយ ស្តេចមានបន្ទូលបើកអំណាចឱ្យអស់សេនាលេងល្បែងភ្លេង ច្រៀង រាំ តាមចិត្តឱ្យសប្បាយក្នុងព្រៃនោះ។ នៅពេលយប់ស្តេចក៏ចូលផ្ងំក្នុងព្រះពន្លាដ៏យ លុះអាជ្រាត្រស្ងាត់ឮសូរតែមាត់បក្សីគ្រប់ភាសាយំមុខ គួរឱ្យស្រងេះស្រងោចលន្លង់លន្លោចក្នុងព្រះទ័យមមែនឹកគិតគ្រប់សព្វ លុះភ្លឺស្វាងព្រះសុរិយាកាលណា ស្តេចក៏មានព្រះរាជឱង្ការបង្គាប់ទៅរាជអាមាត្យឱ្យរៀបទីនំងអស្សតរថ្វាយ ព្រះអង្គនឹងត្រេចមើលព្រៃកម្សាន្តព្រះទ័យ ជាមួយនឹងអាមាត្យពីរនាក់បីនឹងស្តេច។

រួចហើយចេញទៅលាចត្រឡប់មកព្រះពន្លាដ័យវិញ។ គ្រប់បីថ្ងៃនៅវេលាព្រឹកមួយ ស្តេចក៏បរទីន័ងទៅដល់ស្រះកំណើតនៃនាងឧត្តរបុប្ផាទ្រង់ ទតទៅឃើញទឹកក៏រងថ្លាឃើញបុប្ផានិងមច្ឆាគ្រប់បែបហែបហែលជ្រួលច្រវាត់មុខគួរឱ្យទ្រង់សព្វព្រះទ័យនឹងចុះស្រង់។ ទើបស្តេចមានបន្ទូលទៅរាជអាមាត្យទាំង២ថាយើងងូតទឹកស្រះនេះឱ្យត្រជាក់កាយសប្បាយចិត្ត សឹមបន្តដំណើរទៅទើបឈប់លែងពាជីឱ្យស៊ីស្មៅរួចផ្លាស់ព្រះពស្ត្រស្រង់ទៀតព្រមទាំងរាជអាមាត្យទឹកក៏ត្រជាក់ធ្វើឱ្យមានកម្លាំងមែន។ រួចហើយឡើងផ្លាស់ព្រះពស្ត្រស្រេចស្តេចក៏យាងទតតាមឆ្នេរស្រះ ទៅឃើញមានផ្លូវទក់ៗព្រះអង្គនឹកថា"ឃើ!ព្រៃនេះសមសាន្តហានស្ងាត់ណាស់ម្តេចឡើយក៏មានផ្លូវមនុស្សដើរដូច្នោះ"។ រួចស្តេចក៏មាន បន្ទូលទៅនឹងអាមាត្យថា នៅចាំយើងទីនេះចុះយើងដើរទៅមើលត្រង់នោះបន្តិច។ ស្តេចយាងតាមផ្លូវព្រះឥសីនោះទៅៗបន្តិចបានក្រឡេកឃើញអាស្រមស្តេចនឹកក្នុងព្រះទ័យថារោងនេះជារោងអី? ជាផ្ទះព្រានព្រៃទេឬអ្វី? ព្រះអង្គចេះតែយាងចូលទៅឯព្រះឥសីកំពុងធាន់នាងឧត្តរបុប្ផាអង្គុយគាល់លោកតា ។ លុះស្តេចយាងដល់ទទួលនាងនោះក្រឡេកភ្នែកមកឃើញនាងក៏ស្ទុះចូលទៅក្នុងបន្ទប់។ ព្រះឥសីសួរទៅនាងថាម្តេចក៏ស្ទុះរត់ចូលក្នុង? នាងនិយាយតិចៗទូលឥសីថា"មានមនុស្សពីណាដើរចូលមក"។ ព្រះឥសីក៏បែរព្រះភក្ត្រទតយល់ដូចនាងទូលមែន។ ឯព្រះរាជាលុះយល់ច្បាស់ ដូច្នេះហើយក៏ចូលទៅថ្វាយបង្គំព្រះឥសី ឥសីក៏ឈប់ធាន់ សួរទៅស្តេចថា៖ នែចៅមកពីណាបានជាចូលមកដល់ទីនេះ? ទើបស្តេចទូលឥសីថា "ខ្ញុំព្រះករុណាមកពីនគរតក្កសីលា" ឥសីឈ្វេងយល់មួយរំពេចថា នេះជាស្តេចទើបព្រះអង្គសួរទៅទៀតថា"ស្តេចចៅមកទីនេះប្រាថ្នាអ្វី"។ ព្រះបាទសោទត្តទូលឥសីតាមដំណើរ ឯឥសីឈ្វេងយល់ថាស្តេចអង្គនេះត្រូវជាគូ នាងឧត្តរបុប្ផា លោកក៏ហៅចៅស្រីឱ្យចេញមកថ្វាយបង្គំព្រះរាជា។ ហេតុតែនាងជាស្រីមានលក្ខណ៍ ក៏ចេញមកថ្វាយបង្គំព្រះរាជាតាមពុទ្ធដីកា។ ព្រះអង្គក្រឡេកយល់នាង នាងក៏យល់ព្រះភក្ត្រ ព្រះអង្គច្បាស់ហើយចាប់ចិត្តទៅវិញទៅមកទើបព្រះឥសីមានពុទ្ធដីកាថា "ស្តេចចៅនេះហើយដែលជា គូនឹងនាងតាំងតែអំពីអតីតជាតិមកម្ល៉េះ" ។ គ្រានោះឥសីសួរកសេនារេហ៍ពលព្រះបាទសោទត្តក៏ទូលថា ព្រះអង្គយកតែអាមាត្យពីរនាក់មកតាមទេ ឥឡូវឱ្យឈប់ចាំនៅឯមាត់ស្រះខាងទិសឧត្តរឯណោះត្រង់ថា ខ្ញុំករុណាត្រូវជាគូស្រករនឹងនាងនេះក៏ស្រេចតែលោកតាបើសព្វព្រះទ័យយ៉ាងណា ខ្ញុំព្រះករុណាទទួលធ្វើតាមទាំងអស់។ ឥសីបញ្ជាទៅវិញថា" បើដូច្នេះសូមស្តេចចៅថយទៅរៀបចំសង់រោងបីល្វែង ហើយរកផ្កាឱ្យបាន៧ពណ៌យកមកចងផ្តុំជាបីបាច់ទុកឱ្យតាទៅប្រសិទ្ធពរជ័យឱ្យបានគ្នាជាប្តីប្រពន្ធសុខសប្បាយតទៅ"។ ស្តេចស្តាប់ព្រះពុទ្ធដីកាហើយក៏រួសរាន់ថ្វាយបង្គំលាយាងមកដល់ទីកន្លែងស្រះ ដែលឱ្យអាមាត្យចាំហើយបបួលអាមាត្យត្រឡប់ទៅកាន់ពន្លាជ័យវិញ ដល់ហើយបញ្ជានាម៉ឺន សេនា គ្រប់ក្រុមឱ្យរៀបចំសង់រោងបីល្វែងតាមបង្គាប់ឥសី។ បានរួចស្រេចក៏ឱ្យក្បួនទ័ពព្រមទាំងភ្លេងតូរ្យតន្ត្រីពីរោះល្វឹងល្វើយ ទៅដង្ហែនាងឧត្តរបុប្ផាពីអាស្រមឥសី និមន្តទាំងព្រះឥសីឡើងគង់ព្រះវរសលៀងដង្ហែមកកាន់ព្រះពន្លា។ ដល់ហើយព្រះតាបសតាំងសូត្រទិព្យមន្តព្រះឥសីក៏ បាចផ្កាទាំង៧ពណ៌នោះថ្វាយពរជ័យដល់គូស្រករថ្មី ។ បីថ្ងៃតមកទើបព្រះអង្គនិងនាងជាយាថ្វាយបង្គំលាលោកតានាងក៏ស្រក់ទឹកភ្នែកនឹកអាល័យលោកតាព្រោះតាំងពីកើតមក ពុំដែលបែកទៅណាសោះឥឡូវមិនដឹងជាកាលណានឹងបានមកថ្វាយបង្គំវិញទេ ។

គ្រានោះឥសីបានផ្តាំនាងថា៖ បើនាងទៅដល់ប្រាសាទហើយមុននឹងឡើងទៅលើប្រាសាទនាងត្រូវឱបសត្វឆាម៉ាហើយដើរព័ទ្ធប្រទក្សិណប្រាសាទ៣ដុំ រួចសឹមឡើងទៅនៅក្នុងប្រាសាទនោះ ទើបនាងបានសុខមានសិរីសួស្តី ។ នាងស្តាប់សព្វគ្រប់ហើយក៏លាចេញទៅ លុះទៅដល់ព្រះរាជវាំងហើយមុននឹងចូលក្នុងព្រះរាជដំណាក់ព្រះនាងបានធ្វើតាមបណ្តាំឥសី ឥតឱ្យឆ្គងក៏បានប្រកបដោយសេចក្តីសុខចម្រើនរហូតទៅ ។ ទំនងជាដោយសាររឿងនេះទេដឹង បានជាខ្មែរយើងមានទំនៀមមួយក្នុងពេលធ្វើពិធីឡើងផ្ទះថ្មី គឺគេនិយមឱបឆ្មាមួយហើយដើរប្រទក្សិណផ្ទះបីដុំហើយស្រេចទើបគេឡើងនៅ។

(អត្ថបទនេះដកស្រង់ចេញពីសៀវភៅប្រជុំរឿងព្រេងនិទានខ្មែរ ភាគទី៧ ទំព័រ៤១ដល់៤៦)



មេរៀនទី៣ ការទទួលស្គាល់ការពិត

៣.២. អំណានៈ រឿងភ្នំសុពណ៌កាលី

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. តើអំណានរឿង ភ្នំសុពណ៌កាលីជាប្រភេទរឿងបែបអ្វី?

ក. ព្រេងកថា ខ. និទានកថា

គ. ប្រលោមកថា ឃ. ទេវកថា

២. តើភ្នំសុពណ៌កាលី បើយើងមើលពីចម្ងាយមានរាងដូចអ្វី?

ក. រាងដូចមនុស្សស្រី ខ. រាងដូចទូក

គ. រាងដូចសត្វក្រពើ ឃ. រាងដូចសត្វត្រី

៣. តើអ្នកនិពន្ធបង្ហាញបញ្ហាចោទនៅក្នុង "រឿង ភ្នំសុពណ៌កាលី" នៅត្រង់ណា?

ក. ក្រពើនាងឱរៃសម្លាប់លោកនេន ខ. អំណួតរបស់ក្រពើនាងឱរ៉ៃ

គ. ក្រពើនាងឱរ៉ៃប្រយុទ្ធគ្នា ឃ. ចម្លើយទាំង៣

៤. តើនៅក្នុងរឿង"ភ្នំសុពណ៌កាលី"អ្នកនិពន្ធដោះស្រាយបញ្ហាដូចម្តេច?

ក. ឱ្យក្រពើឱរ៉ៃចេះដឹងខុស

ខ. ឱ្យសត្វទាំងពីរទទួលកម្មផលបានសាង

គ. ឱ្យក្រពើក្លាយជាភ្នំបន្សល់ពេលដល់បច្ចុប្បន្ន

ឃ.ឱ្យអ្នកខ្លាំងឈ្នះ រីឯអ្នកខ្សោយត្រូវចាញ់(ស្លាប់)

៥. តើឧត្តមគតិនៅក្នុងរឿង"ភ្នំសុពណ៌កាលី"បង្ហាញពីអ្វីខ្លះ?

ក. ការអួតអាងតែងនាំឱ្យអន្តរាយដល់ជីវិត។

ខ. ឱ្យកូនខ្មែរស្គាល់ពីប្រវត្តិភ្នំដែលមានឈ្មោះជាប់មកដល់សព្វថ្ងៃនេះ។

គ.ឱ្យស្គាល់ប្រវត្តិភ្នំ និងមិនត្រូវមានអំណួតអួតអាងលើខ្លួនឯង។

ឃ. ត្រូវមានសេចក្តីស្មោះត្រង់ចំពោះអ្នកមានគុណរបស់ខ្លួន។

៦. តើនៅក្នុងរឿង"ភ្នំសុពណ៌កាលី" អ្នកនិពន្ធបញ្ចប់ដូចម្តេច?

ក. មានការសោកស្តាយចំពោះកំហុសរបស់ខ្លួន ខ. បញ្ចប់ដោយតួអង្គសំខាន់ៗត្រូវស្លាប់

គ. បញ្ចប់ដោយក្រពើឱរ៉ៃត្រូវមានវិប្បសារី ឃ. បន្សល់ទុកនូវបាបកម្ម

៧. តើក្នុង "រឿង ភ្នំសុពណ៌កាលី" អ្នកនិពន្ធបានបង្ហាញទាក់ទងជំនឿបែបណា?

ក. ជំនឿលើការបន់ស្រន់ទាក់ទងនឹងទឹកន្លែងសក្តិសិទ្ធិ

ខ. ជំនឿលើសាសនាពុទ្ធ (ព្រះសង្ឃ)

គ. ជំនឿជាក់លើខ្លួនឯង

ឃ. ជំនឿលើវត្ថុដែលមានស្រាប់និងគម្ពីរក្បួនខ្នាត

៨. តើរឿងភ្នំសុពណ៌កាលីស្ថិតនៅក្នុងខេត្តណា?

ក. កំពង់ចាម ខ. ក្រចេះ

គ. ស្ទឹងត្រែង ឃ. មិនមានចម្លើយ

៩. អំណាន ភ្នំសុពណ៌កាលីជាប្រភេទអត្ថបទអក្សរសិល្ប៍អ្វី?

ក. ព្រាហ្មណ៍និយម ខ. ពុទ្ធនិយម

គ. ខេមរនិយម ឃ. រឿងព្រេងនិទាន

១០. តើក្នុងរឿង ភ្នំសុពណ៌កាលីអ្នកនិពន្ធបានបង្ហាញពីទឹកន្លែងបែបណា?

ក. ទឹកន្លែងដែលមានក្នុងស្រុកខ្មែរពិតប្រាកដ

ខ. ប្រឌិតដើម្បីឱ្យត្រូវនឹងស្ថានភាពសង្គម

គ. ទឹកន្លែងតាមការស្រមើស្រមៃរបស់អ្នកនិពន្ធ

ឃ. ចម្លើយទាំង៣

II. ចូរប្អូនបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. អាហារដែលប្រមូលឱ្យជាដុំដាក់ក្នុងបាត្រ ចង្ហាន់ដាក់រាប់បាត្រគឺ.....។

២. អមិត្ត សត្រូវ ជា.....។

៣. អានុភាពនៃឫទ្ធិ.....។

៤. ការសម្រេចដោយអំណាច.....។

៥. អាគមវេទ ពាក្យស័ក្តិសិទ្ធិ សម្រាប់សូត្រ.....។

៦. ដែលជន់ឡើង ដែលឡើងកំពុង ទឹកឡើងពោរ.....។

III. ចូរប្អូនរៀបព្រឹត្តិការណ៍តាមលំដាប់លំដោយនៃដំណើររឿងឱ្យបានត្រឹមត្រូវ

[...] កាលដែលមានដំយដម្នះហើយក្រពើនាងឱរ៉ែក៏បានត្រឡប់លំនៅស្ថានវិញ។ ចំណេរកាលក្រោយមក ថ្ងៃមួយពេលក្រពើនាងឱរ៉ែកំពុងបានចម្លងលោកនេន ស្រាប់តែប្រទះនឹងក្រពើបច្ចាមិត្រដទៃទៀតមកបៀតបៀន[...] ។

[...] កាលពីព្រេងនាយមានក្រពើមួយឈ្មោះសុពណ៌កាលី មានមាឌធំមហិមា មានឫទ្ធានុភាពពូកែណាស់ ឥតមានក្រពើណាមួយប្រឡងឫទ្ធិឈ្នះនោះទេ។ ក្រពើសុពណ៌កាលី បានអាស្រ័យនៅអន្លង់មួយឈ្មោះសាលី ដែលសព្វថ្ងៃហៅថា ភូមិអន្លង់សាលី [...]។

[...] ថ្ងៃមួយ ពេលវាដំណែងខ្លួនជាមនុស្សស្រាប់តែឮមនុស្សនិយាយគ្នាថា "ក្រពើនាងឱរ៉ែធំអ្វីប៉ុណ្ណឹងក្រពើសុពណ៌កាលី នៅអន្លង់សាលីធំជាងនេះទៀត"។[...]។

[...]នាងឱរ៉ែបានឮមនុស្សនិយាយដូច្នេះក៏បានប្រែក្រឡាជាក្រពើធំមួយហែលទៅតាមដងទន្លែតូច មានចម្ងាយច្រើនគីឡូម៉ែតសំដៅទៅរកក្រពើសុពណ៌កាលីដើម្បីល្បងឫទ្ធិគ្នា [...]។

IV. សំណួរត្រិះរិះ

១. ចូរបង្ហាញពីបញ្ហាចោទនិងដំណោះស្រាយក្នុងរឿង។

• ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

២. ចូរបកស្រាយពីអត្ថន័យនៃរឿងឱ្យបានក្បោះក្បាយ។

• ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

៣. ចូរបង្ហាញពីតម្លៃអប់រំក្នុងរឿងឱ្យបានក្បោះក្បាយ។

• ចម្លើយ ៖.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

៤. ចូរបង្ហាញលក្ខណៈតួអង្គរបស់ក្រពើនាងឱរ៉ែធៀបជាមួយនឹងមនុស្សក្នុងសង្គមពេលបច្ចុប្បន្ន។

• ចម្លើយ ៖.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។



មេរៀនទី៣ ការទទួលស្គាល់ការពិត

៣.៣. វេយ្យាករណ៍ កំណើតនាមករណ៍ឬករណនាម និងនាមការក៍ឬការកនាម

I. ចូរឬនផ្គូផ្គងចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក "ក"	ផ្នែក "ខ"	ផ្នែក "ចម្លើយ"
១. នាមដែលបង្ហាញពីភាវៈមានជីវិតនិងសកម្មភាពរស់នៅប្រចាំថ្ងៃ។	ក. នាមអជីវចល	១ →
២. នាមសម្រាប់បង្ហាញពីអ្នកដែលធ្វើសកម្មភាព សម្តែងអំពីអំពើលក្ខណៈបែបណាមួយ។	ខ. នាមរូបី	២ →
៣. នាមបង្ហាញពីមនុស្ស សត្វ វត្ថុ ឬរុក្ខជាតិដែលយើងអាចដឹងដោយវិញ្ញាណ។	គ. នាមករណ៍	៣ →
៤. នាមសម្រាប់សម្តែងពីសភាពលក្ខណៈបែបណាមួយ។	ឃ. នាមជីវចល	៤ →
៥. នាមដែលបង្ហាញពីអំពើ គុណភាព ភាពឬលក្ខណៈរបស់មនុស្ស សត្វ ឬវត្ថុ...។	ង. នាមការក៍	៥ →
៦. នាមទាំងឡាយណាដែលបង្ហាញពីភាវៈគ្មានជីវិត ឬមានជីវិតដែរតែពុំមានសកម្មភាពរស់នៅប្រចាំថ្ងៃ។	ច. នាមអរូបី ឆ. សាធារណនាម	៦ →

II. ចូរជ្រើសរើសពាក្យក្នុងប្រអប់ រួចយកបែងចែកទៅតាមប្រភេទនាមករណ៍ឬករណនាមនិងនាមការក៍ឬការកនាមឱ្យបានត្រឹមត្រូវ

សេចក្តីសុខ ការគោរព អ្នកចម្រៀង ទំនប់ ប្រទេស ការការពារ ផ្ទាំ អ្នកនិពន្ធ សំណើម អ្នកនេសាទ ចំណែក វាលស្រែ ថ្មើរជ្រៃ តំបន់ អ្នកទាប ចំណាក ចងចាំ ដំណាំ ល្បឿន អ្នកស្រុក អ្នកក្រីក្រ ការរីកដុះដាល ស្មូម។

នាមករណ៍ ឬករណនាម	នាមការក៍ ឬការកនាម
សេចក្តីសុខ	អ្នកក្រីក្រ

III. ចូរប្អូនកម្លាយពាក្យខាងក្រោមទៅជានាមករណ៍

ពាក្យឬស	នាមករណ៍ ឬករណនាម
កាន់ សើម បាក់ ចែក កាច រុងរឿង ខុស	

IV. ចូរជ្រើសរើសនាមការក៍ចេញពីក្នុងអត្ថបទខាងក្រោម

សន្តិភាព!សន្តិភាព!សំឡេងនេះលាន់ឮខ្ទរខ្ទារ ពេញពិភពលោកទាំងឡាយ ប្រជាជនកំពុងរស់នៅក្នុងសង្គ្រាមទាំងប្រជាជនកំពុងរស់នៅក្នុងសន្តិភាព អ្នកខ្លះបានសុំសន្តិភាពសម្រាប់ខ្លួនឯង អ្នកខ្លះទៀតសុំសន្តិភាពសម្រាប់អ្នកដទៃ។

សន្តិភាពគឺជាមនុញ្ញផលជាទីមនោរម្យនៃប្រជាជនគ្រប់រូប ជាតិសាសន៍គ្រប់រូប គ្រប់ពណ៌សម្បុរគ្រប់ស្រទាប់វណ្ណៈមិនថាជាអ្នកមាន អ្នកក្រ អ្នកធំ ឬអ្នកតូចនោះទេ មានគ្រប់ជាន់ថ្នាក់ក្នុងពិភពលោកនេះ។ សន្តិភាពបានធានាអះអាងជីវិតមនុស្សនិងទ្រព្យសម្បត្តិឱ្យបានស្ថិតស្ថេរ។

V. ចូរប្អូនតែងល្បះឱ្យបាន៦ល្បះ ដោយប្រើប្រាស់នាមករណ៍ និងនាមការក៍។

ឧទាហរណ៍ ៖ មនុស្សគ្រប់រូបតែងតែទទួលបាន*ភាពជោគជ័យ*ពេលដែលមាន*ការតស៊ូ*។

១. ល→.....។

២. ល→.....។

៣. ល→.....។

៤. ល→.....។

៥. ល→.....។

៦. ល→.....។



មេរៀនទី៣ ការទទួលស្គាល់ការពិត

៣.៤. អំណាន កំណើតរាជធានីភ្នំពេញ

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. តើអំណានរឿង កំណើតរាជធានីភ្នំពេញជាប្រភេទរឿងបែបអ្វី?

ក. រឿងបុរាណ ខ. រឿងបែបខេរមនិយម

គ. រឿងព្រេងកថា ឃ. រឿងទេវកថា

២. តើទីកន្លែងដែលសន្មតជាឈ្មោះរាជធានីរបស់ខ្មែរគឺ "រាជធានីភ្នំពេញ" សព្វថ្ងៃ កើតមានតាំងពីពេលណា?

ក. មុនពេលស្ថាបនាព្រះរាជវាំង ខ. មុនមានវត្តអារាមនានា

គ. មុនមានមនុស្សច្រើនរស់នៅ ឃ. មុនពេលមានផ្លូវខ្វាត់ខ្វែង

៣. តើទីកន្លែងនោះមានឈ្មោះអ្វី នៅក្នុងរាជធានីភ្នំពេញសព្វថ្ងៃ?

ក. មានឈ្មោះថា"ព្រះបរមរាជវាំង ខ. មានឈ្មោះថា"វត្តឧណ្ណាលោម

គ. មានឈ្មោះថា"វិមានឯករាជ្យ ឃ. មានឈ្មោះថា "វត្តភ្នំ"

៤. តើរឿង កំណើតរាជធានីភ្នំពេញអ្នកនិពន្ធផ្តើមរឿងដូចម្តេច?

ក. ប្រើពាក្យក្នុងកាលកន្លងទៅ ខ. ប្រើពាក្យកាលពីព្រេងនាយ

គ. បង្ហាញឈ្មោះតួអង្គតែម្តង ឃ. រៀបរាប់ពីទេសភាពធម្មជាតិ

៥. តើអ្នកនិពន្ធបង្ហាញបញ្ហាចោទនៅក្នុង **"រឿង កំណើតរាជធានីភ្នំពេញ"** នៅត្រង់ណា?

ក. កត្តាសាមគ្គីដើម្បីបង្កើតរាជធានីថ្មី ខ. កត្តាភូមិសាស្ត្ររបស់ប្រទេសកម្ពុជា

គ. កត្តាព្រះរាជាផ្លាស់ប្តូររាជធានីថ្មី ឃ. កត្តាលោកយាយពេញជាអ្នកលំបាក

៦. តើអ្នកនិពន្ធប្រើដំណោះស្រាយបែបណានៅក្នុងតួរឿងឬដំណើរ **"រឿងកំណើតរាជធានីភ្នំពេញ"**?

ក. លោកយាយពេញជាអ្នកបង្កើតរាជធានីថ្មីមួយ។

ខ. លោកយាយពេញបានបញ្ជាឱ្យគេរៀបចំរាជធានីថ្មី។

គ. ស្តេចខ្មែរបានជ្រើសរើសទីទួលកេរដំណែលយាយពេញ។

ឃ. មន្ត្រីទាំងអស់នាំគ្នាជួយរៀបចំរាជធានីថ្មីនេះ។

៧. ដំណើររឿងប្រព្រឹត្តទៅនៅគ.ស១៣៧២ រហូតមកដល់គ.ស១៨៦៥ ក្នុងរជ្ជកាលស្តេចនរោត្តមតើគេហៅថាអ្វីនៃរឿង?

ក. កាលនៃរឿង ខ. អាកាសនៃរឿង

គ. ទីកន្លែងពិតនៃរឿង ឃ. សម័យកាលនៃរឿង

៨. ចូរបង្ហាញពីឧត្តមគតិរឿងកំណើតរាជធានីភ្នំពេញ។

ក. ឱ្យស្គាល់ពីដើមកំណើតរាជធានីភ្នំពេញ និងទីតាំងភូមិសាស្ត្រ។

ខ. ឱ្យស្គាល់ពីប្រវត្តិសាស្ត្ររបស់ខ្មែរនិងទីតាំងភូមិសាស្ត្រ។

គ. ឱ្យស្គាល់ពីស្នាព្រះហស្តអតីតបុព្វបុរស និងព្រះមហាក្សត្រ។

ឃ. ស្គាល់ប្រវត្តិសាស្ត្រ ស្នាព្រះហស្តអតីតបុព្វបុរស និងមហាក្សត្រខ្មែរ។

៩. តើអ្នកនិពន្ធបានបញ្ចប់ **"រឿង កំណើតរាជធានីភ្នំពេញ"** ដូចម្តេច?

ក. បញ្ចប់ដោយឱ្យលោកយាយពេញស្លាប់។

ខ. បញ្ចប់ដោយឱ្យតួអង្គព្រះរាជាទទួលបានជោគជ័យ។

គ. បញ្ចប់ដោយឱ្យមានរាជធានីថ្មីគឺរាជធានីភ្នំពេញ។

ឃ. បញ្ចប់ដោយឱ្យលោកយាយពេញទទួលបានជោគជ័យ។

១០. ក្នុង **"រឿង កំណើតរាជធានីភ្នំពេញ"** រាជធានីនេះសាងសង់រួចនៅឆ្នាំ១៤៣៤ ព្រះបាទសម្តេចបរមរាជាពញាយ៉ាតបានប្រទានឈ្មោះថ្មីដល់ក្រុងនេះថា

ក. ក្រុងភ្នំពេញ ខ. ទន្លេចតុមុខ

គ. ទន្លេច្រាបឈាម ឃ. ភ្នំដូនពេញ

១១. ទេវរូបដែលអណ្តែតមកពីស្រុកលាវ គេបានសន្មតហៅព្រះនាមថា៖

ក. អ្នកតាព្រះចៅ ខ. អ្នកតាព្រះចៅស័ង្ខ

គ. អ្នកតាសំរឹទ្ធ ឃ. អ្នកតាម្ចាស់ស្រុក

១២. ដូនពេញបានឃើញព្រះពុទ្ធរូបចំនួនប៉ុន្មានអង្គក្នុងដើមគគីរ?

ក. ២អង្គ ខ. ៣អង្គ

គ. ៤អង្គ ឃ. ៥អង្គ

II. ចូរឫនផ្គូផ្គងចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក "ក"	ផ្នែក "ខ"	ផ្នែក "ចម្លើយ"
១. (ន)ការសម្រេចដោយអំណាច។	ក. មហិទ្ធិឫទ្ធិ	១ ⟶
២. (ន)ឫទ្ធិធំ ឫទ្ធិខ្លាំងក្រៃលែង។	ខ. អាសនៈ	២ ⟶
៣. (គុ) បរិបូណ៌ មានច្រើន។	គ. ស័ក្តិសិទ្ធិ	៣ ⟶
៤. (ន) កន្លែងអង្គុយ។	ឃ. ជ័យភូមិ	៤ ⟶
	ង. ស្តុកស្តម្ភ	៥ ⟶

៥. (ន) ទឹកដីមានជោគជ័យ។ ៦. (កិ) កសាង សាងសង់។	ច. ស្ថាបនា ឆ. លួលួច	៦ ⟶

III. ចូរប្អូនបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. ក្នុងកាលកន្លងទៅហើយនៅ គ.ស១៣៧២មានដូនចាស់ឈ្មោះពេញហៅថា.....។

២. ដូនពេញបានយកកំណាត់ឈើទៅកោសកៀរកក់ចេញ គាត់បានឃើញក្នុងប្រហោងឈើមាន .....ធ្វើអំពីសំរឹទ្ធិ។

៣. ថ្ងៃក្រោយមកដូនពេញបានអំពាវនាវ ឱ្យអ្នកជិតខាងជួយលើកពូនភ្នំដែលនៅខាងលិចផ្ទះគាត់នោះ ឱ្យទៅជា.....។

៤. គាត់យល់ថាទេវរូបនោះអណ្តែតទឹករសាត់មកពីស្រុកលាវ និងមានបែបភាពដូចលាវ គាត់ក៏បានសន្មតថា "....."។

៥. ដូនពេញបានទៅនិមន្តព្រះសង្ឃមកគង់លើជើងភ្នំនោះក្នុងទិសខាងលិច ទើបកើតមានឈ្មោះថា "....."។

IV. ចូរប្អូនរៀបចំព្រឹត្តិការណ៍ក្នុងរឿងឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយ

○ [...] តាមជំនឿអ្នកស្រុកថា ព្រះពុទ្ធរូបទាំងបួនអង្គនិងអ្នកតាព្រះចៅនោះបានបញ្ចេញមហិទ្ធិឫទ្ធិ ឱ្យឃើញពូកែសក្តិសិទ្ធិណាស់ អ្នកដែលបានបន់ស្រន់តែងបានសម្រេចដូចបំណង [...]។

○ [...] ថ្ងៃមួយមានភ្លៀងធ្លាក់យ៉ាងខ្លាំង ធ្វើឱ្យទឹកទន្លេជន់លិចលួលួច។ គ្រានោះដូនពេញចុះទៅកំពង់ទឹកស្រាប់តែឃើញដើមគគីធំមួយ កំពុងអណ្តែតទឹកមកក្បែរមាត់ច្រាំង ហើយដោយអំណាចទឹកហូរចុះឡើង ដើមគគីនោះចេះតែអណ្តែតវិលវល់នៅក្បែរមាត់ច្រាំង [...]។

○ [...] ទីក្រហូងជ្រៅដែលកើតចេញពីការជីកយកដីនោះជាប់ឈ្មោះថា "បឹងតេជោ" គឺដីត្រង់ផ្សារថ្មីសព្វថ្ងៃនេះ។ មកដល់គ.ស១៨៦៥ ព្រះបាទសម្តេចនរោត្តមបានផ្លាស់ព្រះរាជវាំងពីក្រុងឧដុង្គមានជ័យមកគង់នៅក្រុងចតុមុខនេះ [...]។

○ [...] ទេវរូបនោះទ្រង់ឈរ ព្រះហស្តម្ខាងទ្រង់ដំបង ព្រះហស្តម្ខាងទៀតទ្រង់សង្ខ ព្រះកេសទ្រង់ភ្ជង។ ដូនពេញនិងអ្នកជិតខាងដែលបានទៅជួយ មានសេចក្តីត្រេកអរណាស់ដោយរើសបានរបស់ជាតិគោរពក៏នាំគ្នាដង្ហែព្រះបដិមាទាំងនោះ[...]។



មេរៀនទី៤ សាមគ្គីភាព

៤.១. អំណាន ៖ ខ្ញុំត្រូវបានគេនិយាយបញ្ចុះបញ្ចូល

I. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. .....(ន)ភ្លើងអេឡិចត្រូនិច (ពាក្យសន្មតប្រើតាមសម័យនិយម)។

២. .....(កិ) ឃាត់ ហាមលើកចោលឬទាត់ចោលលែងយកជាការបាន។

៣. .....(ន)យសស័ក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង។

៤.....(ន)ភ្នាក់ងារពាណិជ្ជការដែលធ្វើក្នុងក្រសួងផ្សេងៗ ឬជានិយោជិត។

៥.....(ន) ឃ្លាំងដាក់ទ្រព្យ ឬឃ្លាំងប្រាក់។

II. ចូរបំពេញជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. តើនៅក្នុងអត្ថបទ ពាក្យ"ខ្ញុំ" តំណាងឱ្យអ្នកណា?

ក. បុគ្គលិកធនាគារ　　ខ. ប្រធានធនាគារ

គ. ប្រធានក្រុមហ៊ុនអគ្គិសនី　　ឃ. អ្នកនិពន្ធ

២. តើអ្នកនិពន្ធតំណាងតួអង្គមួយណានៅក្នុងអត្ថបទអំណាននេះ?

ក. ប្រធានក្រុមហ៊ុនលក់សម្ភារអគ្គិសនី　　ខ. ប្រធានធនាគារ

គ. បុគ្គលិកធនាគារ　　ឃ. បុគ្គលិកក្រុមហ៊ុនលក់សម្ភារអគ្គិសនី

៣. ចូររកប្រធានបទអំណាន "ខ្ញុំត្រូវគេបញ្ចុះបញ្ចូល" ។

ក. របៀបបញ្ចុះបញ្ចូល　　ខ. លំនាំនៃការបញ្ចុះបញ្ចូល

គ. ការបញ្ចុះបញ្ចូល　　ឃ. គុណសម្បត្តិនៃការបញ្ចុះបញ្ចូល

៤. ការបញ្ចុះបញ្ចូលនរណាម្នាក់ឱ្យបានសម្រេច តើយើងត្រូវយកកត្តាអ្វីមកអនុវត្ត?

ក. កត្តាសាមគ្គីនិងសេចក្តីព្យាយាមរបស់បុគ្គល។

ខ. កត្តាអត់ធ្មត់និងសេចក្តីព្យាយាមរបស់បុគ្គល។

គ. កត្តាជំនឿជាក់និងសេចក្តីព្យាយាមរបស់បុគ្គល។

ឃ. កត្តាតស៊ូ ប្រឹងប្រែង ព្យាយាមនិងបំណិនប្រសប់របស់បុគ្គល។

៥. ចូរជ្រើសរើសពាក្យស្លោកឬសុភាសិតមួយដែលទាក់ទងនឹង **"អំណាន ខ្ញុំត្រូវគេនិយាយបញ្ចុះបញ្ចូល"** ឱ្យបានត្រឹមត្រូវ។

ក. ចំណេះជាអាហារ ប្រាជ្ញាជាអាវុធ ខ. សាមគ្គីជាកម្លាំង

គ. សេចក្តីព្យាយាមគង់បានសម្រេច ឃ. ងើយស្តេកឱនជាក់គ្រាប់

៦. តើគេកំពុងបញ្ចុះបញ្ចូលក្រុមហ៊ុនមានឈ្មោះអ្វី?

ក. Matsushita ខ. Sumitamo

គ. Yuugo ឃ. ចម្លើយទាំង៣

៧. តើក្នុងការបញ្ចុះបញ្ចូលគេត្រូវការអ្វីដែលជាចំណុចសំខាន់?

ក. ផ្តល់ភាពស្មោះត្រង់ចំពោះគ្នា ខ. ការទុកចិត្តភាគីទាំងសងខាង

គ. ការជឿជាក់លើដៃគូសហការ ឃ. ចម្លើយទាំង៣

៨. តើក្នុងអំណាន **"ខ្ញុំត្រូវគេបញ្ចុះបញ្ចូលនេះ"**បានផ្តល់បទពិសោធន៍អ្វីសម្រាប់អ្នកអាន?

ក. ការមិនលះបង់សេចក្តីព្យាយាមធ្វើអ្វីមួយ។

ខ. យល់ចិត្តមនុស្សដែលជាដៃគូ។

គ. រីករាយនឹងការងាររបស់ខ្លួន។

ឃ. ស្វែងយល់ពីការទំនាក់ទំនងគ្នា។

III. ចូរប្អូនសរសេរពាក្យ "**ត្រូវ**" ឬ "**ខុស**" ខាងមុខឈ្មះដែលមានអត្ថន័យក្នុងអំណាន "ខ្ញុំត្រូវគេបញ្ចុះបញ្ចូលនេះ"។

១.....ការបញ្ចុះបញ្ចូលតែងតែមានការបរាជ័យ មុនទទួលបានភាពជោគជ័យ។

២.....មនុស្សទាំងអស់តែងតែមានភាពរីករាយ នៅពេលបានទំនាក់ទំនងជាមួយមនុស្សជុំវិញខ្លួន។

៣.....មនុស្សដែលរីករាយនឹងការងារសុទ្ធទទួលបានការកោតសរសើរពីអ្នកជុំវិញខ្លួន។

៤.....ការរកស៊ីត្រូវតែមានភាពជឿជាក់និងទុកចិត្តលើដៃគូសហការគ្នា។

៥.....ការសម្រេចចិត្តព្រមទទួលយកសំណើពីនរណាម្នាក់វាពិតជាសំខាន់ណាស់។

IV. សំណួរត្រិះរិះ

១. តើអំណានខាងលើមានតម្លៃអប់រំដូចម្តេច?

- ចម្លើយ ៖ .....

.....

.....

.....

.....

.....។

២. តើការបញ្ចុះបញ្ចូលមានផលប៉ុន្មានយ៉ាង? ចូររៀបរាប់។

- ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....។

៣. ចូរប្លូនសរសេរអត្ថបទបញ្ចូលបញ្ចូល "ការយល់ដឹងអំពីបរិស្ថាន"ឱ្យបានក្បោះក្បាយ។

- ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....។



មេរៀនទី៤ សាមគ្គីភាព

៤.២. អំណាន ៖ សាមគ្គីធម៌

I. ចូរផ្គូផ្គងចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក "ក"	ផ្នែក "ខ"	ផ្នែក "ចម្លើយ"
១. វិសហាន	ក. (ន.)កិច្ចដែលគួរធ្វើ ការងារដែលគួរធ្វើ។	១ ⟶
២. បច្ចាមិត្ត	ខ. (កិ.) មិនសុខចិត្តដោយគេបានធ្វើលើសខ្លួន។	២ ⟶
៣. ប្រមាថ	គ. (ន.) សេចក្តីហួង ឬមោះហួង មោះមែដែលនាំឱ្យក្តៅ	៣ ⟶
៤. ឧត្តុងឧត្តម	ក្រហាយ។	៤ ⟶
៥. វឌ្ឍនភាព	ឃ. (ន.) ល្អិតល្អង់យ៉ាងល្អិត។	៥ ⟶
៦. កាតព្វកិច្ច	ង. (ន.) អមិត្ត ឬសត្រូវ។	៦ ⟶
៧. ឧបាយកល	ច. (ន.) សភាវៈឬដំណើរនាំឱ្យរីកចម្រើន។	៧ ⟶
៨. ច្រណែន	ឆ. (ន.) ការបៀតបៀនគេ ការញាំញីគេ។	៨ ⟶
	ជ. (គុ.) ខ្ពង់ខ្ពស់លើសក្រៃលែង ប្រសើរកន្លង។	

II. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. តើសាមគ្គីធម៌មានន័យដូចម្តេច?

ក. ភាពស្រុះស្រួល ព្រមព្រៀងគ្នា ខ. ភាពរួបរួម ស្មោះត្រង់ ព្រមព្រៀងគ្នា

គ. ការយោគយល់ អធ្យាស្រ័យគ្នា ឃ. ភាពស្មោះត្រង់នឹងគ្នា

២. តើសាមគ្គីធម៌កើតឡើងអាស្រ័យលើកត្តាអ្វី?

ក. កត្តាអារម្មណ៍របស់មនុស្ស ខ. កត្តាកាតព្វកិច្ចរបស់មនុស្ស

គ. កត្តាគំនិតរបស់មនុស្ស ឃ. កត្តាចិត្តរបស់មនុស្ស

៣. តើសាមគ្គីធម៌មានផលចម្រើនដូចម្តេច?

ក. មានផលចម្រើនល្អ ខ. មានផលចម្រើនមិនល្អ

គ. មានផលចម្រើនរាប់មិនអស់ ឃ. មានផលចម្រើនល្អនិងមិនល្អ

៤. ហេតុអ្វីបានជាយើងត្រូវមានសាមគ្គីធម៌?

ក. ព្រោះដើម្បីរួមគ្នាការពារទឹកដី សម្បត្តិធម្មជាតិនិងជាតិសាសន៍។

ខ. ព្រោះដើម្បីរួមកម្លាំងគ្នាការពារទឹកដី។

គ. ព្រោះដើម្បីរួមកម្លាំងគ្នាការពារសម្បត្តិវប្បធម៌។

ឃ. ព្រោះដើម្បីរួមសាមគ្គីគ្នាការពារសម្បត្តិធម្មជាតិ។

៥. ដើម្បីឱ្យមានសាមគ្គីធម៌មនុស្សទាំងអស់ត្រូវមានកត្តាសំខាន់អ្វី?

ក. មនុស្សគ្រប់រូបត្រូវមានការប្រកួតប្រជែង។

ខ. មនុស្សម្នាក់ៗហាត់ពត់ទូន្មានចិត្តកុំចង់ឈ្នះ។

គ. ត្រូវចេះប្រើល្បិចក្នុងការទំនាក់ទំនងគ្នា។

ឃ. ត្រូវហាមចិត្តមនុស្សគ្រប់គ្នាកុំគិតអវិជ្ជមាន។

៦. តើយើងត្រូវធ្វើដូចម្តេចដើម្បីរក្សាចំណងសាមគ្គីធម៌បានល្អ?

ក. ត្រូវធ្វើអ្វីតាមសេចក្តីប្រាថ្នារបស់យើង។

ខ. ត្រូវទទួលយកអ្វីដែលយើងបានកំណត់ទុក។

គ. ត្រូវមានសេចក្តីអត់ធ្មត់ ពុះពារគ្រប់ឧបសគ្គដែលមាន។

ឃ. ត្រូវមានសេចក្តីសង្ឃឹមលើបុគ្គលណាម្នាក់។

៧. ដើម្បីរក្សាសាមគ្គីក្នុងចិត្តបានតើមនុស្សគ្រប់រូបគួរតែបោះបង់អ្វី?

ក. មិនត្រូវមានការច្រណែនឈ្នានីសគ្នា។

ខ. មិនត្រូវមានអាស្មិមានះក្នុងចិត្ត។

គ. មិនចេះប្រើឧបាយកលជាមួយអ្នកណាម្នាក់។

ឃ. ចម្លើយទាំង៣

៨. ដើម្បីរក្សាទឹកដី កេរដំណែលវប្បធម៌ សម្បត្តិធម្មជាតិឱ្យបានគង់វង្សតើកូនខ្មែរទាំងអស់ត្រូវមានអ្វី?

ក. ត្រូវពង្រីកបន្ថែមនូវចំណងសាមគ្គីឱ្យបានកាន់តែរឹងមាំ។

ខ. ការព្រមព្រៀគ្នាដោយកាយ វិចារចិត្ត និងកម្លាំងដ៏ខ្លាំង។

គ. ត្រូវបណ្តុះចិត្តជាអ្នកកំណត់លើឧបសគ្គគ្រប់បែបយ៉ាង។

ឃ. ចម្លើយទាំង៣

៩. តើចំណុចមួយណាដែលមិនមែនជាគំនិតក្នុងអត្ថបទ **"អំណាន សាមគ្គីភាព"**នេះ?

ក. និយមន័យនៃសាមគ្គីធម៌ ខ. បង្ហាញពីការរីកចម្រើននៃវប្បធម៌ខ្មែរ

គ. ការរក្សាចំណងសាមគ្គីធម៌ ឃ. បង្ហាញពីការចូលរួមថែរក្សាកម្ពុជទេស

១០. ចូរបង្ហាញសាមគ្គីធម៌ដែលនាំឱ្យមនុស្សមានផលវិបាក។

ក. ការសាមគ្គីគ្នាក្នុងការប្រព្រឹត្តរឿងអបាយមុខ។

ខ. ការសាមគ្គីដែលនាំឱ្យមនុស្សមានការរីកចម្រើន។

គ. ការសាមគ្គីដោយមិនមានចំណងកំហឹង។

ឃ. ការសាមគ្គីប្រកបទៅដោយភាពតស៊ូ អត់ធ្មត់។

III. ចូរប្អូនរកន័យដូចនឹងពាក្យ "ប្រាថ្នា　សាមគ្គី　ប្រមាថ　ទូន្មាន"។

ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....។

IV. ចូរប្អូនរកពាក្យដែលមានន័យផ្ទុយនឹងពាក្យ "ឧបសគ្គ　រក្សា　គង់វង្ស　ស្មោះ　រីករាយ"។

ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....។

V. ចូរប្អូនសរសេរពាក្យ "**ត្រូវ**" ឬ "**ខុស**"នៅខាងមុខល្បះដែលជាគំនិតសំខាន់ទាក់ទងនឹងអត្ថបទអំណាន។

១.....យើងត្រូវមានសេចក្តីសន្តោស និងស្មោះចំពោះកាតព្វកិច្ចដែលយើងធ្វើ។

២.....យើងមិនត្រូវមើលជនណាមួយទ្បើយ គឺមិនប្រកាន់វណ្ណៈពណ៌សម្បុរ។

៣.....ការសាមគ្គីជាឧបករណ៍មួយដែលស័ក្តិសិទ្ធិសម្រាប់មនុស្សទូទៅ។

៤.....កាលបើចិត្តត្រិះរិះទៅហើយឃើញថាមានហេតុផលចេញឆន្ទៈ ចេញពីគំនិត។

៥.....បណ្តុះស្មារតីយោគយល់ អធ្យាស្រ័យឱ្យមានជាដរាបក្នុងចិត្តទៅកាន់អ្នកដទៃ។



មេរៀនទី៤ សាមគ្គីភាព

៤.៣. អំណាន ៖ ដើមកំណើតទំនៀមផ្កាបី

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. តើរឿងទំនៀមផ្កាស្លាបី ដកស្រង់ចេញពីណា?

ក. ស្រង់ចេញពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៦

ខ. ស្រង់ចេញពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៨

គ. ស្រង់ចេញពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៧

ឃ. ស្រង់ចេញពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៩

២. តើការរៀបផ្កាស្លា គេប្រើនៅក្នុងពិធីអ្វី?

ក. ក្នុងពិធីបុណ្យបច្ច័យបួន ខ. ក្នុងពិធីរៀបអាពាហ៍ពិពាហ៍

គ. ក្នុងពិធីបុណ្យចម្រើនព្រះជន្ម ឃ. ក្នុងពីធីភ្ជាប់ពាក្យ

៣. ហេតុអ្វីបានជាពេលរៀបមង្គលការ យើងត្រូវប្រើផ្កាស្លាបី?

ក. ព្រោះផ្កាស្លាទីមួយតំណាងឪពុក ខ. ព្រោះផ្កាស្លាទីពីរតំណាងម្តាយ

គ. ព្រោះនេះជាប្រពៃណីទំនៀមទម្លាប់ ឃ. ព្រោះផ្កាស្លាទីបីតំណាងបង

៤. តើបុរសទស្សន៍ទាយ បានទាយដូចម្តេចនៅពេលគ្មានទូកឬសំពៅឆ្លងសមុទ្រ?

ក. នឹងមានទូកមកដល់បន្តិចទៀត ខ. នឹងមានលាភធំសម្រាប់យើងទាំងអស់គ្នា

គ. នឹងមានសំណាងបានប្រពន្ធគ្រប់ៗគ្នា ឃ. នឹងមានសត្វឥន្ទ្រីពាំកូនក្រមុំស្តេចមកដល់

៥. ក្រោយពីបុរសទាំងបួនបញ្ចេញសមត្ថភាពបានជោគជ័យ ម្នាក់ៗដណ្តើមព្រះនាងធ្វើជាភរិយាតើចៅក្រមកាត់ក្តីឱ្យអ្នកណាទទួលបានព្រះនាង?

ក. បុរសចេះមុជទឹក ខ. បុរសចេះប្រស់

គ. បុរសចេះទស្សន៍ទាយ ឃ. បុរសចេះបាញ់ធ្នូ

៦. តើបុរសទាំងបីនាក់ទៀត ចៅក្រមកាត់ក្តីឱ្យដូចម្តេច?

ក. អ្នកចេះទស្សន៍ទាយទុកជាបង ខ. ម្នាក់ជាឪពុក ម្នាក់ជាម្តាយ ម្នាក់ជាបង

គ. អ្នកចេះបាញ់ធ្នូទុកជាប្អូន ឃ. អ្នកចេះប្រស់ទុកជាឪពុក

៧. តើក្នុងអំណាននេះបានបង្ហាញទាក់ទងនឹងជំនឿអ្វីក្នុងសង្គមខ្មែរ?

ក. ការជឿលើសត្វ ខ. ការជឿលើការទស្សន៍ទាយ

គ. ការជឿលើបាតុភូតចម្លែក ឃ. ជឿលើសមត្ថភាពខ្លួនឯង

៨. តើអំណះអំណាងត្រង់ណាដែលបញ្ជាក់ថាចៅក្រមបានកាត់ក្តីយុត្តិធម៌?

ក. ព្រោះបុរសជាស្វាមីបានប៉ះពាល់រាងកាយព្រះនាងមុនគេ។

ខ. ព្រោះបុរសទាំងបួននាក់ចង់បានព្រះនាងដូចគ្នា។

គ. ដោយសារតែមានការពិចារណាមិនបានត្រឹមត្រូវ។

ឃ. គេតែងតែយកគំនិតចៅក្រមជាការត្រឹមត្រូវបំផុត។

៩. តើមូលហេតុអ្វីបានជាគេលើកបុរសចេះប្រោសជីវិតធ្វើជាម្តាយ?

ក. ដោយសារតែបុរសនោះចេះមើលថែរក្សាអ្នកផ្សេងទៀតបានល្អ។

ខ. ដោយសារតែតាមការកាត់ក្តីរបស់ចៅក្រមយល់ឃើញបែបនេះ។

គ. ដោយសារការប្រោសជីវិតដូចជាការបង្កើតជីវិតថ្មីមួយឡើងវិញ។

ឃ. មកពីបុរសនោះចេះមន្តអាគមខាងវិជ្ជាបែបនេះ។

១០. តើមួយណាមិនមែនជាពិធីស្ថិតក្នុងពីធីមង្គលការ?

ក. ពិធីសែនចងដៃ ខ. ពិធីកាត់ផ្តាស្លា

គ. ពិធីសំពះផ្ទឹម ឃ. គ្មានចម្លើយ

II. ចូរឃ្លួនរៀបចំព្រឹត្តិការណ៍នៃរឿងតាមលំដាប់លំដោយ

.....សម័យថ្ងៃមួយអ្នកទាំងបួនបានគិតគ្នាថា នឹងទៀរៀនសិល្បវិជ្ជាចេះគ្រប់ៗគ្នាហើយ រីឯខ្លួនក៏ធំពេញវ័យហើយដែរ ដូច្នេះពួកយើងនាំគ្នាទៅសុំលាលោកតាព្រះគ្រូបាអាចារ្យ ទៅស្វែងរកទ្រព្យសម្បត្តិ ប្រពន្ធកូនរៀងៗខ្លួនចុះ។

.....បុរសទាំងបួននាក់បានយល់ព្រមតាមការកាត់ក្តីរបស់ចៅក្រម ដោយបានកាត់ក្តីសមហេតុផលត្រឹមត្រូវទៅតាមអ្វីដែលជាការពិត ហើយក៏បានរៀបចំផ្តាស្លាទៅតាមអ្វីដែលចៅក្រមបានប្រាប់ និងតំណាងផ្តាស្លា។ ទំនៀមនេះក៏បានបន្តរហូតមកដល់ពេលបច្ចុប្បន្ន។

.....លុះព្រឹកឡើងថ្ងៃរះពេញពន្លឺ ក៏មានសត្វឥន្ទ្រីមួយបានពាំកូនក្រមុំស្តេច ហើរឆ្លងសមុទ្រមកមែន។ បុរសចេះបាញ់ធ្នូ ហេតុតែត្រេកអរពេកមិនបានពិចារណាក៏បានបាញ់ភ្លាម ត្រូវសត្វឥន្ទ្រីក៏បានធ្លាក់ទាំងកូនក្រមុំស្តេចផងដែរ។

.....មានកុមារកំព្រា៨នាក់ដែលជាមិត្តសម្លាញ់នឹងគ្នា មានឈ្មោះមិនពិតប្រាកដបានបបួលគ្នាទៅរៀនសិល្បៈសាស្ត្រ លុះធ្វើដំណើរយូរទៅក៏បានជួបនឹងអាចារ្យទិសាបាមោក្ខម្នាក់ដែលជាអ្នកបង្រៀនសិល្បៈវិជ្ជាគ្រប់មុខ។

III. ចូរប្អូនសរសេរពាក្យ "**ត្រូវ**" ឬ "**ខុស**"នៅខាងមុខដែលជាគំនិតសំខាន់ក្នុងអត្ថបទអំណាន

១.....អ្នកនិពន្ធចង់បានពីទំនៀមទម្លាប់ខ្មែរក្នុងពីធីរៀបអាពាហ៍ពិពាហ៍ក្នុងសង្គមខ្មែរ។

២.....អ្នកនិពន្ធចង់បានបង្ហាញពីសមត្ថភាពអ្នកទាំង៤នាក់បានរៀនសិល្បៈវិជ្ជា។

៣.....អ្នកនិពន្ធចង់បង្ហាញពីផ្កាស្លាដែលតំណាងឱ្យបុគ្គលនីមួយៗមានន័យដូចម្តេច។

៤.....អ្នកនិពន្ធបានបង្ហាញពីការសិក្សាត្រូវតែមានគ្រូបាអាចារ្យជាអ្នកផ្តល់ឱ្យសិស្ស។

៥.....អ្នកនិពន្ធចង់បានពីការដោះស្រាយបញ្ហាដោយសិស្សសាស្ត្រ មន្តវិជ្ជា។

៦.....អ្នកនិពន្ធបង្ហាញពីការស្រឡាញ់ដោយមានភាពស្មោះត្រង់មិនប្រកាន់វណ្ណៈ។

IV. ចូរប្អូនរកពាក្យន័យដូចនឹងពាក្យ "វិជ្ជា អាចារ្យ មាតា បិតា មេត្តា"។

ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....;

V. ចូរប្អូនរកពាក្យផ្ទុយនឹងពាក្យ "សម្លាញ់ លាភ បារម្ភ"។

.....

.....

.....

.....

.....;

VI. សំណួរត្រិះរិះ

១. ចូររកប្រធានបទនៅក្នុងអត្ថបទអំណាន។

- ចម្លើយ ៖ .....

.....

.....

.....

.....

.....។

២. ចូរសង្ខេបរឿងឡើងវិញឱ្យបានក្បោះក្បាយ។

- ចម្លើយ ៖ .....

.....

.....

.....

.....

.



មេរៀនទី៥ ការកំណត់គោលជៅ

៥.១. បំណិន ៖ ន័យដូចនិងន័យផ្ទុយ

ក. សង្ខេបមេរៀន

- **ពាក្យន័យដូច ៖** ជាពាក្យទាំងឡាយណាដែលមានន័យដូចគ្នា ឬប្រហាក់ប្រហែលគ្នាតែសំណេរ និងសំណូរមិនដូចគ្នានោះទេ។ ពាក្យន័យដូច ក៏ពាក្យមួយប្រភេទដែលកំណត់ន័យដោយទីសេចក្តីដែរ។ ពាក្យមួយអាចមានន័យច្រើន ក្នុងការប្រើប្រាស់ យើងអាចជ្រើសរើសពាក្យន័យដូចគ្នាណាមួយមកប្រើបាន អាស្រ័យលើការកំណត់របស់ទីសេចក្តី។

  ឧទាហរណ៍

  - មើល ៖ ទត ទស្សនា គយគន់ រំពៃ...។
  - មរណៈ ៖ ស្លាប់ សុគត ងាប់ លាចាកលោក...។
  - ឧបត្ថម្ភ ៖ ជួយ ទំនុកបំរុង ជ្រោមជ្រែង...។
  - និពន្ធ ៖ សរសេរ ចារ តែង តាក់តែង...។
- **ពាក្យន័យផ្ទុយ ៖** ជាពាក្យទាំងឡាយណាដែលមានន័យប្រឈមគ្នាឬផ្ទុយគ្នា។ ពាក្យន័យផ្ទុយក៏ជាពាក្យមួយប្រភេទដែលមានន័យកំណត់ដោយទីសេចក្តីដែរ។

  ឧទាហរណ៍

  - ស្រស់ស្រាយ ≠ ស្រពោន ក្រៀមក្រំ ស្វិត...។
  - បរាជ័យ ≠ ជោគជ័យ ជ័យជម្នះ...។
  - សន្តិសុខ ≠ អសន្តិសុខ សង្គ្រាម ច្របូកច្របូល...។
  - សសើរ ≠ បង្អាប់ បន្ទោស បន្ទុះបង្អាប់...។

I. ចូរប្អូនអានអត្ថបទខាងក្រោមហើយអនុវត្តសំណួរ

អត្ថបទ៖

យើងទាំងឡាយជាទាយាទនៃអ្នកដែលចែកឋានទៅហើយ ជាសហការីអ្នកដែលកំពុងរស់នៅនិងជាបុព្វទេពនៃកូនអ្នកដែលកើតជំនាន់ក្រោយ។

បើយើងដាំដើមឈើមួយដើម មុនពេលអនិច្ចកម្មទង្វើបែបនេះពិតជាពុំឥតប្រយោជន៍ឡើយព្រោះយើងបានបន្សល់ទុកឈើមួយដើមដល់មនុស្សជាតិ។ ដើមឈើនោះនឹងផ្តល់ផ្លែផ្កាឬយ៉ាងហោចណាស់ក៏បានជាម្លប់ត្រជាក់ត្រជំសម្រាប់មនុស្សជំនាន់ក្រោយដែរ។ រុក្ខជាតិមួយដើម ឧបករណ៍មួយ សៀវភៅមួយ បដិមាមួយ ផ្ទាំងគំនូរវិចិត្រមួយ តក្កកម្មវិទ្យាសាស្ត្រមួយ សុទ្ធតែជារបស់ដែលយើងម្នាក់ៗអាចមានលទ្ធភាពបង្កើតបានដើម្បីបញ្ចូលជាសម្បត្តិរបស់មនុស្សជាតិ។

ដូចនេះយើងម្នាក់ៗគប្បីប្រឹងប្រែងឱ្យអស់សមត្ថភាព ដើម្បីបច្ចាសន្តានរបស់យើង បានទទួលសេចក្តីសុខក្សេមក្សាន្តជាងយើងសព្វថ្ងៃនេះ។

ក. ចូរប្អូនរកន័យដូចនឹងពាក្យ "អនិច្ចកម្ម ប្រឹងប្រែង សម្បត្តិ បង្កើត"។

ខ. ចូរប្អូនរកន័យនឹងពាក្យ "ត្រជាក់ បញ្ចូល បង្កើត ក្សេមក្សាន្ត"។

II. ចូរអានអត្ថបទដកស្រង់ខាងក្រោម រួចស្រង់ពាក្យន័យដូចនិងន័យផ្ទុយដែលមានក្នុងអត្ថបទ

ក្រឡេកមើលទង់ជាតិបក់រវើចៗ កណ្តាលរលកអាកាសវេហាហ៍ប្រជាជនខ្មែរ តែងនាំគ្នាបណ្តែតអារម្មណ៍ទៅកាន់ប្រាសាទបុរាណដ៏មានកំពូលស្រួចត្រដឹម បង្ហាញអរិយធម៌ត្រចះត្រចង់របស់ខ្មែរនាសម័យកាលមុនដ៏រុងរឿងបំផុត។ អង្គរវត្តជាប្រាសាទមួយ ដែលដូនតាយើងបានប្រើពេលវេលាដ៏យូរនិងបូជាជីវិតដ៏ច្រើនក្នុងការកសាងស្នាដៃទុកឱ្យកូនចៅជំនាន់ក្រោយ។ ប្រជាជនទូទាំងសកលលោកតែងតែសរសើរខ្មែរពីការរចនាវត្ថុ និងបុរាណដ្ឋានទាំងឡាយ។ កវី អ្នកនិពន្ធសឹងតែគ្រប់ប្រទេសដែលស្ថិតក្នុងធរណីមណ្ឌលនេះហើយដែលបានទស្សនាអតីតសុវណ្ណភូមិនេះ សុទ្ធតែបានសរសេរវេចខ្ចប់ដោយផ្ទិតផ្ទង់នូវព័ត៌មានពីអង្គរវត្តដើម្បីយកទៅប្រាយប្រាប់អ្នកអានថា ខ្លួនបានដឹងច្បាស់លក្ខណៈអរិយធម៌ដ៏មានរស្មីរុងរោចន៍របស់ប្រទេសកម្ពុជា។

III. ចូរប្អូនជ្រើសរើសក្នុងប្រអប់ដែលមានន័យដូចគ្នាយកទៅជំនួសក្នុងឃ្លះ

ពិសា ~~អាទនភាព~~ ឧស្សាហ៍ ស្លាប់ ប្រមាថ ទស្សនា ឧបត្ថម្ភ សាងសង់

មោទនភាព

ឧទាហរណ៍ ៖ កូនខ្មែរគ្រប់រូប~~គោតស្ងប់ស្ងែង~~នឹងស្នាដៃរបស់ដូនតាខ្មែរគ្រប់ជំនាន់។

១. ពិសីបានរៀបចំម្ហូបអាហារជូនម្តាយឪពុកហូប។

២. សាលារៀនមួយខ្នងបានស្ថាបនារួចរាល់ចុងខែធ្នូនេះ។

៣. សិស្សានុសិស្សមួយក្រុមព្យាយាមសិក្សាមុនពេលប្រឡងឆមាសនេះ។

៤. កវីខ្មែរបានមរណភាពក្នុងសម័យខ្មែរក្រហម។

៥. កូនខ្មែរគ្រប់រូបមិនគួរមើលងាយសមត្ថភាពគ្នាឡើយ។

៦. ជនបរទេសមួយតែងតែមកមើលប្រាសាទបុរាណខ្មែរ។

៧. រាជរដ្ឋាភិបាលបានជួយប្រជាជនដែលកំពុងជួបបញ្ហានឹងគ្រោះទឹកជំនន់។



មេរៀនទី៥ ការកំណត់គោលដៅ

៥.២. អំណាន ៖ បណ្តាំឪពុក

I. ចូរប្អូនផ្គូផ្គងចំណុចខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក "ក"	ផ្នែក "ខ"	ផ្នែក "គ"ឆ្លើយ"
១. ធ្វើយ	ក. (គុ.) ផ្អែម ធ្ងាញ់ ពីរោះ។	១ ⟶
២. និន្ទា	ខ. (គុ.) ដែលងើយឡើង ឆ្គងខុសទំនង ដែលឆ្វេង។	២ ⟶
៣. ឥរិយា	គ. (ន.) ការត្រិះរិះ រំពឹងទុកបំភ័យដោយឧបាយកល	៣ ⟶
៤. ឧបមា	ឱ្យរឹតតែភ័យ។	៤ ⟶
៥. មធុរ	ឃ. (ន.) ដំមណើរតិះដៀល ការរិះគន់។	៥ ⟶
៦. ព្យូហ៍	ង. (ន.) ឫកពា កិរិយា លំនាំឫកពា។	៦ ⟶
	ច. (ន.) សេចក្តីប្រៀបធៀប ប្រៀបប្រដូច។	

II. ចូរប្អូនពន្យល់អត្ថន័យកំណាព្យក្នុងវគ្គខាងក្រោម

- សូវស្លាប់ទៅជា ឱ្យគិតជញ្ជឹង
  កុំបង់ធម្មា រំពឹងឱ្យសព្វ ពាក្យគាប់ឱ្យយក។
  ឥរិយាសីលគាប់ ពាក្យស្លែងកុំស្អប់
- ចង់គង់ឱ្យទុក យើញច្បាប់ធម៌អាថ៌
  ចង់បានក្តីសុខ ឱ្យយកខ្លួនជ្រក ឱ្យចៀសចេញឆ្ងាយ។
  ឱ្យស្វែងដើរកក្តីសោកមមោក

III. ចូរប្អូនបង្ហាញពីចួន ផ្ងួន រណ្តំក្នុងកំណាព្យវគ្គខាងក្រោម

- កូនអើយលោកិយ រៀនទាំងសម្តី
  នេះឱ្យរៀនក្តី កុំបីរាយមាយ ក្តីគួរក្តីសម។
  រៀនច្បាប់ទាំងឡាយ ក្តីក្រក្តីងាយ
- ឱកូនពុំងា រៀនដាក់រៀនទុក
  ធម្មតាអ្នកជា រៀនរៀបរៀនចំ លក់ចេញទិញចូល។
  ឱ្យរៀនថែទាំ រៀនរករៀនសម



មេរៀនទី៥ ការកំណត់គោលដៅ

៥.៣. អំណាន ៖ ការរុករករបស់លោកគ្រីស្តុបកូឡុំ

I. ចូរប្អូនបំពេញចន្លោះនូវឈ្មោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. .....(ន.) អ្នកគ្រប់គ្រងរក្សាប្រទេស។

២. .....(ន..) ទីប្រជុំប្រឹក្សាការសម្រាប់ប្រទេស។

៣. .....(ន.) ដួងចិត្ត បេះដូង ចិត្ត។

៤. .....(ន.) ទិសដៅ គោលដំណង។

៥. .....(ន.) ទ្រព្យដើម ប្រាក់ដើម ដើមទុន។

៦. .....(កិ.) ផ្គត់ផ្គង់ គាំទ្រ។

II. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. តើលោកគ្រីស្តុប កូឡុំបានរស់នៅឯណា?

ក. ទីក្រុងឡុង ខ. ទីក្រុងសេនូ

គ. ទីក្រុងអាំទែន ឃ. ទីក្រុងម៉ិកសិកកូ

២. លោកគ្រីស្តុប កូឡុំបានចេញពីទ្វីបអឺរ៉ុបដោយបែរមុខឆ្ពោះ ទៅខាងកើតពេលត្រឡប់មកវិញមកកាន់ទិសអ្វី?

ក. ទិសបស្ចឹម ខ. ទិសបូព៌ា

គ. ទិសអាគ្នេយ៍ ឃ. ទិសទក្សិណ

៣. តើឆ្នាំណាដែលមិនមែនជាឆ្នាំលោកគ្រីស្តុប កូឡុំបានចេញដំណើរ?

ក. ១៤៩៣-១៤៨៦ ខ. ១៥០២-១៥០៤

គ. ១៤៩៨-១៥០០ ឃ. ១៥០២-១៥០០

៤. លោកគ្រីស្តុប កូឡុំបានធ្វើលិខិតស្នើដល់រដ្ឋាភិបាល តើលើកលែងតែរដ្ឋាភិបាលអ្វី?

ក.រដ្ឋសភាព័រទុយហ្គាល់ ខ. .រដ្ឋសភាអេស្ប៉ាញ

គ. .រដ្ឋសភាអង់គ្លេស ឃ. រដ្ឋសភាសហរដ្ឋអាមេរិក

៥. ក្នុងការរុករកទាំង៤លើកតើលោកគ្រីស្តុប កូឡុំបានរកឃើញកោះអ្វី?

ក. កោះបាហាម៉ា ខ. កោះគូបា

គ. កោះហៃទី ឃ. ហ្គារ៉ូន

III. ចូរបំពេញសរសេរពាក្យ "**ត្រូវ**" ឬ "**ខុស**"នៅខាងមុខឃ្លះដែលជាគំនិតត្រឹមត្រូវក្នុងអត្ថបទ

១. ជនមួយចំនួនបានយល់ឃើញថាទស្សនៈថារបស់លោកគឺឆ្កួត។

២. ព្រះនាងអេលីសាបេឡាមិនបានជួយអ្វីដល់លោកគ្រីស្តុប កូឡុំនោះទេ។

៣. លោកគ្រីស្តុប កូឡុំបានយល់ឃើញថាពិភពលោកនេះមានរាងមូល។

៤. លោកគ្រីស្តុប កូឡុំបានចេញរកមិត្តម្នាក់ ដែលបុគ្គលសំខាន់និងមានកេរ្តិ៍ឈ្មោះ។

៥. លោកគ្រីស្តុប កូឡុំបានអស់សង្ឃឹមក្នុងការរុករកទ្វីបនេះ។

IV. សំណួរត្រៃរិះ

១. ចូររកន័យដូចនឹងពាក្យ ៖ "លិខិត មើល សៅហ្មង ហប្ញទ័យ ប្រឹក្សា"។

- ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....។

២. ចូររកន័យផ្ទុយនឹងពាក្យ ៖ "ដំបូង ធំ សរសេរ សរសើរ ស្រឡាញ់ គោរព"។

- ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....។

៣. ចូររកគំនិតសំខាន់ក្នុងអត្ថបទអំណានខាងលើឱ្យបានក្បោះក្បាយ។

- ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

៤. ចូរសង្ខេបអត្ថបទអំណានឡើងវិញ។

- ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....

.



មេរៀនទី៥ ការកំណត់គោលដៅ

៥.៤. អំណាន ៖ ទិសដៅនៃជីវិត

I. ចូរបួនបំពេញបន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

[...] គោលដៅគឺជាគ្រឿងដឹកនាំ.....ឱ្យដើរតាមអ្វីដែលយើងបានកំណត់។ យើងត្រូវគិតថាយើងត្រូវតែ.....ធ្វើនូវអ្វីដែលយើងបានគិត ពុំមិនដូចនោះទេនឹងមិនទទួលបាន .....ដូចដែលយើងចង់បាននោះទេ។ បន្ទាប់ពីបានកំណត់.....ហើយជំហានបន្តទៅទៀតគឺយើងត្រូវធ្វើ.....សកម្មភាពដើម្បីញុំាងទិសដៅនោះឱ្យសម្រេចបាន .....តាមការកមណត់។.....គឺគម្រោងសកម្មភាពការងារជាវិជ្ជមានដែលយើងបានគំណត់.....ច្បាស់លាស់និងទំហំកិច្ចការឬ.....ដែលអាចឱ្យការងារនោះប្រព្រឹត្តិទៅបាន [...] ។

II. ចូរបួនរៀបព្រឹត្តិការណ៍តាមលំដាប់ដោយ

.....ទិសដៅរបស់មនុស្ស គឺចង់ឱ្យខ្លួនបានល្អប្រសើរ ចង់ឱ្យខ្លួនមានកិត្តិយស កេរ្តិ៍ឈ្មោះនិងទទួលបានការរាប់អានច្រើន ពីសំណាក់អ្នកផងទាំងពួង។ យើងមិនចង់ឱ្យខ្លួនយើងរស់នៅក្នុងសភាពអាប់ឱន គ្មានកិត្តិយស កេរ្តិ៍ឈ្មោះ និងគ្មានការរាប់អានពីសំណាក់អ្នកដទៃនោះឡើយ។

.....ទីបំផុតក្នុងការរស់នៅរបស់មនុស្សម្នាក់ៗ ត្រូវមានផែនការ ទើបយើងអាចដឹកនាំខ្លួនយើងឱ្យធ្វើដំណើរទៅរកភាពល្អប្រសើរ ខ្ពង់ឡើងៗចាប់ពីពេលបច្ចុប្បន្នរហូតដល់ពេលអនាគត។ យើងត្រូវកសាងជីវិតរស់នៅឱ្យមានការភិវឌ្ឍសន្សឹមៗឆ្ពោះទៅរកឧត្តមភាពដែលនាំមកនូវប្រយោជន៍ក៏ដូចជាដល់សង្គមជាតិទាំងមូលផងដែរ។

.....ន័យនៃជីវិតមិនសំដៅត្រឹមតែលើភាពហ៊ឺហា ការដើរលេងសប្បាយឬមានប្រាក់កាសច្រើននោះទេការមានការងារល្អធ្វើនោះទេ ប៉ុន្តែជីវិតត្រូវតែមានគោលដៅច្បាស់លាស់និងប្រកបដោយឧត្តមគតិខ្ពង់ខ្ពស់។



មេរៀនទី៦ ស្មារតីទទួលខុសត្រូវ

៦.១. បំណិន ៖ លក្ខណៈសម្គាល់រឿងល្ខោន

I. ចូរប្អូនជ្រើសរើសចម្លើយត្រឹមត្រូវ

១.មហោស្រពមួយប្រភេទលេងរាំផ្សេងៗ

ក.សម្តែង ខ.របាំ

គ.ល្ខោន យ.យីកេ

២.ពាក្យពីដើមពាក្យរបស់ល្ខោនគឺ

ក.អេឡា ខ.អៃឡាំ

គ.ល្ខោន យ.អៃម៉ា

៣.តើល្ខោនមានអត្តសញ្ញាណតាំងពីពេលណា?

ក.សម័យមុនអង្គរ ខ.សម័យក្រោយអង្គរ

គ.សម័យអង្គរ យ.សម័យលង្វែក

៤.តើណាមួយខាងក្រោមជាប្រភេទល្ខោន?

ក.ល្ខោនខោល ខ.ល្ខោនតុក្កតា

គ.ល្ខោនកំណាព្យ យ.ចម្លើយទាំងអស់

៥.តើណាមួយខាងក្រោមមិនមែនជាល្ខោន?

ក.ល្ខោនយីកេ ខ.ល្ខោនតុក្កតា

គ.ល្ខោនចម្រុះ យ.គ្មានចម្លើយ

៦.ចែកជាឈុតធាក អាចសរសេរជាពាក្យកាព្យ ពាក្យរាយពាក្យពោលឬការសន្ទនារវាងតួអង្គ និងតួអង្គ ហើយនៅដើមអត្ថបទមានរាយនាមតួអង្គ ឋាន:.....

ក.សំណេរ ខ.សំណេរអត្ថបទល្ខោន

គ.សំណេរអត្ថបទរឿង យ.កំណាព្យល្ខោន

៧. រឿងទាំងឡាយណាដែលអ្នកនិពន្ធបានបែងចែកឈុកនិងធាកជាប្រភេទរឿងអ្វី?

ក.ល្ខោន ខ. ប្រលោមលោក

គ. រឿងព្រេងនិទាន យ. អត្ថបទកំណាព្យ

៨. តើរឿងខាងក្រោមមួយណាមិនមែនជាប្រភេទអត្ថបទល្ខោន?

ក. រឿងកុលាបប៉ែលិន ខ. រឿង ថៅកែចិត្តចោរ

គ. រឿង តេជោយ៉ត យ. អំណាន កំហុសអ្នកណា



មេរៀនទី៦ ស្គាល់តើឧទ្ទេសខុសត្រូវ

៦.២. បំណិន ៖ វិធីបង្ហាញតួអង្គក្នុងរឿងល្ខោន

I. ចូរប្អូនជ្រើសរើសចម្លើយត្រឹមត្រូវមួយ។

១. តើឃ្លាខាងក្រោមមួយណាមិនមែនជានិយមន័យអត្ថបទល្ខោន?

ក. ជាអត្ថបទអក្សរសិល្ប៍មួយប្រភេទគេយកទៅសម្តែងលើឆាក

ខ. អត្ថបទត្រូវតែជាពាក្យកាព្យ

គ. បែងចែកជាឈុតនិងឆាក

ឃ. មានបញ្ជីរាយនាមរបស់តួអង្គ

២. ទម្រង់សំណេរអត្ថបទល្ខោនខុសពីទម្រង់សំណេរអត្ថបទរឿងប្រលោមលោកត្រង់៖

ក. អត្ថន័យនៃរឿង ខ. វិធីតែងនិពន្ធ

គ. រាយនាមឈ្មោះតួអង្គ ឋានៈ ឃ. ចម្លើយទាំង៣

៣. ជាសិល្បៈមួយបប្រភេទដែលអ្នកនិពន្ធយកទៅសម្តែងលើឆាកជា៖

ក. ល្ខោន ខ. អត្ថបទល្ខោន

គ. រឿងព្រេងនិទាន ឃ. ប្រលោមលោក

៤. ការបង្ហាញតួអង្គដោយបុគ្គលណាម្នាក់ទៀតហៅថាអ្វី?

ក. បង្ហាញតួអង្គដោយខ្លួនឯង ខ. ការបង្ហាញដោយអ្នកដទៃ

គ. ការបង្ហាញដោយអ្នកនិពន្ធ ឃ. ការបង្ហាញដោយដំណើររឿង

៥.តើវិធីបង្ហាញតួអង្គមានប៉ុន្មានបែប?

ក.១ ខ.២

គ.៣ ឃ.៤

៦. នៅពេលតួអង្គមួយចេញមកសម្តែងប្រាប់ឈ្មោះខ្លួនឯងផ្ទាល់ តើជាវិធីបង្ហាញតួអង្គមួយណា?

ក. តួអង្គបង្ហាញតួអង្គខ្លួនឯង ខ. តួអង្គបង្ហាញតួអង្គដទៃ

គ. ដំណើររឿងបង្ហាញតួអង្គ ឃ. អ្នកនិពន្ធបង្ហាញតួអង្គ

៧. នៅពេលតួអង្គសន្ទនាគ្នាបន្ទាប់មកវ៉ែកឈ្មោះតួអង្គម្នាក់ទៀត តើជាវិធីបង្ហាញតួអង្គមួយណា?

ក. តួអង្គបង្ហាញតួអង្គខ្លួនឯង ខ. អ្នកនិពន្ធបង្ហាញតួអង្គ

គ. តួអង្គបង្ហាញតួអង្គដទៃ ឃ. ដំណើររឿងបង្ហាញតួអង្គ

៨. ការសរសេររាយនាមតួអង្គ មុខងារ ប្រភពកំណើតរបស់តួអង្គ តើជាវិធីបង្ហាញតួអង្គមួយណា?

ក. តួអង្គបង្ហាញតួអង្គដទៃ ខ. អ្នកនិពន្ធបង្ហាញតួអង្គ

គ. ដំណើររឿងបង្ហាញតួអង្គ ឃ. តួអង្គបង្ហាញតួអង្គខ្លួនឯង

៩. នៅពេលដែលដំណើររឿងកំពុងប្រព្រឹត្តទៅ ស្រាប់តែមានតួអង្គម្នាក់ទៀតចេញមកធ្វើសកម្មភាពជាមួយ តើជាវិធីបង្ហាញតួអង្គមួយណា?

ក. ដំណើររឿងបង្ហាញតួអង្គ ខ. តួអង្គបង្ហាញតួអង្គដទៃ

គ. តួអង្គបង្ហាញតួអង្គខ្លួនឯង ឃ. អ្នកនិពន្ធបង្ហាញតួអង្គ

II. ចូរប្អូនផ្គូផ្គងផ្នែកខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក "ក"	**ផ្នែក "ខ"**	**ចម្លើយ**
ក.វិធីបង្ហាញតួអង្គដោយតួអង្គផ្ទាល់	១.សរសេររាយឈ្មោះ ហាន:អាយុតួអង្គនៅខាងដើមអត្ថបទ។	ក
ខ.បង្ហាញតាមរយៈសាច់រឿង ឬសកម្មភាព	២.ជាការប្រកាសអាយុ ភេទ មុខងារតាមតួអង្គផ្ទាល់	ខ
គ.បង្ហាញតួអង្គដោយអ្នកនិពន្ធ	៣.តាមរយៈតួអង្គដទៃ	គ

III. សំណួរ

១.ចូរប្អូនអានអត្ថបទល្ខោនសំបុកឥតមេបារួចបង្ហាញពីវិធីបង្ហាញតួអង្គ។

- ចម្លើយ ៖ .....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

២.ចូរប្អូនបង្ហាញពីតួអង្គសំខាន់ៗក្នុងរឿងតេជោយ៉ោតព្រមទាំងបង្ហាញពីវិធីបង្ហាញតួអង្គនីមួយៗ។

- ចម្លើយ ៖ .....

.....

.....

.



មេរៀនទី៦ ស្មារតីទទួលខុសត្រូវ

៦.៣.អំណាន ៖ កំហុសអ្នកណា

មេរៀនសង្ខេប

រឿងនេះស្ថិតក្នុងទីក្រុង រ៉ូមីណា ប្រទេសអ៊ីតាលីហើយចាប់ផ្តើមឡើង ដោយជម្លោះគ្រួសារម៉ុងតេហ្គុយ និងកាប់ពុយឡែត។ជម្លោះគ្រួសារទាំងពីរមិនដឹងកើតឡើងពីពេលណាទេ រ៉ូមេអូជាកូនក្នុងគ្រួសារម៉ុងតេហ្គុយ រីស៊ុលីយ៉ែតជាកូនគ្រួសារកាពុយឡែត។ ឪពុកម្តាយរបស់នាងចង់ឱ្យរៀបការជាមួយ ប៉ារីស៍ទើបគ្រួសារកាពុយឡែតរៀបចំប្រារព្ធពិធីក្នុងគេហដ្ឋានកាពុយឡែត រ៉ូមេអូក៏ទៅចូលរួមពីធីនោះដែរហើយក៏បានជួបនឹងស៊ុលីយ៉ែត ស៊ុលីយ៉ែតនិងរ៉ូមេអូរក៏បានចាប់ចិត្តស្រឡាញ់គ្នា។ ព្រះសង្ឃឡូរិនជួយស៊ុលីយ៉ែតនិងរ៉ូមេអូរៀបការដោយសម្ងាត់ នៅថ្ងៃដែលពួកគេរៀបការរ៉ូមេអូ ក៏ជ្រុលដៃសម្លាប់បងបងប្អូនជីដូនមួយស៊ុលីយ៉ែត ទើបព្រះអង្គបណ្តេញគេចេញពីរ៉ូណា។ ក្រោយមកស៊ុយលីយ៉ែតត្រូវបានបង្ខំឱ្យរៀបការជាមួយស៊ុលីយ៉ែតម្តងទៀតជាមួយប៉ារីស៍ ព្រះសង្ឃឡូរិនក៏បានជួយនាង ដោយឱ្យស៊ុលីយ៉ែតធឹកថ្នាំបិទជីពចរយ:ពេលខ្លីប្រៀបដូចស្លាប់រួចក៏ដើរប្រាប់គេថាស៊ុលីយ៉ែតស្លាប់ ក៏ប៉ុន្តែផែនការរបស់ពួកគេគឺបរាជ័យ ព្រោះរ៉ូមេអូបានដឹងដំណឹងថាស៊ុលីយ៉ែតស្លាប់ក៏ស្តាត់មកជួបនាងទាំងយប់ រួចលេបថ្នាំពុលសម្លាប់ខ្លួនក្បែរស៊ុលីយ៉ែត។ បន្តិចក្រោយមកស៊ុលីយ៉ែតបានដឹងខ្លួនឡើង ឃើញបុរសជាទីស្នេហាបានពុលស្លាប់ក៏ចាក់សម្លាប់ខ្លួន ទីបំផុតគ្រួសារទាំងពីរឈប់ឈ្លោះគ្នាពីពេលនោះមក។

I. ចូរឆ្លើយជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. ការបង្ហាញតួអង្គដោយបុគ្គលណាម្នាក់ទៀតតើជាអ្វី?

ក. បង្ហាញតួអង្គដោយខ្លួនឯង ខ. ការបង្ហាញដោយអ្នកដទៃ

គ. ការបង្ហាញដោយអ្នកនិពន្ធ ឃ. ការបង្ហាញដោយដំណើររឿង

២. រឿងរ៉ូមេអូនិងស៊ុលយែតជាអក្សរសិល្ប៍អ្វី?

ក. អក្សរសិល្ប៍ខេមរនិយម ខ. អក្សរសិល្ប៍ពុទ្ធនិយម

គ. អក្សរសិល្ប៍បរទេស ឃ. អក្សរសិល្ប៍ព្រាហ្មនិយម

៣. កាលកំណត់តែងនៅគ.សណា?

ក. គ.ស ១៥៩៥ ខ. គ.ស ១៥៩៦

គ. គ.ស ១៥៩៧ ឃ. គ.ស ១៥៩៨

៤. តើរឿងរ៉ូមេអូស៊ុលយែតបកប្រែដោយអ្នកណា? នៅឆ្នាំណា?

ក. សេកស្ពៀរ ឆ្នាំ១៩៧០ ខ. សេកស្ពៀរ ឆ្នាំ១៩៧៥

ខ. ហង្ស ធុនហាក់ ឆ្នាំ១៩៧២ ឃ. ហង្ស ធុនហាក់ ឆ្នាំ១៩៧១

៥. រឿងRomeo and julietជាប្រលោមលោកបែបអ្វី?

ក. បែបទុក្ខសោក ខ. បែបស្នេហាកម្សត់

គ. បែបមនោសញ្ចេតនា ឃ. បែបលួងលោម

៦. តើRomeoជាកូនប្រុសរបស់នរណា?

ក. កាប់ពុយឡែត ខ. ឧកញ៉ាម៉ុងតេហ្គុយ

គ. បាល់ថេហ្សារ ឃ. ព្រះអង្គម្ចាស់

៧. តើ Julietជាកូនរបស់នរណា?

ក. កាប់ពុយឡែត ខ. ឧកញ៉ាម៉ុងតេហ្គុយ

គ. បាល់ថេហ្សារ ឃ. ព្រះអង្គម្ចាស់

៨.តើអត្ថបទនេះមានតម្លៃអប់រំយ៉ាងដូចម្តេច?

ក.មិនត្រូវកុហកអ្នកដទៃ ខ.កុំស្រឡាញ់គ្នា២ថ្ងៃហើយការ

គ.ការស្លាប់មិនមែនជាមធ្យោបាយ ឃ.ចម្លើយ ក និង គ

៩.ហេតុអ្វីរ៉ូមេអូត្រូវបណ្តេញចេញពីទីក្រុង?

ក.សម្លាប់ប៉ារីស៍ ខ.សម្លាប់បងប្អូនដីដូនមួយស៊ុលីយ៉ែត

គ.លួចរួមមេត្រីជាមួយស៊ុលីយ៉ែត ឃ.គ្មានចម្លើយ

១០.ហេតុអ្វីបានជាស៊ុលីយ៉ែតស្លាប់?

ក.ព្រោះរ៉ូមេអុមិនបានមកជួបនាង ខ.ព្រោះនាងលេបថ្នាំដែលព្រះសង្ឃឡូរ៉ែនឱ្យ

គ.ព្រោះនាងដឹងថារ៉ូមេអូស្លាប់ ឃ.ព្រោះនាងត្រូវបង្ខំពីឪពុកម្តាយ

១១.ហេតុអ្វីបានជាគ្រួសារទាំងពីរដំទាស់មិនឱ្យពួកគេទាក់ទងគ្នា?

ក.មកពីពួកគេរៀនអត់ទាន់ចប់ ខ.មកពីគ្រួសារទាំងពីរឈ្លោះគ្នាតាំងពីដើម

គ.ព្រោះរ៉ូមេអូមានកូន ឃ.ព្រោះស៊ុលីយ៉ែតបានភ្ជាប់ភាក្យជាមួយប៉ារីស៍

១២.ហេតុអ្វីបានជាព្រះសង្ឃឡូរ៉ែនព្រមជួមរ៉ូមេអូនិងស៊ុលីយ៉ែត?

ក.ព្រោះគាត់មានបំណងល្អចង់ផ្សះផ្សាគ្រួសារទាំងពីរ ខ.ព្រោះគាត់បានទទួលលុយ

គ.ព្រោះគាត់អាណិតប៉ារីស៍ ឃ.គ្មានចម្លើយ

១៣. តើអត្ថបទ **"អំណាន កំហុសអ្នកណា"** តួអង្គណាជាអ្នកមានកំហុសធំជាងគេ?

ក. ព្រះសង្ឃឡូ រ៊ុន ខ. ឪពុកម្តាយស៊ុលីយែត

គ. រ៉ូមេអូ ឃ. ស៊ុលីយែត

១៤. តើអត្ថបទអំណាន"កំហុសអ្នកណា" ដកស្រង់ចេញពីរឿងអ្វី?

ក. រឿងស្នេហាមួយ ខ. រឿងរ៉ូមេអូនិងស៊ុលីយែត

គ. រឿងទុំទាវ ឃ. រឿងវិប្បដិសារី

១៥. តើអត្ថបទអំណាន"កំហុសអ្នកណា" កែសម្រួលដោយអ្នកនិពន្ធឈ្មោះអ្វី?

ក. ញ៉ុក ថែម ខ. នូ ហាច

គ. លាង ហាប់អាន ឃ. ហង្ស ធុនហាក់

១៦. អត្ថបទអំណាន"កំហុសអ្នកណា" ជាប្រភេទអត្ថបទ.....<u>លើកលែងតែ</u>ៈ

ក. អត្ថបទព័ត៌មាន ខ. អត្ថបទល្ខោន

គ. អត្ថបទប្រលោមលោក ឃ. អត្ថបទរឿងព្រេង

II. ចូរបួនបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. ការប្រាប់ឈ្មោះ ឋានៈ អាយុ ប្រភពកំណើតរបស់តួអង្គនីមួយៗជា.....។

២. ជាពាក្យសម្រាប់បន្ថែមនៅខាងដើមពាក្យឫសហៅថាៈ.....។

៣. ជាទម្រង់សិល្បៈម្យ៉ាងដែលមានប្រភពមកពីបរទេស (អ៊ឺរ៉ុប)ហៅថាៈ.....។

៤. ជាទម្រង់សិល្បៈម្យ៉ាងដែលមានតួអង្គសុទ្ធតែប្រុសសម្រាប់សម្តែងជាៈ.....។

៥. ជាពាក្យដែលបង្កើតចេញពីពាក្យឫសដោយប្រើផ្នត់ហៅថា.....។

III. ចូរបួនផ្គូផ្គងផ្នែកខាងក្រោមឱ្យបានត្រឹមត្រូវ។

ផ្នែក "ក"	ផ្នែក "ខ"	ចម្លើយ
ក.សំណំ	១.(ន.)អ្នកចេះមើលជំងឺ អ្នកចេះថ្នាំរំងាប់រោគ គ្រូមើលជំងឺពេទ្យ។	ក-
ខ.គ្រូហ្ម	២.(ន.)ការសាកសួរបញ្ជាក់សាក្សី ដំណើរស៊ើបសួរសង្កេតដឹងការពិត។	ខ-
គ.បរិពារ	៣.(ន.)ដំណើរដាសាក្សី។	គ-
ឃ.អង្កេត	៤.(គុ.)ដែលធំហំ ដែលហំសមរម្យ។	ឃ-
ង.សក្ខីភាព	៥.(ន.)អ្នកចោមរោមកំដរ អ្នកហែហមកិត្តិយស អ្នកបម្រើ។	ង-



មេរៀនទី៦ ស្មារតីទទួលខុសត្រូវ

៦.៤.អំណាន ៖ ល្ខោនខ្មែរ

I. ចូរប្អូនពន្យល់ពាក្យខាងក្រោមខាងក្រោមឱ្យបានត្រឹមត្រូវ

-មហោស្រពះ

-នាដ្យកថា៖

-និយោជក៖

II. ចូរប្អូនជ្រើសរើសចម្លើយមួយត្រឹមត្រូវ។

១.តើល្ខោនអាប៉ែមានដើមកំណើតមកពីណា?

ក.កំពង់ចាម ខ.តាកែវភាគខាងត្បូង

គ.កំពត យ.ចម្លើយ ក ខ គ

២.តើគេសម្តែងល្ខោនអាប៉ែនៅពេលណា?

ក.ពេលជួបគ្រោះរាំងស្ងួត ខ.ពិធីបុណ្យប្រជាពលរដ្ឋ

គ.ភ្ជុំបិណ្ឌ យ.គ្មានចម្លើយត្រឹមត្រូវ

៣.តើល្ខោនមហោរីមានដើមកំណើតមកពីណា?

ក.ព្រះបរមរាជវាំង ខ.ស្រុកល្វរ

គ.បាសាក់ យ.ស្រុកព្រៃជ្រៅ

៤.តើល្ខោនប្របោទ្យមានវត្តមាននៅទឹកដីកម្ពុជាតាំងពីពេលណា?

ក.សម័យអង្គរ ខ.សម័យចតុមុខ

គ.សម័យក្រោយអាណានិគម យ.សម័យមុនអង្គរ

៥.តើពីដើមគេហៅឈ្មោះល្ខោនបាសាក់យ៉ាងដូចម្តេច?

ក.ល្ខោនទ្រីងឃ្លោក ខ.ល្ខោនបន់សាក់

គ.ល្ខោនទ្រើងឃ្លោក យ.ល្ខោនបាសា

៦.តើល្ខោនបាសាក់មានដើមកំណើតមកពីណា?

ក.ប្រទេសឡាវ ខ.ខេត្តបាសាក់

គ.តាកែវ យ.គ្មានប្រភព

៧.តើល្ខោនបាសាក់ចូលមកភ្នំពេញលើកដំបូងសម្តែងនៅទីណា?

ក.ទូកប៉ុកចាយ ខ.ទូកបាសាក់

គ.មុខវត្តបុទុមសាគរ យ.ព្រះបរមរាជវាំង

៨.ល្ខោនដែលសម្តែងរឿងព្រះវេសន្តរ រាមកេរ្តិ៍

ក.ល្ខោនបាសាក់ ខ.ល្ខោនទ្រមោក

គ.ល្ខោនខោល ឃ.ល្ខោនស្បែក

៩.ទម្រង់សិល្បៈល្ខោនម្យ៉ាងដែលមានដើមកំណើតមកពីបរទេស

ក.ល្ខោនបរទេស ខ.ល្ខោនសម្តែង

គ.ល្ខោនស្បែកតូច ឃ.ល្ខោននិយាយ

១០.ល្ខោនដែលសម្តែងដោយបរិយាកាសរីករាយមិនសម្តែងអំពីភាពកម្សត់ ព្រាត់ប្រាស

ក.ល្ខោនប្រាមោទ័យ ខ.ល្ខោនបាសាក់

គ.ល្ខោនតុក្កតា ឃ.ល្ខោននិយាយ

១១. រឿងទាំងឡាយណាដែលបង្ហាញឈុតនិងឆាក ជារឿងបែប.....<u>លើកលែងតែ៖</u>

ក. ល្ខោនបាសាក់ ខ. យីកេ

គ. ល្ខោននិយាយ ឃ. ព្រេងនិទាន

១២. ការសរសេរបញ្ជីឈ្មោះតួអង្គនៅម្ខាង ការសន្ទនារបស់តួអង្គនៅម្ខាង ជាអត្ថបទបែប....៖

ក. អត្ថបទពណ៌នា ខ. អត្ថបទល្ខោន

គ. អត្ថបទប្រលោមលោក ឃ. អត្ថបទរឿងព្រេង

III. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១.នៅប្រទេសកម្ពុជាមានទម្រង់ល្ខោនជាង.....។ក្នុងនោះមានដូចជាល្ខោន .....ដែលមានដើមកំណើតចេញពីព្រះបរមរាជវាំងតែម្តង។

២.ល្ខោនខោលជាសិល្បៈម្យាងដែលអ្នករាំសុទ្ធតែជា.....។

៣.ល្ខោនខោលច្រើនសម្តែងនៅតាម.....និងនៅក្នុង.....។

IV. ចូរប្អូនផ្គូផ្គងផ្នែកខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក “ក”	ផ្នែក “ខ”	ចម្លើយ
ក.ល្ខោនខោលចូលបេតិកភណ្ឌ	១.មានដើមកំណើតពីស្រុកជ្វា	ក-
ខ.ល្ខោនស្រមោលស្បែកធំចូលបេតិកភណ្ឌ	២.២៨ខែវិច្ឆិកាឆ្នាំ២០១៨	ខ-
គ.ល្ខោនខោល	៣.សម្តែងរឿងថៅកែចិត្តចោ គ្រូបង្រៀនស្រុកស្រែ.....	គ-
ឃ.ល្ខោននិយាយ	៤.ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥	ឃ-
ង.ល្ខោនយីកេ	៥.សម្តែងដោយមនុស្សប្រុសទាំងអស់	ង-

V. សំណួរត្រិះរិះ

១.តើល្ខោនស្រមោលមាននៅប្រទេសណាខ្លះ?មានប៉ុន្មានប្រភេទ?

- ចម្លើយ៖.....

.....

.....

.....

.....

.....

.....

.....

.....

.....។

២.ចូររៀបរាប់ពីលក្ខណៈពិសេសរបស់ល្ខោនខោល។

- ចម្លើយ៖.....

.....

.....

.....

.....

.....

.....

.....

.....

.....

.....។

៣.តើល្ខោនយីកេមានដើមកំណើតមកពីណា?សម្តែងនៅពេលណា?

- ចម្លើយ៖.....

.....

.....

.....

.....

.....

.....

.....

.....

.....។

៤.តើគេប្រើប្រាស់ឧបករណ៍អ្វីខ្លះក្នុងការសម្តែងល្ខោនអាប៉ែ?

- ចម្លើយៈ.....

.....

.....

.....

.....

.....

.....

.....

.....

.....។



មេរៀនទី៦ ស្គាតើឧទ្ទេសខុសត្រូវ

៦.៥.វេយ្យាករណ៍ ៖ ពាក្យបន្ថែមដើម និងពាក្យបន្ថែមចុង

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. តើពាក្យបន្ថែមដើម"ការ សេចក្តី ភាព" ផ្សំជាមួយពាក្យឫសសម្គាល់នាមអ្វី?

ក. នាមរូបី ខ. នាមជីវចល

គ. នាមករណ៍ ឃ. នាមការក៍

២. តើពាក្យបន្ថែមដើម"អ្នក ជន" ផ្សំជាមួយពាក្យឫសសម្គាល់នាមអ្វី?

ក. នាមជីវចល ខ. នាមការក៍

គ. នាមអជីវចល ឃ. នាមករណ៍

៣. តើពាក្យបន្ថែមចុង"ករ ការី វិទូ បុរស" ផ្សំជាមួយពាក្យឫសសម្គាល់នាមអ្វី?

ក. នាមការក៍ ខ. នាមអរូបី

គ. នាមករណ៍ ឃ. នាមអជីវចល

៤. តើពាក្យបន្ថែមចុង"កម្ម កិច្ច ភាព ធម៌" ផ្សំជាមួយពាក្យឫសសម្គាល់នាមអ្វី?

ក. នាមជីវចល ខ. នាមការក៍

គ. នាមអជីវចល ឃ. នាមករណ៍

៥. តើពាក្យខាងក្រោមមួយណាមិនមែនជាពាក្យបន្ថែមដើម?

ក. ប្រជាជន ខ. ភាពសោកសៅ

គ. អ្នកជំនួញ ឃ. ជនអកតញ្ញូ

៦. តើពាក្យបន្ថែមដើមខាងក្រោមមួយណាសម្គាល់នាមការក៍?

ក. ល្មួន ខ.ថ្មើរជ្រៃ

គ. ស្នួម ឃ. អ្នកលក់ដូរ

៧. តើក្រុមពាក្យខាងក្រោមណាខ្លះបង្ហាញពាក្យបន្ថែមចុង?

ក. ទស្សនៈវិទូ ព្រាហ្មណ៍និយម ខ. សេរីភាព សុខសាន្ត

គ. ភាពក្លាហាន ភាពស្មោះត្រង់ ឃ. សង្គមរាស្ត្រនិយម ជនប្រមឹក

II. ចូរជ្រើសរើសពាក្យបន្ថែមដើម និងបន្ថែមចុងបំពេញក្នុងកថាខណ្ឌខាងក្រោមឱ្យបានត្រឹមត្រូវ

អក្ខរកម្ម	សាមគ្គីភាព	សមត្ថភាព	សិល្បករ	ភាពប្តុំប្តើន	អនក្ខរជន

នៅគ្រប់កាល:ទេស:ពលរដ្ឋត្រូវរួម.....ធ្វើការតនស្នងមាតុភូមិដែលយើងរស់នៅ។ ការងារដែលធ្វើ គឺតម្រូវតាមមុខជំនាញនីមួយៗ។ សិស្ស និស្សិត បញ្ញាវ័ន្ត កវីនិពន្ធ បណ្ឌិត.....ត្រូវប្រើ .....ដែលខ្លួនមានផ្សព្វផ្សាយដល់ជនរួមឈាមនូវ.....នៃទឹកដី តាំងពីយុគសម័យបរមបុរាណបង្ហាញពីធម្មជាតិ ដីធ្លី ពីប្រពៃណីស្អាតផូរផង់របស់ខ្មែរយើង ដើម្បីឱ្យអ្នកទាំងនោះមានទឹកចិត្តស្រឡាញ់ទឹកដីខ្លួន។ ទន្ទឹមនឹងនេះត្រូវរួសរាន់ផ្ទេរចំណេះដឹងឱ្យទៅ.....តាមរយៈចលនា .....និងបំពេញវិជ្ជា។

III. ចូរប្អូនស្រង់ពាក្យបន្ថែម និងបន្ថែមចុងក្នុងប្រអប់យកទៅដាក់តាមប្រភេទក្នុងប្រអប់

អ្នកស្នុត សេចក្តីរុងរឿង សង្គ្រាម ភាពស្រស់ស្រាយ ការស្តាប់ ការការពារ ព្រៃព្រឹក្សា ជនរួមជាតិ សីលធម៌ កម្មការិនី ពលកម្ម អក្សរសាស្ត្រ ប្រមាញ់ ទឹកឡើង កិច្ចការ នារីក្លាហាន អ្នកវិទូ ភាពលំបាក អ្នកសិក្សា។

ពាក្យបន្ថែមដើម	ពាក្យបន្ថែមចុង



មេរៀនទី៧ ការជឿជាក់

៧.១.វេយ្យាករណ៍ ៖ អំពីពាក្យក្លាយ

I. ចូរជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. តើក្រុមពាក្យណាជាក្រុមពាក្យក្លាយ?

ក. ល្មួន ដី ដឹក ខ. សន្សើម ជម្រើស គម្រប

គ. ជើរ ធ្មាំ ផ្តេក ឃ. ច្បង ខ្ចើយ កើត

២. តើពាក្យក្លាយខាងក្រោមមួយណាជាពាក្យក្លាយផ្នត់ដែក?

ក. ខ្មាន់ ល្បក ខ.កញ្ជាស់ សំបក

គ. សង្កិន គំនិត ឃ. ចំណែក បង្គាប់

៣. ចូរប្រាប់ពីទម្រង់និងផ្នត់របស់ពាក្យក្លាយ "ក្បាច់"៖

ក. [-ក-] (-ពស-) ខ. [ក-] (ព-)

គ. [-ប-] (-ព-) ឃ. [ប-] (សព-)

៤. ចូរឬនស្រង់ពាក្យក្លាយដែលស្ថិតនៅក្នុងផ្នត់ដើម៖

ក. ខ្មោស កំណក ខ. បំបាក់ ជំនាញ

គ. ខ្ចើយ ថ្មើរ ឃ. ផ្តើម ផ្តួល

II. ចូរឬនផ្គូផ្គងចំណុចខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក "ក"	ផ្នែក "ខ"	ផ្នែកចម្លើយ
1. បាំង	a) បបោស	1. →
2. បូត	b) បង្កើត	2. →
3. កាយ	c) កង្វៀច	3. →
4. បោស	d) តតះ	4. →
5. តះ	e) បង្ហួត	5. →
6. កើត	f) បង្គាប់	6. →
7. កាប់	g) ចចឹក	7. →
8. ចាក់	h) ស្រទន់	8. →
9. ទន់	i) ស្តុក	9. →
10. អួត	j) ច្បូត	10. →
11. វៀច	k) សង្កិន	11. →
12. ចឹក	l) កកាយ	12. →
13. កិន	m) ប្រចាក់	13. →

14. កក	ក) ក្បាំង	14. →

III. ចូរប្អូនជ្រើសរើសពាក្យត្លាយក្នុងអត្ថបទខាងក្រោម ដោយប្រាប់ពីពាក្យឫស ផ្នត់ និងទម្រង់

[...] ព្រះសង្ឃព្រះអង្គត្រូវបានទេសនាអប់រំប្រមុំចិត្តពុទ្ធសាសនិក ឱ្យវៀរចាកអំពីអកុសលឱ្យជាមនុស្ស មានចិត្តជ្រះថ្លា មេត្តាសន្តោសប្រណី ស្គាល់គុណទោស ឱ្យបោះបង់គំនិតចងអាឃាតព្យាបាទតែជាតិ សាសន៍ឯងរួមជាមួយនេះដែរ។ ព្រះសង្ឃជាប្រទីបបំភ្លឺផ្លូវដល់ជន្មនានុជនឱ្យជ្រះថ្លារួមគ្នាកសាងស្ពានថ្ម សាលារៀនការពារវត្ថុបុរាណដើម្បីទុកជាកេរមតកដល់មនុស្សជំនាន់ក្រោយ ធ្វើបែបនេះបានទើបសមជាច្បាប់រដ្ឋធម្មនុញ្ញចែងថា "ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ"។

ចំណែកខាងអាជីវករ ពាណិជ្ជករ សិប្បករ អ្នកតោងធ្វើជំនួញដោយសុចរិតមិនត្រូវគិតតែពីចំណេញហួសប្រមាណ។ អ្នកមិនត្រូវផលិតទំនិញខ្វះអនាម័យ ខ្វះគុណភាព និងមិនត្រូវគេចវេះពីការបង់ពន្ធជូនរដ្ឋឡើយ [...]។



មេរៀនទី៧ ការជឿជាក់

៧.២.អំណាន ៖ អត្ថបទឃោសនា

I. ចូរបួនបំពេញចន្លោះក្នុងឈ្មោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. .....(កិ) លក់ ប្តូរសារពើទំនិញដោយយកផលចំណេញឬឱ្យរបស់ទៅវិញទៅមក។

២. .....(ន) គ្រឿងសម្រាប់អាស្រ័យបួនយ៉ាង ចីវ(គ្រឿងស្លៀកដណ្តប់) បិណ្ឌបាត(អាហារ) សេនាសនៈ(លំនៅ) គិលានភេសជ្ជៈ(ថ្នាំរំងាប់ជំងឺ រំងាប់រោគ...)។

៣. .....(កិ) ពោលពាក្យលើកសរសើរហួសហេតុហួសទំនង។

៤. .....(កិ) ល្បួងឱ្យស្រួលចិត្ត។

៥. .....(ន) ភ្ញៀវ អ្នកដទៃក្រៅពីគ្នាឯង ដែលគេមករក...។

II. ចូរបួនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. ការប្រកាស ការផ្សាយដំណឹងឱ្យសាធារណជនដឹងឮពីកម្មវត្ថុណាមួយជាអ្វី?

ក. ព័ត៌មាន ខ. ការឃោសនា

គ. ការផ្សាយ ឃ. ការបង្ហាញ

២. មធ្យោបាយដែលគេធ្វើការផ្សព្វផ្សាយពេញនិយមជាងគេគឺអ្វី?

ក. សំបុត្រ ទស្សនាវដ្តី ខ. ទូរទស្សន៍ វិទ្យុ

គ. អ៊ីនធើណេត អ៊ីម៉ែល ឃ. ចម្លើយទាំង៣

៣. គេតែងតែប្រើបច្ចេកទេសអ្វីសម្រាប់ធ្វើការឃោសនា?

ក. ប្រើពាក្យបំផុសអារម្មណ៍ឱ្យរំភើប ខ. ផ្សព្វផ្សាយតាមអ្នកអាន

គ. បង្ហាញពីភាពរីករាយនឹងការងារ ឃ. បញ្ជាក់ពីតម្លៃនៃផលិតផលនោះ

៤. តើចំណុចខាងក្រោមមួយណាមិនបានបង្ហាញពីកម្មវត្ថុនៃការឃោសនា?

ក. បង្ហាញពីកម្មវត្ថុមួយយ៉ាងច្បាស់នោពេលឃោសនា

ខ. បង្ហាញពីភាពចាំបាច់នៃវត្ថុនោះ

គ. ត្រូវប្រើបុគ្គលិកធ្វើជាទីផ្សារសម្រាប់ឃោសនា

ឃ. ប្រើពាក្យទាក់ទាញប្រកបដោយភាពរំភើប

៥. រាល់ព័ត៌មានដែលបានការឃោសនាបំណងរបស់កម្មវត្ថុនោះគឺអ្វី?

ក. រកផលចំណេញ ខ. ភាពជោគជ័យសម្រាប់មុខរបរ

គ. ភាពរីកចម្រើននៃផលិតផល ឃ. ចម្លើយទាំង៣

III. ចូរប្អូនសរសេរពាក្យ "**ត្រូវ**" ឬ "**ខុស**" ពីមុខល្បះដែលជាគំនិតសំខាន់ក្នុងអត្ថបទអំណាន

១.....រាល់សេចក្តីដែលឃោសនាដែលគេបានធ្វើសុទ្ធតែជាការពិត។

២.....ការឃោសនាមានច្រើនបែបច្រើនយ៉ាងអាស្រ័យលើទេពកោសល្យអ្នកឃោសនា។

៣. .....ពេលអ្នកឃើញការឃោសនាត្រូវវែកញែក ពិចារណាឱ្យបានសមហេតុផលមុននឹងជឿ។

៤.....ការឃោសនាពិតជាល្អប្រសើរសម្រាប់មនុស្សក្នុងសង្គម។

៥.....ការឃោសនាត្រូវការអ្នកដែលពូកែថ្វីមាត់ និងភាពប៉ិនប្រសប់ រួមទាំងភាពច្នៃប្រឌិត។

IV. ចូរប្អូនស្រង់សំនួនពាក្យដែលបង្ហាញពីការឃោសនានិងពាក្យបញ្ចើចបញ្ចើក្នុងអត្ថបទខាងក្រោម

<u>អត្ថបទ៖</u>

ប្រទេសកម្ពុជាមាតុភូមិយើង ជាប្រទេសដែលសម្បូរទៅដោយប្រាសាទល្អឆើតឆាយ ធ្វើឱ្យពិភពលោកកោតស្ងប់ស្ងែងក្រៃលែង។

ក្នុងសម័យមហានគរដ៏ឃ្លរលង់ មាតុភូមិយើងមានកេរ្តិ៍ឈ្មោះល្បីល្បាញខ្ចរខ្ចារនៅអាស៊ីអាគ្នេយ៍និងលើសកលលោក។ បុព្វបុរសដូនតាយើងបានបន្សល់ទុកស្នាដៃកេរដំណែលវប្បធម៌ អរិយធម៌ សម្បូរបែបកស្តុតាងនៃអ្នកវិទ្យាសាស្ត្រនៅសម័យរុងរឿងនោះ។ ប្រាសាទនានានៅថែរក្សាក្បូរក្បាច់រចនាវិចិត្រកម្មល្អិតផ្ទូរផង់គន់មើលមិនទាស់ភ្នែកឡើយ ហើយតែតែប្រណិតឡើងៗ ពីរចនាបថមួយទៅរចនាបថមួយទៀត [...]។



មេរៀនទី៧ ការជឿជាក់

៧.៣.អំណាន ៖ ជីវិតជាការតស៊ូ

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. ចូរប្អូនបង្ហាញពីគំនិតសំខាន់របស់អត្ថបទ "អំណាន ជីវិតជាការតស៊ូ"៖

ក. ត្រូវចេះតស៊ូជម្នះរាល់ឧបសគ្គ។ ខ. ត្រូវរស់នៅដោយភាពជឿជាក់។

គ. ត្រូវចេះប្រើជីវិតឱ្យមានន័យ។ ឃ. ត្រូវបណ្តុះស្មារតីក្លាហាន។

២. ចូរបង្ហាញពីចំណុចមួយដែលមិនមែនជាគុណសម្បត្តិរបស់ស្ត្រីមេម៉ាយ៖

ក. ប្រឹងប្រែងចិញ្ចឹមកូនៗ ខ. មិនឱ្យឈប់កូនសិក្សា

គ. ទុកកូនៗឱ្យនៅម្នាក់ឯង ឃ. មានភាពអំណត់ក្នុងការងារ

៣. ក្នុងអំណាន "ជីវិតជាការតស៊ូ"បងស្រីមេម៉ាយបានពោលពាក្យក្នុងចិត្តយ៉ាងដូចម្តេច?

ក. ទោះលំបាកយ៉ាងណាក៏ខ្ញុំមិនសុំគេដែរ។ ខ. ខ្ញុំសុខចិត្តប្រើកម្លាំងដ៏ស្តួចស្តើងនេះ។

គ. ខ្ញុំកាប់គាស់ដំណាំយកផលចិញ្ចឹមកូន។ ឃ. ចម្លើយទាំង៣

៤. នៅពេលដែលស្ត្រីមេម៉ាយពិបាកខ្លាំងបានលះបង់អ្វី?

ក. ព្រមលះបង់កូន២នាក់ឱ្យទៅជាមួយបងប្អូននៅទីក្រុង

ខ. ព្រមធ្វើការងារគ្រប់យ៉ាងដើម្បីកូនគ្រប់រូប

គ. បានស្វែងរកជំនួយពីអ្នកជុំវិញខ្លួន

ឃ. បានចាកចេញស្រុកកំណើតទៅរកកន្លែងថ្មី

៥. តើសកម្មភាពរបស់បងស្រីមេម៉ាយបានផ្តល់អ្វីដល់អ្នកសិក្សា?

ក. បានផ្តល់ជាកម្មភាពខ្លះមិនឱ្យគិតវែងឆ្ងាយ

ខ. ផ្តល់ជាបទពិសោធសម្រាប់ការរស់នៅ

គ. ផ្តល់ជាគំរូដ៏ល្អមួយនិងជាបទពិសោធសម្រាប់រៀនសូត្រ

ឃ. ផ្តល់ជាទឹកចិត្ត និងមេត្តាធម៌ដល់មនុស្សគ្រប់គ្នា

៦. តើកស្តុតាងដែលបង្ហាញពីភាពតស៊ូរបស់បងស្រីមេម៉ាយ?

ក. គាត់ព្យាយាមធ្វើការ និងដាំដំណាំជុំវិញផ្ទះ

ខ. គាត់បានធ្វើការងារដែលនៅឆ្ងាយពីផ្ទះ

គ. ទោះជាជួបការលំបាកបែបណាក៏មានមិនសុំទានគេដែរ

ឃ. ចម្លើយទាំង៣

II. ចូរបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ

១. ឃ្លា "ជីវិតជាការតស៊ូ"នេះជាម្ដេ.....។

២. ស្ត្រីមេម៉ាយបាននិយាយថា "ទោះបើជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនដើរសុំទានគេដែរ ខ្ញុំសុខចិត្តប្រើកម្លាំងដ៏ស្គមស្គាំងរបស់ខ្ញុំ.....″។

៣. ម្នាក់ៗត្រូវតែប្រើលទ្ធភាពដែលខ្លួនមាន ដើម្បីអនាគតរបស់ខ្លួន និងគ្រួសារមានរុងរឿង.....។

៤. ពេលខ្លះបងស្រីបានធ្វើការនៅកន្លែងឆ្ងាយព្រោះតែចង់បាន.....ដើម្បីធ្វើការផ្គត់ផ្គង់គ្រួសាររបស់គាត់តែប៉ុណ្ណោះ។

៥. បងស្រីត្រូវចេញទៅធ្វើការចម្ងាយ.....ព្រមទាំងរែកដីពីមួយថ្ងៃទៅមួយថ្ងៃ បានពី .....។



មេរៀនទី៧ ការជឿជាក់

៧.៤.អំណាន ៖ តម្លៃនៃការជឿទុកចិត្ត

I. ចូរបំពេញចន្លោះនូវពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ

- (ន.) ផលនៃការងារដែលបានសម្រេច ផលដែលបានសម្រេចហើយ ជានិយមរបស់ពាក្យ.....។
- (ន.) ភាពដែលសម្រេចរួចរាល់ហើយយ៉ាងល្អប្រសើរ ជានិយមរបស់ពាក្យ.....។
- (ន.) ការរិះគិតល្អ គំនិតត្រឹមត្រូវ ជានិយមរបស់ពាក្យ.....។
- (ន.) អ្នកដឹកនាំ អ្នកបង្គាប់ឬប្រើឱ្យគេធ្វើការផ្សេងៗ ជានិយមរបស់ពាក្យ.....។
- (ន.) អ្នកដែលគេប្រើឱ្យធ្វើការ កូនឈ្នួល កម្មករ ជានិយមរបស់ពាក្យ.....។

II. ចូរជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. ការដែលមានទំនុកចិត្ត ឬជឿលើនរណាម្នាក់ ជានិយមរបស់កន្សោមពាក្យមួយណា?

ក. ការទទួលខុសត្រូវ ខ. ការជឿទុកចិត្ត

គ. ការស្រឡាញ់ ឃ. គ្មានចម្លើយ

២. តើក្នុងអត្ថបទ "អំណាន តម្លៃនៃការជឿទុកចិត្ត" បានបង្ហាញក្រុមហ៊ុនឈ្មោះអ្វី?

ក. ក្រុមហ៊ុនគ្រឿងអគ្គិសនី MATSUSHITO

ខ. ក្រុមហ៊ុនគ្រឿងអគ្គិសនី MATSUSHOTO

គ. ក្រុមហ៊ុនគ្រឿងអគ្គិសនី MATSUSHITA

ឃ. ក្រុមហ៊ុនគ្រឿងអគ្គិសនី MATSUSOTA

៣. តើក្នុងអត្ថបទ "អំណាន តម្លៃនៃការជឿទុកចិត្ត" បានបង្ហាញពីអ្វី?

ក. ការទទួលខុសត្រូវរបស់ក្រុមហ៊ុន MATSUSHITA

ខ. ការជឿទុកចិត្តរបស់និយោជិត

គ. ការជឿទុកចិត្តរបស់ប្រធានក្រុមហ៊ុន MATSUSHITA ចំពោះនិយោជិត

ឃ. ការមិនជឿទុកចិត្តចំពោះក្រុមហ៊ុន MATSUSHITA

៤. តើក្នុងអត្ថបទ "អំណាន តម្លៃនៃការជឿទុកចិត្ត" បានបង្ហាញពីខ្លឹមសារអ្វីខ្លះ?

ក. បង្ហាញពីការជឿទុកចិត្តទៅលើនិយោជិត

ខ. បង្ហាញពីទំនុកចិត្តរបស់ម្ចាស់ក្រុមហ៊ុនទៅលើបុគ្គលិក

គ. បង្ហាញពីភាពស្មោះត្រង់

ឃ. ចម្លើយទាំងអស់ខាងលើ

៥. តើការសម្ងាត់ក្នុងអត្ថបទ "អំណាន តម្លៃនៃការជឿទុកចិត្ត" ជាអ្វី?

ក. លេខកូដសម្ងាត់ ខ. រូបមន្តនៃការផលិតមីកញ្ចប់

គ. រូបមន្តនៃការផលិតគ្រឿងអគ្គិសនី ឃ. រូបមន្តនៃការផលិតប្លាស្ទិច

III. ចូរប្អូនសរសេរពាក្យ "**ត្រូវ**" ឬ "**ខុស**" ពីខាងល្អះដែលទាក់ទងនឹងអត្ថបទអំណាន

១. .....អ្នកធ្វើការងារក្នុងក្រុមហ៊ុនកត្តាដែលសំខាន់បំផុត គឺការដែលមនុស្សទាំងអស់នោះមានការទុកចិត្តគ្នា។

២. .....ទំនិញជាផលិតផលមួយ ដែលមនុស្សក្រុមហ៊ុនត្រូវយកចិត្តទុកដាក់បំផុតសម្រាប់ផ្តល់ជូនអតិថិជនប្រើប្រាស់។

៣. .....ក្រៅពីម្ចាស់រោងចក្រមានតែមនុស្សក្នុងក្រុមគ្រួសារដូចជា បងប្អូនបង្កើត ឬសាច់ញាតិតែប៉ុណ្ណោះដែលអាចដឹងពីរបៀបរក្សាទុកនូវរូបមន្តផលិតផលបាន។

៤. .....ការចាប់ផ្តើមបង្រៀនរូបមន្តនោះដល់បុគ្គលិកខ្លួនឯង បញ្ជាក់ថាយើងមានការទុកចិត្តចំពោះគ្នាដូចជាក្រុមគ្រួសារតែមួយ ព្រមទាំងអាចដឹងពីចរិតលក្ខណៈរបស់មនុស្សបានផងដែរ។

៥. .....ការជឿទុកចិត្តនេះធ្វើឱ្យបុគ្គលិកដែលមិនចាប់អារម្មណ៍លើខ្លួនឯង ក្លាយជាមានលក្ខណៈមួយគួរឱ្យកោតសរសើរចំពោះមនុស្សយើងម្នាក់ៗ។



មេរៀនទី៨ សេចក្តីព្យាយាម

៨.១.វេយ្យាករណ៍ ៖ ពាក្យផ្សំ

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. ចូរជ្រើសរើសពាក្យផ្សំដែលចេញពីគុណនាម+នាម៖
ក. បូតសណ្តែក ទាញព្រ័ត្រ ខ. សិល្បករ ស្ថានភាព
គ. ឈើត្រង់ ខ្មៅដៃ ឃ. ធ្ងន់ត្រចៀក សប្បាយចិត្ត

២. តើពាក្យមួយណាដែលមិនមែនជាពាក្យផ្សំ?
ក. ទូរសព្ទ ខ. ត្បាល់កិន
គ. បាក់សាច់ ឃ. មិត្តភាព

៣. ការរួមផ្សំចូលគ្នារវាងស្រៈនិងព្យញ្ជនៈសម្រាប់សម្គាល់បញ្ញត្តិមួយច្បាស់ជាក់លាក់គេហៅថាអ្វី?
ក. ព្យាង្គ ខ. ពាក្យ
គ. សូរអាន ឃ. ព្យាង្គនិងពាក្យ

៤. កំណើតពាក្យអាចកើតឡើងដោយសារអ្វីខ្លះ?
ក. អាចកើតពីការកម្លាយពាក្យ ខ. ការបន្សំពាក្យចូលគ្នា
គ. អាចបន្ថែមពាកយនៅខាងដើមនិងចុង ឃ. ចម្លើយទាំង៣

៥. ពាក្យ "ដំឡូងឈាមមាន់ ស្បែកជើងកង់ឡាន" ជាពាក្យផ្សំតាមបែបអ្វី?
ក. ការធ្វើពាក្យក្លាយ ខ. ពាក្យបន្ថែមដើម
គ. ផ្សំពាក្យក្នុងថ្នាក់ពាក្យ ឃ. ពាក្យបន្ថែមចុង

៦. តើពាក្យខាងក្រោម ពាក្យណាដែលជាពាក្យផ្សំបន្ថែមដើម?
ក. សៀវភៅសរសេរ ខ. ព្រឹទ្ធបុរស
គ. ភាពជឿនលឿន ឃ. ថ្មើរ

៧. ពាក្យ "ផ្ទះបាយ ដៃកឆាប"ចូរបង្ហាញពីទម្រង់នៃពាក្យផ្សំនេះ។
ក. នាម+នាម,នាម+កិ ខ. កិ+នាម,គុ+កិ
គ. កិ+នាម,កិ+កិ ឃ. គុ+នាម,នាម+កិ

៨. ចូរប្អូនប្រាប់ពាក្យក្លាយនៅខាងក្រោម។
ក. ជំនួញ ខ. កំហូច
គ. សេចក្តីចម្រើន ឃ. ទូទឹកកក

II. ចូរប្អូនជ្រើសរើសពាក្យផ្សំក្នុងប្រអប់ខាងក្រោម រួចបែងចែកទៅតាមប្រភេទនៃពាក្យផ្សំនោះ

សេចក្តីព្យាយាម សន្សើម សីលធម៌ បាក់ដំរបាយ ជនបរទេស ករណីយកិច្ច ទឹកខ្មៅ ដេក ស្រួច ផលិតកម្ម ធ្មាំ លួន ការបង្កើត ការសិក្សាអប់រំ ភាសាវិទូ ភ្លៅកង្កែប មេអណ្តើក។

ពាក្យភ្ជាយ	ពាក្យបន្ថែមដើម	ពាក្យបន្ថែមចុង	ផ្សំថ្នាក់ពាក្យ

III. ចូរប្អូនស្រង់ពាក្យក្នុងអត្ថបទខាងក្រោម

វិជ្ជានិងសីលធម៌ជាចរន្តពីរ ជាគុណសម្បត្តិពីរ ដែលមនុស្សភាគច្រើនប្រាថ្នាចង់បាន។ ក្នុងជីវភាពរស់នៅរបស់មនុស្សក្នុងសង្គម តើចរន្តទាំងពីរត្រូវការមានទាក់ទងគ្នារបៀបណា? កន្លងមកយើងបានឃើញថា អ្នកប្រាជ្ញដែលមានចំណេះវិជ្ជាជ្រៅជ្រះជាច្រើន បានខិតខំត្រិះរិះពិចារណា ស្រាវជ្រាវ ពិសោធបង្កើតបានឧបករណ៍ប្រើប្រាស់ផ្សេងៗ ដើម្បីបម្រើសេចក្តីត្រូវការរបស់មនុស្សក្នុងសង្គម។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកប្រាជ្ញដែលមានឧត្តគតិខ្ពង់ខ្ពស់ទាំងនោះ។ ប៉ុន្តែយើងក៏មានសេចក្តីសោកស្តាយចំពោះអ្នកប្រាជ្ញខ្លះដែលបណ្តោយឱ្យវិទ្យាសាស្ត្រ ទៅបម្រើមហិច្ឆតារបស់ចក្រពត្តិល្មោភសង្គ្រាមទៅវិញ [...] ។



មេរៀនទី៨ សេចក្តីព្យាយាម

៨.២.អំណាន ៖ ឧត្តមគតិបុគ្គលសំខាន់ៗ

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. មានទស្សនៈមួយបានលើកឡើងថា "កុំនៅស្ងៀមដោយមិនបានធ្វើអ្វី"ជាទស្សនៈរបស់អ្នកណា?
ក. ប៉ូឡេអុង ខ. រ៉ូប៊ឺតស័ន
គ. ស៊ីវ៉ាល់ទ័រស្កត់ ឃ. ម៉ាទិនឡូធើរ

២. តើសិលាចារឹកនៃប្រាសាទវ៉ៃកាញ់របស់ព្រះមហាក្សត្រខ្មែររាជវង្សស្រីមារៈបានបង្ហាញខ្លឹមសារសំខាន់ពីអ្វី?
ក. ការថែរក្សាទឹកដីមាតុភូមិ។ ខ. ការការពារប្រជាជនឱ្យមានសន្តិភាព។
គ. ការរួមសាមគ្គីជាធ្លុងមួយ។ ឃ. ការសរសេរប្រណីដោយព្រហ្មវិហារធម៌។

៣. អត្ថបទដែលនិយាយពីស្នាព្រះហស្ត ព្រះរាជនិពន្ធ វចនានុក្រម កថ្វាយនូបត្ថម្ភកៈជារបស់អ្នកណា?
ក. សម្តេចព្រះសង្ឃរាជ ជួន ណាត ខ. ព្រះនាងឥន្ទ្រទេវី
គ. អតីតព្រះមហាក្សត្រខ្មែរ ឃ. ព្រះភិក្ខុប៉ាងខាត

៤. សៀវភៅស្រីហិតោបទេសជាច្បាប់មួយដែលអត្ថន័យបង្ហាញពីអ្វី?
ក. បង្ហាញពីការលោភលន់របស់មនុស្សក្នុងសង្គម
ខ. បង្ហាញពីការដោះស្រាយបញ្ហាដោយសន្តិវិធី
គ. បង្ហាញពីជីវប្រវត្តិរបស់អង្គក្សត្រនីមួយៗតាមសម័យកាល
ឃ. បង្ហាញពីការលះបង់របស់បុព្វបុរសខ្មែរ

៥. តើព្រះនាងឥន្ទ្រទេវីបានជំរុញខាងវិស័យអ្វីខ្លះក្នុងសង្គម?
ក. វិស័យសិល្បៈ ខ. វិស័យអក្សរសាស្ត្រ
គ. ខាងវប្បធម៌ជាតិនានា ឃ. ចម្លើយទាំង៣

II. ចូរប្អូនផ្គូផ្គងចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក "ក"	ផ្នែក "ខ"	ចម្លើយ
១. ឧត្តមគតិ	ក. អំណាច សេចក្តីក្លាហាន សេចក្តីអង់អាច។	១
២. ពង្សាវតារ	ខ. សេចក្តីដឹងខ្លួន ការមិនភ្លេចខ្លួន ការប្រុងប្រយ័ត្ន។	២
៣. ពលានុភាព	គ. គតិឬប្រាជ្ញាញាណដ៏ខ្ពង់ខ្ពស់ ល្អប្រពៃ។	៣
៤. បុគ្គលិកលក្ខណៈ	ឃ. ដែលរុងរឿងថ្លៃថ្លា ភ្លឺចញ្ចែងចញ្ចាច។	៤
៥. សម្បជ្ជញ្ញៈ	ង. លក្ខណៈរបស់បុគ្គលម្នាក់ៗ...។	៥
៦. រុងរោចន៍	ច. រឿងរ៉ាវតាមលំដាប់វង្សត្រកូល...។	៦

III. ចូរប្អូនស្រង់ពាក្យក្នុងប្រអប់ រួចយកទៅបំពេញក្នុងលកថាខណ្ឌខាងក្រោម

ស្ថាបនា រាជធានីអង្គរធំ គុណធម៌ ព្រះរាជបុត្រ ប្រាសាទបាយ័ន ព្រះមហាក្សត្រ ប្រជានុរាស្ត្រ ព្រះបាទជ័យវរ្ម័នទី៧ ប្រាសាទតាព្រហ្ម ទីសក្ការៈ។

ក្នុងឋានៈជាអគ្គមហេសីនៃ.....ដ៏មានអំណាចខ្លាំងពូកែមួយអង្គព្រះនាងទ្រង់ព្យាយាមបញ្ចុះបញ្ចូលព្រះស្វាមីឱ្យមាន..... យ៉ាងជ្រាលជ្រៅចំពោះ..... និងងាកមកកាន់ព្រះពុទ្ធសាសនាយ៉ាងមុតមាំ។ នៅពេលដួសដុល.....ជំនួសរាជធានីចាស់យសោធបុរៈ.....ទ្រង់ចាត់ឱ្យកសាង.....ដើម្បីតម្កល់ព្រះពុទ្ធរូបមួយអង្គ ដែលមានកម្ពស់៩ម៉ែតទុកជា.....បូជាចំពោះព្រះពុទ្ធសាសនា។ ទន្ទឹមនឹងនេះដែរព្រះអង្គត្រង់ចាត់ឱ្យ.....ប្រាសាទព្រះខ័នសម្រាប់រំឭកវិញ្ញាណក្ខន្ធព្រះវរបិតា.....ជាទីតម្កល់ព្រះបរមរូបនៃព្រះមាតា និងសម្តេចព្រះគ្រូប្រាសាទបន្ទាយឆ្មារជាតង្វាយរបស់.....មួយអង្គព្រះនាមស្រីន្ទ្រកុមារ ដែលមានគុណចំពោះព្រះបាទយសោវរ្ម័នទី២ក្នុងចម្បាំងនឹងជនក្បត់រាហ៊ូ និងប្រាសាទដទៃទៀតជាច្រើន។



មេរៀនទី៨ សេចក្តីព្យាយាម

៨.៣.អំណាន ៖ អាលីយូហ្សា

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. ចំណុចមួយណាដែលមិនទាក់ទងការបំពានសិទ្ធកុមារក្នុងអំណាន "អាលីយូស្សា"?
ក. ប្រើកុមារហួសកម្លាំង ខ. ធ្វើទារុណកម្មលើកុមារ
គ. មិនឱ្យកុមារបានសិក្សា ឃ. ការស្តីបន្ទោស

២. ចូរជ្រើសរើសលក្ខណៈសម្បត្តិរបស់ម្ចាស់ផ្ទះអាលីយូស្សា៖
ក. ការចេះទទួលស្គាល់កំហុស ខ. ជួយផ្តល់ការសិក្សាដល់ក្មេង
គ. ជាមនុស្សដែលមានគុណធម៌ ឃ. ចម្លើយទាំង៣

៣. តើអាលីយូហ្សាបានសៀវភៅមកពីណាសម្រាប់អាន?
ក. ទិញពីផ្សារ ខ. សៀវភៅរបស់អ៊ីម្ចាស់ផ្ទះ
គ. ម្តាយក្មេងស្រីម្នាក់ ឃ. ខ្ចីពីបណ្ណាល័យ

៤. នៅពេលអាលីយូហ្សាអានសៀវភៅភ្លេចខ្លួនតើមានរឿងអ្វីបានកើតឡើង?
ក. អ៊ីម្ចាស់ផ្ទះបានវាយអាលីយូហ្សា ខ. កំសៀវទឹកបានផ្ទុះ
គ. ម្ចាស់សៀវភៅមកយកវិញ ឃ. ចម្លើយទាំង៣

៥. តើអាលីយូហ្សាយកពន្លឺអ្វីសម្រាប់អានសៀវភៅ?
ក. ភ្លើងទៀន ខ. ភ្លើងអំពូល
គ. ភ្លើងពិល ឃ. ពន្លឺព្រះចន្ទ

៦. តើនៅពេលទំនេរអាលីយូហ្សាចូលចិត្តធ្វើអ្វី?
ក. អានសៀវភៅ ខ. ធ្វើការងារផ្ទះ
គ. មើលថែសួនច្បារ ឃ. ចម្លើយទាំង៣

៧. តើទឹកចិត្តអាលីយូហ្សាចំពោះម្ចាស់ផ្ទះយ៉ាងដូចម្តេច?
ក. គេនឹងប្តឹងម្ចាស់ផ្ទះ ខ. គេខឹងគុំទុកក្នុងចិត្ត
គ. មិនរករឿង មិនតបតអ្វីទាំងអស់ ឃ. គ្មានចម្លើយ

៨. តើកម្ទេចឈើចំនួនប៉ុន្មានដើមជាប់នឹងអាលីយូហ្សា?
ក. ៣៩ ខ. ៤០
គ. ៤១ ឃ. ៤២

៩. តើចំណុចខាងក្រោមនេះមួយណាមិនមែនជាគំនិតសំខាន់ក្នុង "**អំណាន អាលីយូហ្សា**"?
ក. និយាយពីការតស៊ូក្នុងជីវិត ខ. និយាយស្រឡាញ់ការសិក្សា
គ. និយាយពីការមេត្តាចំពោះគ្នា ឃ. និយាយពីភាពអត់ធ្មត់



មេរៀនទី៩ ជោគជ័យនៃជីវិត

៩.១.បំណិន ៖ កំណាព្យបទភុជ្ឈលីលា

I. ចូរឆ្លងជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. ក្នុង ១វគ្គមាន ៣ឃ្លា។ ឃ្លាទី១ មាន៦ព្យាង្គ ឃ្លាទី២និងទី៣ មាន៤ព្យាង្គ។ តើជាវង្វាស់កាព្យបទអ្វី?

ក. បទបន្ទោលកាក ខ. បទភុជង្គលីលា

គ. បទពំនោល ឃ. បទព្រហ្មគីតិ

២. ព្យាង្គទី៦ នៃឃ្លាទី១ ចួននឹងព្យាង្គទី៤ នៃឃ្លាទី២ ក្នុងវគ្គទី១។ ជាលក្ខណៈចួនក្នុងវគ្គបទអ្វី?

ក. បទព្រហ្មគីតិ ខ. បទពំនោល

គ. បទបន្ទោលកាក ឃ. បទភុជង្គលីលា

៣. ព្យាង្គទី៤ ឃ្លាទី៣ នៃវគ្គទី១ ចួននឹង ព្យាង្គទី៦ ឃ្លាទី១ នៃវគ្គទី២។ តើគេហៅចួនអ្វី? បទអ្វី?

ក. ចួនឆ្លងវគ្គ បទភុជង្គលីលា ខ. ចួនឆ្លងវគ្គ បទពំនោល

គ. ចួនឆ្លងវគ្គ បទបន្ទោលកាក ឃ. ចួនឆ្លងវគ្គ បទព្រហ្មគីតិ

៤. តើការសូត្របទភុជង្គលីលា គេត្រូវទម្លាក់សំឡេងលើព្យាង្គណាខ្លះ?

ក. ព្យាង្គទី២គ្រប់ឃ្លា ខ. ព្យាង្គទី២និងទី៤គ្រប់ឃ្លា

គ. ព្យាង្គទី៤គ្រប់ឃ្លា ឃ. ព្យាង្គទី២ និងទី៣គ្រប់ឃ្លា

II. ចូរឆ្លងជ្រើសរើសពាក្យក្នុងប្រអប់ដើម្បីបំពេញចន្លោះខាងក្រោមឱ្យបានត្រឹមត្រូវ។

សិរសោ	ប្តី	ស្វាមី	ឥន្ទវតី	ភុជង្គលីលា

១. នេះបទកំណត់ចងជា	.....	ចងជាច្បាប់ស្រី។
២. កាលនាង	ចរចាកតាម	គឺបុណ្យយក្សា។
៣. នាងវិមាលាជាព្រះមាតា	បើកបន្ទូលថា	ហៃកូនពិសី។
៤. នាងនឹងគ្រាច់ត្រង់តាមប្តី	ចេញចាកអំពី	ពិភពនាគនេះ។
៥. ទៅឋានមនុស្សលោកនាយអេះ	ចូរនាងចាំចេះ	បម្រើ .....
៦. ធ្វើវត្តប្រតិបត្តិប្រក្រតី	កុំឱ្យស្វាមី	អាក់អន់ចិន្តា។
៧. នាងអើយគម្តែងក្រឡា	ជាម្ចាស់	កូនកុំមាក់ងាយ។

III. ចូរប្អូនធ្វើការផ្គូផ្គងចម្លើយពីប្រអប់ "ក" ទៅប្រអប់ "ខ" ឱ្យបានត្រឹមត្រូវ។

ផ្នែក "ក"	ផ្នែក "ខ"	ចម្លើយ
១. ព្យាង្គទី ៦ ឃ្លាទី ១	ក. ដំណើររបស់នាគ ឬ នាគដើរ	១-.....
២. ព្យាង្គទី ៤ ឃ្លាទី ១ វគ្គទី ១	ខ. ព្យាង្គក្នុងឃ្លានីមួយៗ ឬចំនួនឃ្លាក្នុងវគ្គនីមួយ	២-.....
៣. រង្វាស់កាព្យជាចំនួន	គ. ចួននឹង ព្យាង្គទី ៤ ឃ្លាទី ២	៣-.....
៤. កុជង្គលីលាមានន័យថា	ឃ. ចួននឹងព្យាង្គទី ៤ ឃ្លាទី ២ វគ្គទី ២	៤-.....
	ង. ចួននឹងព្យាង្គទី ៦ ឃ្លាទី ១ វគ្គទី ២	



មេរៀនទី៩ ឡោគជ័យនៃជីវិត

៩.២.អំណាន ៖ វិជ្ជាជាទ្រព្យ

I. ចូរប្អូនឱ្យនិយមន័យពាក្យគន្លឹះខាងក្រោមឱ្យបានត្រឹមត្រូវ។

១. អប្រិយ ( ) .....។

២. ពណ្ណរាយ ( ) .....។

៣. សង្វាត ( ) .....។

៤. និរន្តរ ( ) .....។

៥. ធនធាន ( ) .....។

II. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យត្រឹមត្រូវ។

១. តើអត្ថបទខាងលើនេះនិពន្ធឡើងដោយកវីនិពន្ធមួយណា?

ក. បណ្ឌិត ម៉ឺន ម៉ៃ ខ. ភិក្ខុ បទុមត្ថេរ សោម

គ. លោក ពេជ្ស ទុំក្រវិល ឃ. ហ្មឺនភក្តី អង្គ តន់

២. តើរង្វាស់កាព្យបទភុជង្គលីលាមួយណាខាងក្រោមដែលត្រឹមត្រូវ?

ក. ១ វគ្គ មាន ៤ ឃ្លា ខ. ឃ្លាទី ១ និងទី ៣ មាន ៦ ព្យាង្គ

គ. ឃ្លាទី ២ និងទី ៣ មាន ៤ ព្យាង្គ ឃ. ១ វគ្គ មាន ៧ ឃ្លា

៣. តើមួយណាជានិយមន័យរបស់ពាក្យ ឃ្មាតខ្មី?

ក. ការមានវិប្បដិសារី ខ. ការខំប្រឹងប្រែង សង្វាតខ្លាំង

គ. ជំណើររាវាំងស្ទះការងារ ឃ. ផ្អោះឥតរសជាតិ

៤. តើមួយណាជាចំណាប់ចួនក្នុងវគ្គនៃបទភុជង្គលីលា?

ក. ព្យាង្គទី ៤ ឃ្លាទី ១ ចួននឹង ព្យាង្គទី ៤ ឃ្លាទី ២

ខ. ព្យាង្គទី ៦ ឃ្លាទី ២ ចួននឹង ព្យាង្គទី ៤ ឃ្លាទី ៣

គ. ព្យាង្គទី ៤ ឃ្លាទី ៣ វគ្គទី ១ ចួននឹង ព្យាង្គទី ៦ ឃ្លាទី ១ វគ្គទី ២

ឃ. ព្យាង្គទី ៦ ឃ្លាទី ១ ចួននឹង ព្យាង្គទី ៤ ឃ្លាទី ២

៥. តើឃ្លាថា **ឈ្មានចោរមកធក់ប្លន់បាន**ឯមានន័យយ៉ាងដូចម្តេច?

ក. វិជ្ជាជាទ្រព្យនៅក្នុងខ្លួន មិនដូចមាសពេជ្សកែវកងដែលនៅក្រៅខ្លួននោះទេ

ខ. ចំណេះវិជ្ជាជាទ្រព្យមិនសំខាន់ ដូច្នេះចោរមិនចង់ប្លន់

គ. ចំណេះវិជ្ជាពិបាកក្នុងធក់ប្លន់ណាស់

ឃ. បើប្រៀបវិជ្ជាជាមួយនឹងលុយកាក់ គឺលុយកាក់សំខាន់ជាង

៦. តើឃ្លាថា ចាយច្រើនកើនច្រើនឥតខ្ជោះ មានន័យយ៉ាងដូចម្តេច?

ក. កាលណាយើងចាយលុយច្រើន យើងក៏បានលុយច្រើនមកវិញ

ខ. កាលណាយើងប្រើប្រាស់ចំណេះដឹងយើងច្រើន យើងនឹងកើនចំណេះវិជ្ជាកាន់តែច្រើនទៅ

គ. កាលណាយើងចាយលុយច្រើន យើងកើនចំណេះវិជ្ជាច្រើនឡើងៗ

ឃ. កាលណាយើងចាយចំណេះដឹងយើងច្រើន យើងនឹងកើនលុយច្រើនមកវិញ

៧. តើគំនិតសំខាន់នៅក្នុងអត្ថបទត្រង់វគ្គទី ១ ដល់ទី ៥ មានអ្វីខ្លះ?

ក. ចំណេះវិជ្ជាជាទ្រព្យដ៏សំខាន់ដែលយើងត្រូវតែមាន

ខ. ចំណេះវិជ្ជាជាទ្រព្យដែលគួរចាំបាច់ចាយដើម្បីបង្កើនចំណេះដឹងបន្ថែម

គ. ចំណេះវិជ្ជាធ្វើឱ្យមនុស្សមានតម្លៃ

ឃ. ចម្លើយទាំងអស់ខាងលើ

៨. តើគំនិតសំខាន់នៅក្នុងអត្ថបទត្រង់វគ្គទី ៥ ដល់ទី ១៥ គឺជាអ្វី?

ក. គុណវិបត្តិនៃការប្រើប្រាស់គ្រឿងញៀន

ខ. ផលវិបាកនៃការមានចំណេះវិជ្ជា

គ. តម្លៃនៃការមានចំណេះវិជ្ជា និងសីលធម៌

ឃ. ផលប្រយោជន៍នៃវិជ្ជាចំពោះតម្លៃមនុស្ស

៩. តើអត្ថបទខាងលើមានតម្លៃអប់រំយ៉ាងដូចម្តេច?

ក. ឱ្យយើងខិតខំសិក្សារៀនសូត្រ

ខ. ចង់ឱ្យមនុស្សទាំងអស់ស្វែងយល់ពីតម្លៃនៃវិជ្ជា

គ. ចង់ឱ្យយើងចេះប្រើប្រាស់ពេលវេលាសន្សំសំចៃ

ឃ. ចម្លើយទាំងអស់ខាងលើ

១០. តើការសិក្សាបែបណាខ្លះដែលជំរុញឱ្យបានភាពជោគជ័យ?

ក. ការសិក្សាជាក្រុម ជាមួយការស្រាវជ្រាវ

ខ. ការសិក្សាជាបុគ្គលខ្លួនឯងដោយគ្មានប្រដាប់ប្រដាសិក្សា

គ. ការសិក្សាដោយគ្មានការស្រាវជ្រាវ

ឃ. ការសិក្សាតែពីសៀវភៅគោល

១១. អំណាន "វិជ្ជាជាទ្រព្យ"តាក់តែងជាបទអ្វី?

ក. បទកុង្គលីលា ខ. បទព្រហ្មគីតិ

គ. បទពំនោល ឃ. បទកាកគតិ

១២. អំណាន "វិជ្ជាជាទ្រព្យ"អ្នកនិពន្ធចង់បង្ហាញពីតម្លៃអ្វី?

ក. តម្លៃសីលធម៌ ខ. តម្លៃទ្រព្យសម្បត្តិ

គ. តម្លៃនៃចំណេះវិជ្ជា ឃ. តម្លៃចរិយាសម្បត្តិ

១៣. តើអំណាន"វិជ្ជាជាទ្រព្យ" សំដៅលើទ្រព្យមួយណា?

ក. ទ្រព្យសម្បត្តិ ខ. ទ្រព្យក្រៅខ្លួន

គ. ទ្រព្យក្នុងខ្លួន ឃ. មាសពេជ្រ កែវកែង

១៤. គេបានចាត់ទុកវិជ្ជាជាទ្រព្យក្នុងខ្លួន.....លើកលែងតែ៖

ក. ព្រោះគ្មានអ្នកណាមើលឃើញ ខ. ព្រោះអាចប្រើប្រាស់បានគ្រប់ពេល

គ. ព្រោះចោរមិនអាចលួចបាន ឃ. ព្រោះងាយស្រួលយកចាយ

១៥. ឃ្លា"ចង់បាត់ងងឹត" នៅក្នុងអំណានវិជ្ជាទ្រព្យ សំដៅលើ....៖

ក. ភាពពិការភ្នែក ខ. ការខ្វះប្រាជ្ញា

គ. ភាពអវិជ្ជា ឃ. ភាពល្ងិតល្ងង់

១៦. នៅក្នុងអត្ថបទអំណា"វិជ្ជាជាទ្រព្យ" ឱ្យយើងខិតខំសិក្សា ដើម្បី.....៖

ក. ភាពរុងរឿងនៃជីវិត ខ. ការបំបាត់ភាពខ្ជិល

គ. ភាពជោគជ័យនៃជីវិត ឃ. ការធ្វើឱ្យមានអនាគតល្អ

១៧. ភាពជោគជ័យនៃជីវិតកើតឡើងមកពី.....៖

ក. សេចក្តីព្យាយាម ខ. ចិត្តជាអ្នកកំណត់

គ. ការទទួលខុសត្រូវ ឃ. ការជឿជាក់



មេរៀនទី៩ ជោគជ័យនៃជីវិត

៩.៣.វេយ្យាករណ៍៖ អំពីល្បះផ្សំ

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ។

១. តើល្បះទោលចែកចេញជាប៉ុន្មានប្រភេទ?

ក. ២ ប្រភេទ ខ. ៣ ប្រភេទ

គ. ៤ ប្រភេទ ឃ. ៥ ប្រភេទ

២. ល → នារីរាំលេង។

ក. ល → កន + កិ ខ. ល → កន + កិ + កមធ

គ. ល → កន១ + កិ +កន២ ឃ. ល → កន + កិ + ឃ្លា

៣. តើល្បះមួយណាខាងក្រោមចូលក្នុងទម្រង់ ល → កន១ + កិ + កន២ + កមធ?

ក. នារីចូលចិត្តទៅស្រែ។ ខ. បុប្ផាជិះកង់ទៅសាលារៀន។

គ. ធីតាអង្គុយមាត់ស្រះទឹក។ ឃ. សត្តាច្រៀង។

៤. តើល្បះមួយណាខាងក្រោមដែលចូលក្នុងទម្រង់ ល → កន១ + កិ + កមធ?

ក. ចិន្តាកំពុងរៀនមេរៀនភាសាខ្មែរ។ ខ. ទេពីលេងជាមួយប្អូននាង។

គ. សុកីយំ។ ឃ. នារីខិតខំសិក្សារៀនសូត្រ។

៥. តើល្បះមួយណាខាងក្រោមដែលមានកន្សោមមានធ្នាក់?

ក. វិជ្ជាជាទ្រព្យនៅក្នុងខ្លួន។ ខ. ចំណេះវិជ្ជាជាទ្រព្យមិនសំខាន់។

គ. គ្រឿងញៀនជាអាវុធប្រល័យសុខភាព។ ឃ. សីលធម៌ចម្រាញ់ធនធានមនុស្ស។

៦. តើល្បះផ្សំចែកចេញជាប៉ុន្មានបែប?

ក. ១ បែប ខ. ២ បែប

គ. ៣ បែប ឃ. ៤ បែប

៧. តើល្បះខាងក្រោមមួយណាដែលចូលក្នុងទម្រង់ទី ១ នៃល្បះផ្សំ?

ក. ធនធានមនុស្សជាសម្បត្តិដែលប្រទេសជាតិត្រូវការក្នុងការអភិវឌ្ឍ។

ខ. យើងត្រូវខិតខំសិក្សារៀនសូត្រដើម្បីអនាគតខ្លួនយើង។

គ. ដារាសង្ឃឹមថាគេនឹងប្រឡងជាប់ឆ្នាំនេះ។

ឃ. យើងត្រូវគោរពលោកគ្រូអ្នកគ្រូដែលជាឪពុកម្តាយទីពីររបស់យើង។

៨. តើល្បះខាងក្រោមមួយណាដែលចូលក្នុងទម្រង់ទី ២ នៃល្បះផ្សំ?

ក. ប្រជាពលរដ្ឋយើងខិតខំធ្វើការដើម្បីប្រទេសជាតិរីកចម្រើន។

ខ. ចំណេះវិជ្ជាចម្រាញ់ធនធានមនុស្សដែលមានសក្តានុភាព។

គ. យើងខិតខំថែរក្សាវប្បធម៌ជាតិខ្មែរដើម្បីអភិរក្សអត្តសញ្ញាណជាតិយើង។

ឃ. សាលារៀនជាថ្នាលបណ្តុះចំណេះវិជ្ជា។

៩. តើល្បះខាងក្រោមមួយណាដែលចូលក្នុងទម្រង់ទី ៣ នៃល្បះផ្សំ?

ក. យើងត្រូវចេះសន្សំសំចៃពេលវេលា។

ខ. ព្រះវេស្សន្តរបានធ្វើមហាបរិច្ចាគប្រាំមុខដើម្បីត្រាស់ដឹងក្លាយជាព្រះសមាសម្ពុទ្ធ។

គ. នាងមទ្រីជាកន្សែសារពេជ្ជរបស់ព្រះវេស្សន្តរ។

ឃ. រឿងពុទ្ធនិយមអប់រំទ្រឹស្តីកម្មផលទៅកាន់មនុស្ស។

១០. តើពាក្យណាខ្លះដែលត្រូវតាងចេញពីកន្សោមនាម?

ក. នៃ របស់ ខ. ដើម្បី ពីព្រោះ

គ. ដែល របស់ ឃ. ដល់ នៃ

១១. យើងនាំគ្នាចូលរួមថែរក្សាបរិស្ថាន។ តើជាប្រភេទល្បះអ្វី?

ក. ល្បះបញ្ជា ខ. ល្បះឧទាន

គ. ល្បះបញ្ជាក់ ឃ. ល្បះសំណួរ

១២. សូមលោកគ្រូអភ័យទោសឱ្យនាងផង ! តើជាប្រភេទល្បះអ្វី? បែបអ្វី?

ក. ល្បះបញ្ជាបែបបង្គាប់បញ្ជា ខ. ល្បះបញ្ជាបែបសំណូមពរ

គ. ល្បះបញ្ជាបែបអង្វរ ឃ. ល្បះបញ្ជាបែបឱ្យដំបូន្មាន

១៣. នៅមេរៀនល្បះផ្សំ តើល្បះមានប៉ុន្មានយ៉ាង?

ក. មាន ៣យ៉ាង ខ. មាន ៤យ៉ាង

គ. មាន ៥យ៉ាង ឃ. មាន ៦យ៉ាង

១៤. តើបីយ៉ាងនោះមានល្បះអ្វីខ្លះ?

ក. ល្បះទោល ល្បះផ្សំ ល្បះសំណួរ ខ. ល្បះទោល ល្បះផ្សំ ល្បះបញ្ជា

គ. ល្បះទោល ល្បះផ្សំ ល្បះឧទាន ឃ. ល្បះទោល ល្បះផ្សំ ល្បះក្រង

១៥. "សុភាពនិយាយជាមួយសុជាតា"។ តើស្ថិតក្នុងល្បះទោលទម្រង់ទីប៉ុន្មាន?

ក. ទម្រង់ទី១ ខ. ទម្រង់ទី២

គ. ទម្រង់ទី៣ ឃ. ទម្រង់ទី៤

១៦. "សុភាពនិយាយជាមួយសុជាតា"។ ចូរញែកទម្រង់ល្បះទោលទី៣។

ក. កន១+ កិ+កន២ ខ. កន១+កិ+ កមធ

គ. កន១+ កិ+កន២+កមធ ឃ. កន១+កកិ

១៧. "ម្តាយខ្ញុំទិញផ្លែឈើក្នុងផ្សារទំនើប។" តើស្ថិតក្នុងល្បះទោលទម្រង់ទីប៉ុន្មាន?

ក. ទម្រង់ទី១ ខ. ទម្រង់ទី២

គ. ទម្រង់ទី៣ ឃ. ទម្រង់ទី៤

១៨. "ម្តាយខ្ញុំទិញផ្លែឈើក្នុងផ្សារទំនើប។" ចូរញែកទម្រង់ល្បះទោលទី៤។

ក. កន១+ កិ+កន២ ខ. កន១+កិ+ កមធ គ. កន១+ កិ+កន២+កមធ ឃ. កន១+កកិ

១៩. ចូររើសចម្លើយខាងក្រោមឱ្យត្រូវតាមទម្រង់"កន១+កិ+កន២"។

ក. ជីតាខ្ញុំក្ងរស្រែ។ ខ. ឪពុកខ្ញុំកាប់ព្រៃក្រោយផ្ទះ។

គ. ឆ្កែព្រុស។ ឃ. តារាវត់លេងក្នុងសួនច្បារ។

២០. តើកន្សោមនាមមួយ(កន១)មាននាទីជាអ្វីក្នុងល្បះទោល?

ក. ជាប្រធាន ខ. ជាកម្មបទផ្ទាល់

គ. ជាកម្មបទមិនផ្ទាល់ ឃ. ជាកិរិយាបង្គោល

២១. តើកន្សោមនាមពីរ(កន២)មាននាទីជាអ្វីក្នុងល្បះទោល?

ក. ជាប្រធាន ខ. ជាកម្មបទផ្ទាល់

គ. ជាកម្មបទមិនផ្ទាល់ ឃ. ជាកម្មបទផ្ទាល់ឬមិនផ្ទាល់

២២. តើធាតុសំខាន់ៗនៅក្នុងល្បះទោលមានអ្វី?

ក. កន្សោមនាម ខ. កន្សោមកិរិយា

គ. កន្សោមមានផ្នាក់ ឃ. ចម្លើយទាំង៣

២៣. ល្បះដែលកើតឡើងពីទម្រង់តូចបំផុតមានកន្សោមនាម និងកន្សោមកិរិយា ដែលមិនមានភាពស៊ាំញ៉ាំជាល្បះអ្វី?

ក. ល្បះទោល ខ. ល្បះផ្សំ

គ.ល្បះក្រង ឃ. បែបនៃល្បះ

២៣. កន្សោមនាមអាចប្រើបានជា.....<u>លើកលែង</u>

ក. ប្រធាន ខ. គុណកិរិយា

គ.កម្មបទផ្ទាល់ ឃ. គុណប្រធាន

២៤. ល→ ធីតាជាអ្នកចម្រៀង។ ពាក្យ "អ្នកចម្រៀង"មានតួនាទីអ្វីក្នុងល្បះនេះ។

ក. ប្រធាន ខ. គុណប្រធាន

គ.កម្មបទផ្ទាល់ ឃ. ឧបបទ

២៥. ល→ សូរិយាជជែកគ្នាក្រោយសាលារៀន។ ពាក្យ "ក្រោយសាលារៀន"មានតួនាទីអ្វីក្នុងល្បះ?

ក. កន្សោមនាម ខ. កន្សោមកិរិយា

គ.កន្សោមមានផ្នាក់ ឃ. កន្សោមទេសកាល

២៦. តើកន្សោមពាក្យខាងក្រោមមួយណាជាកន្សោមនាម?

ក. លក់សៀវភៅ ខ.រត់យឺត

គ. ក្នុងបន្ទប់រៀន ឃ. សៀវភៅប្រវត្តិសាស្ត្រ

២៧. តើល្បះផ្សំជាអ្វី?

ក.ល្បះជាច្រើនបូករួមផ្សំចូលគ្នា។

ខ. ល្បះដែលកើតឡើងរវាងឃ្លាច្បងនិងឃ្លារណប។

គ. ល្បះមានតែកន្សោមនាមនិងកន្សោមកិរិយា។

ឃ. ល្បះដែលកើតឡើងពីកន្សោមមានធ្នាក់តែមួយគត់។

២៨. តើល្បះខាងក្រោមមួយណាដែលមិនមែនជាល្បះផ្សំ?

ក.ល→ធីតាខំធ្វើការងារដើម្បីផ្គត់ផ្គង់គ្រួសារ។

ខ. ល→យើងជួយទិញបន្លែដែលដាំដោយកសិករ។

គ.ល→នារីប្រាប់ថាម្តាយនាងទិញសម្លៀកបំពាក់ថ្មី។

ឃ. ល→សូរិយាដាំបន្លែក្រោយផ្ទះរបស់វា។

II. **ចូរឃ្លុនគូសតាងខាងក្រោមជាមែកធាង និងជាប្រអប់។**

១. របបប្រល័យពូជសាសន៍ខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរដោយគ្មានហេតុផល។

២. រចាំព្រះរាជទ្រព្យខ្មែរយើងជាសម្បត្តិបេតិកភណ្ឌពិភពលោក។

៣. យើងត្រូវចេះសន្សំសំចៃពេលវេលា។

៤. ប្រជាពលរដ្ឋយើងខិតខំធ្វើការដើម្បីប្រទេសជាតិរីកចម្រើន។

៥. ធនធានមនុស្សជាសម្បត្តិដែលប្រទេសជាតិត្រូវការក្នុងការអភិវឌ្ឍ។

III. ចូរឃ្លុនស្វែងរកល្បះផ្សំ ដែលមាននៅក្នុងអត្ថបទខាងក្រោមឱ្យបាន ៣ រួចបង្ហាញទម្រង់ល្បះនោះ។

រចាំកិន្នរ

កិន្នរ និងកិន្នរី គឺជាសត្វដែលមាននៅក្នុងព្រៃហិមពាន្ត ដែលមានរាងកាយផ្នែកខាងលើជាមនុស្សខាងក្រោមជាសត្វមានស្លាបអាចហោះហើរបាន។ នៅក្នុងវចនានុក្រមខ្មែរបានផ្តល់និយមន័យថា «ឈ្មោះបក្សីមួយប្រភេទដែលមានរូបដូចមនុស្ស មានស្លាបហើរបាន មាននិយាយតែក្នុងរឿងបុរាណ»។ តាមតំណាលនិទានថាកិន្នរនេះអាស្រ័យនៅក្នុងព្រៃហិមពាន្តជើងភ្នំកៃលាស ហើយដែលជាសត្វមួយប្រភេទមានប្រាកដនៅក្នុងសិល្បៈបុរាណខ្មែរក៏ដូចជានៅក្នុងអក្សរសិល្ប៍ខ្មែរ មាននិយាយដល់ប្រភេទសត្វនេះដែរ ដូចជានៅក្នុងរឿងព្រះសុធន នាងកែវមនោរាហ៍ជាដើម។ល។ គេប្រទះឃើញសិល្បៈសត្វកិន្នរដំបូងគេនៅប្រាសាទសម្ប្ររព្រៃគុក (ស.វ.ទី ៧) ដែលជាតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។ នៅសម័យអង្គរសត្វកិន្នរត្រូវបានគេពណ៌នានៅជញ្ជាំងប្រាសាទអង្គរវត្ត ដែលមានរូបរាងខុសប្លែកពីគ្នា។ នៅប្រាសាទអង្គរវត្ត ក៏មានការពណ៌នាជាច្រើនអំពីរចាំកិន្នរ ដែលត្រូវបានគេឃើញជាទូទៅធ្លាក់ជារូបចម្លាក់ដួរឈរតាមសសរ ឬជញ្ជាំង។ នៅក្នុងសម័យអាណានិគមបារាំង រចាំកិន្នរត្រូវបានលើកកម្ពស់ជាខ្លាំងដោយព្រះមហាក្សត្រ។ នៅឆ្នាំ ១៩០៦ រចាំកិន្នរត្រូវបានលេងនៅទីបអ៊ីរ៉ុបជាលើកដំបូង។



មេរៀនទី៩ ជោគជ័យនៃជីវិត

៩.៤.អំណាន ៖ ជ័យជម្នះរបស់លោកគូប៊ែតាំង

I. ចូរប្អូនជ្រើសរើសចម្លើយត្រឹមត្រូវមួយគត់ចំពោះសំណួរខាងក្រោម។

១. តើអត្ថបទខាងលើនិយាយអំពីកីឡាអ្វី?

ក. បាល់ទាត់ ខ. អូឡាំពិក

គ. វាយសី ឃ. បោះបូល

២. តើមួយណាខាងក្រោមជាក្តីស្រមៃរបស់លោកគូប៊ែតាំង?

ក. លោកតម្កើងកីឡាឡើងវិញ ខ. មនុស្សគ្រប់ជាតិសាសន៍អាចចូលរួម

គ.កីឡានាំមកនូវសន្តិភាពពិភពលោក ឃ. ចម្លើយទាំងអស់ខាងលើ

៣. តើមានប្រជាជនមកពីតំណាងប្រទេសប៉ុន្មានដែលចូលរួមសមាជដើម្បីរៀបចំល្បែងកីឡាអូឡាំពិក?

ក. ១២ ប្រទេស ខ. ១៣ ប្រទេស

គ. ១៤ ប្រទេស ឃ. ១៥ ប្រទេស

៤. នៅឆ្នាំ ១៩៦៤ ល្បែងកីឡាអូឡាំពិកត្រូវបានប្រព្រឹត្តនៅទីណា?

ក. ទីក្រុងតូក្យូ ប្រទេសជប៉ុន ខ. ទីក្រុងម៉ិកស៊ិក ប្រទេសម៉ិកស៊ិក

គ. ទីក្រុងញូយ៉ក សហរដ្ឋអាមេរិក ឃ. ទីក្រុងប៉េកាំង ប្រទេសចិន

៥. នៅឆ្នាំ ១៩៦៨ ល្បែងកីឡាអូឡាំពិកត្រូវបានប្រព្រឹត្តនៅទីណា?

ក. ទីក្រុងតូក្យូ ប្រទេសជប៉ុន ខ. ទីក្រុងម៉ិកស៊ិក ប្រទេសម៉ិកស៊ិក

គ. ទីក្រុងញូយ៉ក សហរដ្ឋអាមេរិក ឃ. ទីក្រុងប៉េកាំង ប្រទេសចិន

៦. តើកីឡានាំមកនូវផលប្រយោជន៍អ្វីខ្លះ?

ក. សុខភាពល្អរឹងមាំ ខ. បណ្តុះគំនិតប្រឌិត

គ. ធ្វើឱ្យរាងកាយធន់នឹងជំងឺ ឃ. ចម្លើយទាំងអស់ខាងលើ

៧. តើពិធីបុណ្យអូឡាំពិកមានតាំងពីឆ្នាំណាមកម្ល៉េះ?

ក. ៨០០ មុនគ.ស ខ. ៥៧៦ មុនគ.ស

គ. ៧៧៦ មុនគ.ស ឃ. ៨៩៣ មុនគ.ស

៨. តើអ្នកឈ្នះបុណ្យកីឡាអូឡាំពិកទទួលបានរង្វាន់ជាទម្រង់អ្វី?

ក. មេដាយមាស ខ. ពានរង្វាន់មាស

គ. ម្កុដមែកអូលីវ ឃ. ខ្សែកពេជ្រ

៩. តើល្បះដែលដកស្រង់ចេញពីអត្ថបទមួយណាដែលជាល្បះផ្សំ?

ក. នៅឆ្នាំ ១៩៦៨ ល្បែងនេះត្រូវបានរៀបចំឡើងនៅក្នុងប្រទេសម៉ិកស៊ិក។

ខ. នារីមិនត្រូវគេអនុញ្ញាតឱ្យចូលក្នុងកីឡាដ្ឋានទេ។

គ. ជនជាតិជាច្រើនបានបង្កើតក្រុមប្រឹក្សាអូឡាំពិកអន្តរជាតិ។

ឃ. យើងសូមអរគុណលោកគូប៊ែតាំង ដែលបានធ្វើឱ្យល្បែងអូឡាំពិកកើតឡើងវិញ។

១០. តើកីឡាអូឡាំពិកមានសារប្រយោជន៍អ្វីខ្លះដល់ពិភពលោក?

ក. លុបបំបាត់រាល់ការរើសអើងពូជសាសន៍ ពណ៌សម្បុរ

ខ. លើកស្ទួយសមភាពយេនឌ័រ

គ. ផ្សព្វផ្សាយអត្ថប្រយោជន៍នៃការលេងកីឡា

ឃ. ចម្លើយទាំងអស់ខាងលើ

១១. តើលោកគូប៊ែតាំងមានគោលបំណងធំបំផុតជាអ្វី?

ក. ឱ្យប្រទេសបារាំងនិងពិភពលោកទាំងស្គាល់កីឡា។

ខ. ធ្វើការផ្សព្វផ្សាយពីការឆន្ទៈរបស់គាត់។

គ. ឱ្យប្រទេសក្រិចទទួលស្គាល់កីឡាអត្តពលកម្ម។

ឃ. ធ្វើឱ្យមានឯកភាព និងភាតរភាព។

១២. តើនរណាជាអ្នកធ្វើឱ្យមានល្បែងអូឡាំពិកកើតឡើងវិញ?

ក. ក្រុមប្រឹក្សាអូឡាំពិក ខ. លោកបារ៉ុងព្យែរឌឺ គូប៊ែតាំង

គ. អត្តពលទាំងអស់ ឃ. ប្រជាជនក្រិច

II. ចូរប្អូនប្រើប្រាស់ពាក្យក្នុងប្រអប់ខាងក្រោមដើម្បីបំពេញចន្លោះ ..... ខាងក្រោមឱ្យបានត្រឹមត្រូវ។

បួនឆ្នាំម្តង	អូឡាំ	១០៤ ប្រទេស	សម្លៀកបំពាក់	ភាតរភាព

១. លុះដល់ឆ្នាំ ១៩៦៤ ក្នុងឱកាសល្បែងកីឡាអូឡាំពិក នៅតូក្យូ ប្រទេសដែលចូលរួមមានរហូតដល់ទៅ ..... ហើយអត្តពលករបានចូលរួមជាផ្លូវការរហូតដល់ ៨៥០០ នាក់។

២. ទស្សនីយភាពល្បែងនេះបានធ្វើឱ្យយុវជនប្រកបដោយសុខភាព បំណិនប្រសប់និង .....។

៣. ល្បែងកីឡាអូឡាំពិកប្រព្រឹត្តទៅរៀងរាល់.....។

៤. កាលពីសម័យមុន កីឡានេះត្រូវបានប្រព្រឹត្តទៅក្នុងកីឡាដ្ឋាន អត្តពលករទាំងអស់ត្រូវតែដោះ .....ចេញ ដើម្បីឱ្យអ្នកផងស្ងើចសរសើរសោភណភាពរាងកាយរបស់គេ។

៥. នៅពេលប្រារព្ធល្បែងកីឡាអូឡាំពិកម្តងៗ សូម្បីតែតំបន់អេលីដ ដែលជាទីតាំងនៃភ្នំ..... ក៏ត្រូវហាមប្រាមមិនឱ្យកងទ័ពចូលដែរ។



មេរៀនទី៩ ជោគជ័យនៃជីវិត

៩.៥.អំណាន ៖ កាព្យឆ្ពោះឆ្ពង

I. ចូរឬនឱ្យនិយមន័យពាក្យគន្លឹះខាងក្រោមឱ្យបានត្រឹមត្រូវ។

១. រាជការ ( ) .....។

២. គូលី ( ) .....។

៣. ក្រវើន ( ) .....។

៤. នាម៉ឺន ( ) .....។

៥. ក្រាញ ( ) .....។

II. ចូរឬនជ្រើសរើសចម្លើយត្រឹមត្រូវតែមួយគត់ចំពោះសំណួរខាងក្រោម។

១. តើអត្ថបទខាងលើនេះនិពន្ធឡើងដោយកវីនិពន្ធមួយណា?

ក. លោក ម៉ុក សំឱិក ខ. លោក សួន សុរិន្ទ

គ. លោក ពេជ្យ ទុំក្រវិល ឃ. លោក ញ៉ុក ថៃម

២. តើរង្វាស់កាព្យបទបន្ទោលកាកមួយណាខាងក្រោមដែលត្រឹមត្រូវ?

ក. ១ វគ្គ មាន ៤ ឃ្លា ខ. ឃ្លាទី ១ និងទី ៣ មាន ៦ ព្យាង្គ

គ. ឃ្លាទី ២ និងទី ៣ មាន ៤ ព្យាង្គ ឃ. ១ វគ្គ មាន ៧ ឃ្លា

៣. តើមួយណាជានិយមន័យរបស់ពាក្យ គៀច?

ក. ទម្រន់ ក្រាញ មិនព្រមទៅ ខ. ការខំប្រឹងប្រែង សង្វាតខ្លាំង

គ. ដំណើររារាំងស្ទះការងារ ឃ. ផ្ទោះឥតរសជាតិ

៤. តើមួយណាជាចំណាប់ចួនក្នុងវគ្គនៃបទកុជង្គលីលា?

ក. ព្យាង្គទី ៤ ឃ្លាទី ១ ចួននឹង ព្យាង្គទី ៤ ឃ្លាទី ២

ខ. ព្យាង្គទី ៦ ឃ្លាទី ២ ចួននឹង ព្យាង្គទី ២ ឃ្លាទី ៣

គ. ព្យាង្គទី ៤ ឃ្លាទី ៣ វគ្គទី ១ ចួននឹង ព្យាង្គទី ៦ ឃ្លាទី ១ វគ្គទី ២

ឃ. ព្យាង្គទី ៦ ឃ្លាទី ១ ចួននឹង ព្យាង្គទី ៤ ឃ្លាទី ២

៥. តើកំណាព្យខាងលើជាកិច្ចសន្ទនារវាងនរណានឹងនរណា?

ក. មន្ត្រីរាជការ និងពលករ ខ. ព្រះមហាក្សត្រ និងរាស្ត្រ

គ. នាម៉ឺន (មន្ត្រីរាជការ) និងកសិករ ឃ. គ្រូ និងសិស្ស

៦. មូលហេតុអ្វីបានជាកសិករបដិសេធមិនធ្វើមន្ត្រីរាជការ?

ក. គ្មានអ្នកណាសម្រាប់ធ្វើការងារធ្ងន់ដូចជាកសិកម្ម

ខ. កសិករមានហានៈស្មើនឹងមន្ត្រីរាជការព្រោះបម្រើជាតិតែមួយ

គ. កសិករ និងមន្ត្រីរាជការប្រើប្រាស់កម្លាំងប្រាជ្ញា និងហត្ថាដូចគ្នា

ឃ. ចម្លើយទាំងអស់ខាងលើ

៧. តាមគំនិតរបស់កសិករ តើការងារមន្ត្រីរាជការមានលក្ខណៈបែបណា?

ក. ស្រួល គ្មានពិបាកអ្វីទាល់តែសោះ

ខ. ពិបាកខ្លាំងជាងការងារស្រែចម្ការ

គ. ដូចតែការងារស្រែចម្ការគឺប្រើទាំងកម្លាំងហត្ថា និងកម្លាំងប្រាជ្ញា

ឃ. ធុញថប់ព្រោះត្រូវតែអង្គុយតែមួយកន្លែងទាំងថ្ងៃទាំងយប់

៨. តាមរយៈអត្ថបទ ការងារសុចរិតទាំងអស់អាចទទួលជោគជ័យបានដោយសារអ្វី?

ក. មានឆន្ទៈ និងទំនួសខុសត្រូវ

ខ. មានឆន្ទៈ និងជំនឿជាក់

គ. មានឆន្ទៈ និងសមត្ថភាព

ឃ. មានឆន្ទៈ និងកម្លាំងបាយ

៩. តើអត្ថបទខាងលើមានតម្លៃអប់រំយ៉ាងដូចម្តេច?

ក. ការងារទាំងអស់សុទ្ធតែមានតម្លៃ

ខ. មនុស្សទាំងអស់សុទ្ធតែមានសមត្ថភាពខុសៗ គ្នាក្នុងការធ្វើការងារ

គ. កុំមើលស្រាលការងារអ្នកដទៃ

ឃ. ចម្លើយទាំងអស់ខាងលើ

II. ចូរប្អូនពន្យល់អត្ថន័យក្នុងកំណាព្យខាងក្រោម

ម៉ែ(**បទព្រហ្មគីតិ**)

- ពីរោះណាស់អ្នកមេ សៀងបំពេរសូរវង់
  បានឮកូនលែងយំ ភារៈធំនៃអ្នកម្តាយ ។
- ទឹកដោះឥតលាក់លៀម កូនអង្គាមបឺតសប្បាយ
  ម៉ែឱ្យកូនឥតស្តាយ កូនគ្រប់កាយត្រូវតែដឹង ។
- កូនអើយបឺតឈាមម៉ែ រាប់សិបខែឥតខេខឹង
  ទោះទន់ទាល់តានតឹង រគឹងឆ្អឹងប្រឹងតស៊ូ ។
- កាយម៉ែដូចបង្គន់ នោមជុះជន់ដូចជាលូ
  រោគរាករុះរូៗ ឥតរអ៊ូស្អុយឆ្អាបឆ្អេះ ។

- ឥតថ្លូវត្រាកូនធំ　　ហ៊ានទូលក្នំពុំប្រហែស
  ម៉ែខ្លះខ្លីចំណេះ　　បោលដូចសេះដើម្បីបុត្រ ។
- សាច់ម៉ែធ្លាក់យូរយារ　　រុំរោគាឥតតក់ស្លុត
  ចម្លងកូនវិសុទ្ធ　　ឱ្យឆ្លងផុតលោកកិយកម្ម។

(ដកស្រង់ចេញពីកំណាព្យពីនេះពីនោះ និពន្ធដោយលោកដ៏យចាប)



មេរៀនទី៩ ជោគជ័យនៃជីវិត

៩.៦.ការស្តាប់ ៖ ល្បែក ជុចនិចត្រី

I. ចូរប្អូនពន្យល់ពាក្យគន្លឹះខាងក្រោមឱ្យបានត្រឹមត្រូវ។

១. ល្បែក ( ) .....។

២. ជុច ( ) .....។

៣. ទម្លុះ ( ) .....។

៤. បារមី ( ) .....។

៥. សូគ៌ា ( ) .....។

II. ចូរប្អូនផ្គូផ្គងចម្លើយពីប្រអប់ ក ទៅប្រអប់ ខ ឱ្យបានត្រឹមត្រូវ។

ក	ខ	ចម្លើយ
១. អត្ថបទកាព្យខាងលើតែងជា	ក. ក្អែងក្អាង មានអំណួត	១-.....
២. ត្រង់កន្លែងបណ្តាំមច្ចាតែងជា	ខ. បទព្រហ្មគីតិ និងបន្ទោលកាក	២-.....
៣. ត្រីមានលក្ខណៈ	គ. បទបន្ទោលកាក	៣-.....
៤. ជុចមានលក្ខណៈ	ឃ. ដឹងចំណុចខ្សោយដៃគូ	៤-.....
	ង. បទព្រហ្មគីតិ	

III. ចូរប្អូនជ្រើសរើសចម្លើយត្រឹមត្រូវតែមួយគត់ចំពោះសំណួរខាងក្រោម។

១. តើអត្ថបទកាព្យនេះត្រូវបាននិពន្ធឡើងដោយនរណា?

ក. បណ្ឌិត ម៊ឺន ម៉ែ ខ. ភិក្ខុ បទុមត្ថេរ សោម

គ. លោក វិសេសដួង ឃ. ហ្ម៊ឺនកក្តី អង្គ តន់

២. តើតួអង្គត្រីក្នុងល្បែកមួយនេះតំណាងឱ្យមនុស្សបែបណា?

ក. មនុស្សរឹងប៉ឹង ម៊ឹងម៉ាត់ ខ. មនុស្សទន់ជ្រាយ កំសាក

គ. មនុស្សអំណួត ក្អែងក្អាង ឃ. មនុស្សមានឧបាយកលច្រើន

៣. តួអង្គជុចក្នុងល្បែកមួយនេះតំណាងឱ្យមនុស្សបែបណា?

ក. មនុស្សរឹងប៉ឹង ម៊ឹងម៉ាត់ ខ. មនុស្សទន់ជ្រាយ កំសាក

គ. មនុស្សអំណួត ក្អែងក្អាង ឃ. មនុស្សមានឧបាយកលច្រើន

៤. តើតួអង្គជុចដោះស្រាយបញ្ហាជាមួយត្រីតាមរបៀបណា?

ក. ភាពមាន: រឹងរូស ខ. សន្តិវិធី អហិង្សា

គ. ប្រាជ្ញា និងភាពវៃឆ្លាត ឃ. ការបោកបញ្ឆោត

៥. ហេតុអ្វីបានជាតួអង្គត្រីទទួលបានបរាជ័យក្នុងវិវាទជាមួយជុច?

ក. ភាពមាន: និងរឹងរូសរបស់ខ្លួន គ្មានបំណងចុះចាញ់

ខ. ប្រាជ្ញារបស់ខ្លួនមិនដល់ប្រាជ្ញារបស់ជុច

គ. ជុចមិនប្រើប្រាស់សន្តិវិធី

ឃ. ត្រីត្រូវចាញ់ឧបាយកលរបស់ជុច

៦. ត្រង់វគ្គ បណ្តាំមច្ឆា តើល្បើកត្រូវបានតែងជាបទអ្វី?

ក. បន្ទោលកាក ខ. ពាក្យប្រាំពីរ

គ. ព្រហ្មគីតិ ឃ. កុជង្គលីលា

៧. ត្រង់វគ្គ ត្រីនិងមច្ឆាផ្តោះផ្តងគ្នា តើល្បើកត្រូវបានតែងជាបទអ្វី?

ក. បន្ទោលកាក ខ. ពាក្យប្រាំពីរ

គ. ព្រហ្មគីតិ ឃ. កុជង្គលីលា

៨. តើអត្ថបទ "**ការស្តាប់ ល្បើក ជុចនិងត្រី**"ខាងលើមានតម្លៃអប់រំយ៉ាងដូចម្តេច?

ក. កុំរឹងរូស រឹងប៉ឹង និងមានមានះពេក

ខ. ត្រូវចេះប្រើប្រាស់ប្រាជ្ញាក្នុងការដោះស្រាយបញ្ហា

គ. កុំអួតអាង ក្អេងក្អាងពេក

ឃ. ចម្លើយទាំងអស់ខាងលើ

IV. ចូរប្អូនពន្យល់អត្ថន័យនៃកំណាព្យខាងក្រោម

- ថ្លែងដោយទំនង ដំណើរត្រីផងយាត្រា
  ពើបនឹងជុចណា ត្រីស្រែកថារើយចៀសចេញ។
- ជុចថានេះអើ បុណ្យអ្នកនេះតើម្តងមិញ
  ក៏មកប្រើអញ ចៀសចេញឱ្យអ្នកជាល្បែង។
- ត្រីថាបើច្នោះ អញនឹងទំលុះចៅឯង
  ឱ្យយល់ជាក់ស្តែង ត្បិតឯងមករាំងផ្លូវ។



មេរៀនទី១០ ពលរដ្ឋល្អ

១០.១. បំណិន ៖ ប្រលោមលោកទំនើប

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. រឿងដែលប្រលោមចិត្តរបស់មនុស្សនិងបង្ហាញពីស្ថានភាពសង្គមជាក់ស្តែងជាប្រភេទរឿងអ្វី?

ក.ប្រលោមលោកបុរាណ ខ. រឿងព្រេងនិទាន

គ.ប្រលោមលោកទំនើប ឃ. ចម្លើយទាំង៣

២. វិធីដែលអ្នកនិពន្ធធ្វើឱ្យអ្នកអាន អ្នកស្តាប់ឆ្ងល់ចង់តាមដាមហៅថាអ្វី?

ក. សន្ទេហាវិធី ខ. វចនាវិធី

គ. រចនាវិធី ឃ. វណ្ណនាវិធី

៣. វិធីដែលអ្នកនិពន្ធបានធ្វើការប្រៀបធៀបតួអង្គឬសកម្មភាពផ្សេងៗហៅថាអ្វី?

ក. សំវាទវិធី ខ. បដិវិធី

គ.ឯកវាទវិធី ឃ. ឧបមានវិធី

៤. តម្លៃដែលអ្នកនិពន្ធបង្កើតឱ្យមានដំណើររឿងក្តីភាពអណ្តែតអណ្តូងហៅថាអ្វី?

ក.បច្ចេកវេស ខ. កាព្យវេស

គ.ប្រលោមវេស ឃ. នាដកវេស

៥. តើប្រលោមលោកទំនើបគឺជាអ្វី?

ក. រឿងប្រលោមចិត្តមនុស្ស ដែលអ្នកតែងប្រឌិតប្រដូចឡើងតាមទំនងព្រឹត្តិការណ៍ក្នុងសង្គម ។

ខ. រឿងកើតចេញពីភាពច្នៃប្រឌិតរបស់មនុស្ស និងរៀបរាប់អំពីព្រឹត្តិការណ៍ប្រឌិតហួសហេតុ។

គ. រឿងដែលនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយ

ឃ. រឿងប្រលោមចិត្តមនុស្ស ដែលត្រូវបានតាក់តែងមុនសង្គ្រាមលោកលើកទី ២។

៦. តើរឿងខាងក្រោមនេះ រឿងមួយណាជាប្រលោមលោកទំនើប?

ក. វេស្សន្តរជាតក ខ. រាមកេរ្តិ៍ខ្មែរ

គ. គ្រូបង្រៀនស្រុកស្រែ ឃ. រាមាយណៈឥណ្ឌា

៧. តើរឿងខាងក្រោមនេះ រឿងមួយណាដែលមិនមែនជាប្រលោមលោកទំនើប?

ក. កុលាបប៉ៃលិន ខ. មហាភារយុទ្ធ

គ. ផ្កាស្រពោន ឃ. តេជោយ៉ត

៨. តើប្រលោមលោកទំនើបមានចំណុចសំខាន់ៗ អ្វីខ្លះ?

ក. អត្ថន័យ ខ. អត្ថរស

គ. អត្ថរូប ឃ. ចម្លើយក ខ គ

៩. តើបញ្ហាតួអង្គ ជំនឿ ស្នេហា វណ្ណៈនៅក្នុងសង្គមជាក់ស្តែងស្ថិតនៅឯណា?

ក. អត្ថន័យ ខ. អត្ថរូប

គ. អត្ថរស ឃ. ប្រធានរឿង

១០. តើប្រលោមលោកទំនើបធ្វើការផ្តើមរឿងតាមរយៈអ្វី?

ក. រៀបរាប់ពីតួអង្គ ខ. បង្ហាញបញ្ហានៅចំពោះមុខ

គ. តាមគំនិតរបស់អ្នកនិពន្ធម្នាក់ៗ ឃ. បង្ហាញពីទេសភាព

១១. តើសិល្បីតែងនិពន្ធក្នុងអត្ថរូបមានប៉ុន្មានចំណុច?

ក. ៣ ចំណុច ខ. ៤ ចំណុច

គ. ៥ ចំណុច ឃ. ៦ ចំណុច

១២. តើអត្ថរសមានចំណុចអ្វីខ្លះ?

ក. បច្ចេករស ខ. វិសេសរស

គ. សព្វរស ឃ. ចម្លើយទាំងអស់ខាងលើ

១៣. តើអ្នកនិពន្ធបញ្ចប់រឿងពឹងផ្អែកទៅលើអ្វី?

ក. តាមមនោគតិរបស់អ្នកនិពន្ធម្នាក់ៗ ខ. ឱ្យតួអង្គឯកស្លាប់ទាំងអស់

គ. តួអង្គទាំងអស់ត្រូវសរជាតិ ឃ. តួអង្គល្អឈ្នះតួអង្គអាក្រក់

១៤. តើរឿងកុលាបប៉ៃលិនបញ្ចប់រឿងតាមរបៀបណា?

ក. ឱ្យតួអង្គចៅចិត្ររងរបួសធ្ងន់ធ្ងរហូតដល់ស្លាប់

ខ. នាងឃុននារីត្រូវបានលោកបាឡាត់យកធ្វើភរិយា

គ. លោកហ្លួងរតនសម្បត្តិបានលើកនាងឃុននារីឱ្យចៅចិត្រ

ឃ. ចៅចិត្របរឡានទៅកាន់ខេត្តសិរីសោភ័ណ

II. ចូរប្អូនធ្វើការបំពេញចន្លោះ ..... ខាងក្រោមឱ្យបានត្រឹមត្រូវជាមួយពាក្យក្នុងប្រអប់។

វិសេសរស	បច្ចេករស	តថរស	ឯកវាទវិធី	ប្រលោមវិធី	វចនវិធី	កុសលរស

១. ..... ជាតម្លៃដែលអ្នកនិពន្ធបង្កើតឡើងពិសេសសម្រាប់តាក់តែងនិពន្ធរឿងរ៉ាវផ្សេងៗ។

២. ..... ជាវិធីដែលអ្នកនិពន្ធប្រើប្រាស់ពាក្យពេចន៍ក្នុងអត្ថបទឱ្យស្របតាមបរិយាកាស។

៣. ..... ជាវិធីដែលគេធ្វើឱ្យតួអង្គមួយរងទុក្ខទោសឈឺចាប់ ឬមានវិប្បដិសារី។

៤. ..... ជាវិធីដែលអ្នកនិពន្ធចេះលួងលោម បបោសអង្អែលធ្វើឱ្យអ្នកអាន។

៥. ..... ជាតម្លៃដែលអ្នកនិពន្ធបង្កើតឡើងពិសេសៗ នៅក្នុងការតាក់តែងនិពន្ធល្ខោន កំណាព្យ រឿងព្រេង រឿងល្បើកឬអត្ថបទផ្សេងៗក្តី ។

៦. ..... តម្លៃដែលអ្នកនិពន្ធយកតួអង្គជាក់ស្តែងមានមនុស្សគ្រប់វ័យ និងលើកបញ្ហាជីវភាពប្រចាំថ្ងៃរបស់មនុស្ស។

៧. ..... តម្លៃដែលស្ថិតនៅលើការអប់រំទូន្មានប្រៀនប្រដៅ។

III. ចូរប្អូនធ្វើការផ្គូផ្គងចម្លើយពីប្រអប់ ក ទៅប្រអប់ ខ ឱ្យបានត្រឹមត្រូវ។

ក	ខ	ចម្លើយ
១. រឿងកុលាបប៉ៃលិន	ក. បញ្ចប់ដោយឱ្យតួអង្គស្លាប់ទាំងពីរ	១-.....
២. រឿងតេជោយ៉ត	ខ. ផ្តើមរៀបរាប់ទិដ្ឋភាពព្រះអាទិត្យអស្តង្គត	២-.....
៣. រឿងផ្កាស្រពោន	គ. ដំណើររឿងពោរពេញដោយទារុណកម្ម	៣-.....
៤. រឿងថៅកែចិត្តចោរ	ឃ. តាក់តែងជាល្ខោនបាសាក់	៤-.....
៥. រឿងទុំទាវ	ង. អប់រំមនុស្សស្អប់ខ្ពើមអំពើពុករលួយក្នុងសង្គម	៥-.....



មេរៀនទី១០ ពលរដ្ឋល្អ

១០.២. អំណាន ៖ ភ្នាក់ព្រួក

I. ចូរប្អូនពន្យល់ពាក្យពិបាកខាងក្រោមឱ្យបានត្រឹមត្រូវ។

១. វ៉ក់វី ( ) .....។

២. ទើសទាស់ ( ) .....។

៣. រំលោភ ( ) .....។

៤. ស្និទ្ធស្នាល ( ) .....។

៥. ញោស ( ) .....។

II. ចូរប្អូនជ្រើសរើសចម្លើយត្រឹមត្រូវមួយគត់ចំពោះសំណួរខាងក្រោម។

១. តើអត្ថបទ **"អំណាន ភ្នាក់ព្រួក"**ខាងលើនេះនិពន្ធឡើងដោយនរណា?

ក. លោក ញ៉ុក ថែម ខ. ភិក្ខុ បទុមត្ថេរ សោម

គ. លោក អ៊ឹម ថុក ឃ. លោក សួន សុរិន្ទ

២. តើ**"អំណាន ភ្នាក់ព្រួក"**ខាងលើនេះដកស្រង់ចេញមកពីរឿងអ្វី?

ក. រឿងកុលាបប៉ៃលិន ខ. រឿងផ្កាស្រពោន

គ. រឿងស៊ឹមអ្នកបរឡាន ឃ. រឿងសូជាត

៣. តើមួយណាជានិយមន័យរបស់ពាក្យ យ៉ាប់?

ក. ការមានវិប្បដិសារី ខ. ដែលនឿយហត់ខ្លាំង

គ. ដំណើររវាំងស្នះការងារ ឃ. ផ្ដោះឥតរសជាតិ

៤. តើតួអង្គមួយណាជាតួអង្គភ្នាក់ព្រួកនៅក្នុងអត្ថបទរឿងមួយនេះ?

ក. តួអង្គស៊ឹម ខ. តួអង្គលឹម

គ. តួអង្គថៅកែ ឃ. តួអង្គពូសន

៥. តើការហ៊ានតវ៉ាជាមួយអ្នកធំរបស់ស៊ឹមបានធ្វើឱ្យស៊ឹមទទួលបានអ្វី?

ក. សិទ្ធិសេរីភាព ខ. បរាជ័យ

គ. ការដិះដាន់បន្ថែម ឃ. បណ្ដេញចេញពីការងារ

៦. តើពូសនភ្នាក់ព្រួកទៅលើអ្វី?

ក. លែងផ្ដេកផ្ដួលលើព្រែងវាសនា ខ. មានស្មារតីរើបម្រាស់ពីការដិះដាន់

គ. ការអានសៀវភៅនាំមកនូវចំណេះដឹងបន្ថែម ឃ. ចម្លើយទាំងអស់ខាងលើ

៧. តើចំណុចណាខ្លះដែលបញ្ជាក់ថាស៊ឹមជាពលរដ្ឋល្អ?

ក. គាត់មានចំណេះដឹងជ្រៅជ្រះ និងយល់ពីអត្ថប្រយោជន៍នៃការអានសៀវភៅ

ខ. ស៊ឹមចេះពន្យល់ណែនាំ និងកែតម្រូវកំហុសអ្នកដទៃ

គ. គាត់ធ្វើការងារដោយមានការគោរពច្បាប់ និងពេលវេលាបានត្រឹមត្រូវ

ឃ. ចម្លើយទាំងអស់ខាងលើ

៨. តើរឿងស៊ឹមអ្នកបរទ្បានបញ្ចប់រឿងតាមរបៀបណា?

ក. លែងមានការជិះជាន់លើវណ្ណៈតូចតាច

ខ. ស៊ឹមមានសិទ្ធិសេរីភាពឡើងវិញ

គ. បណ្តុះការស្រឡាញ់ចំណេះវិជ្ជាក្នុងវង់កម្មករ

ឃ. ចម្លើយទាំងអស់ខាងលើ

៩. តើអត្ថបទខាងលើមានតម្លៃអប់រំយ៉ាងដូចម្តេច?

ក. ឱ្យយើងខិតខំសិក្សាស្រាវជ្រាវឱ្យបានជ្រៅជ្រះ

ខ. ចេះប្រើប្រាស់ចំណេះវិជ្ជាដើម្បីអភិវឌ្ឍសង្គមជាតិ

គ. ចេះពន្យល់ណែនាំ និងកែតម្រូវកំហុសអ្នកដទៃ កុំផ្តេកផ្តួលលើព្រេងវាសនា

ឃ. ចម្លើយទាំងអស់ខាងលើ

១០. តើរឿងស៊ឹមអ្នកបរទ្បានត្រូវបាននិពន្ធឡើងនៅឆ្នាំណា?

ក. ១៩៥៦ ខ. ១៨៥៧

គ. ១៩១៣ ឃ. ១៩៧២



មេរៀនទី១០ ពលរដ្ឋល្អ

១០.៣. ភេយ្យាករណ៍ ៖ ល្បះក្រង

I. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. ល្បះដែលកើតឡើងពីល្បះរងចាប់ពីឡើងទៅបន្តគ្នា ហើយឃ្លាទោលទាំងអស់ភ្ជាប់គ្នាដោយសារ "ឈ្នាប់ចង"ឬដាក់បន្តគ្នាគេហៅថាល្បះអ្វី?

ក. ល្បះក្រង ខ. ល្បះទោល

គ. ល្បះផ្សំ ឃ. ចម្លើយទាំង៣

២. ល→ គាត់ចង់បានពិន្ទុល្អតែមិនខិតខំរៀន។ ចូរបង្ហាញល្បះរងទី១ក្នុងល្បះនេះ។

ក. មិនខំរៀន ខ. តែមិនខិតខំរៀន

គ. គាត់ចង់បានពិន្ទុល្អ ឃ. គាត់ចង់បានពិន្ទុល្អតែ

៣. តើល្បះក្រងទាំងអស់មានប៉ុន្មានប្រភេទ?

ក. តែមួយប្រភេទ ខ. ពីរប្រភេទ

គ. បីប្រភេទ ឃ. បួនប្រភេទ

៤. ល្បះរងទី១កើតឡើងដោយសារតែអ្វី?

ក. ល្បះរងទាំងពីរភ្ជាប់គ្នាដោយសារតែឈ្នាប់

ខ. ល្បះរងបង្ហាញពីភាពអវិជ្ជមាន

គ. ល្បះរងប្រើឈ្នាប់ជាច្រើនបន្តគ្នា

ឃ. ចម្លើទាំង៣

៥. ល្បះរងប្រភេទទី២កើតឡើងដោយសារអ្វី?

ក. ល្បះរងទាំងពីរភ្ជាប់គ្នាដោយសារតែឈ្នាប់

ខ. ល្បះរងបង្ហាញពីភាពអវិជ្ជមាន

គ. ល្បះរងប្រើឈ្នាប់ជាច្រើនបន្តគ្នា

ឃ. ល្បះរងទាំងពីរដាក់បន្តគ្នាដោយមិនប្រើឈ្នាប់

II. ចូរប្អូនអានល្បះខាងក្រោមដោយប្រាប់ថា តើល្បះនីមួយៗកើតឡើងដោយសារអ្វី?

១. គាត់មើលសិល្បៈឬដើរកម្សាន្តតាមមាត់ទន្លេ។

២. វាខ្ជិលរៀនសូត្រតែវាចង់បានការងារធ្វើ។

៣. អំពើល្អទទួលបានផលល្អ អំពើអាក្រក់ទទួលបានផលអាក្រក់។

៤. គ្រូពន្យល់មេរៀន សិស្សខ្លះស្តាប់ សិស្សខ្លះជជែកគ្នា សិស្សខ្លះខំកត់ត្រា។

III. ចូរប្អូនបង្កើតល្បះក្រងឱ្យបាន៥ល្បះ។

១. ល→.....។

២. ល→.....។

៣. ល→.....។

៤. ល→.....។

៥. ល→.....។



មេរៀនទី១០ ពលរដ្ឋល្អ

១០.៤.អំណាន ៖ មហាចោរចុលដែន

I. ចូរប្អូនផ្គូផ្គងចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

ផ្នែក "ក"	ផ្នែក "ខ"	ចម្លើយ
១. សច្ចា	ក. (កិ.) កើតចលនាភ្ជាក់ផ្អើលដោយធ្វើសង្គ្រាមនឹងគ្នាឯងដរាបដល់ប្រែកិច្ចរាជការផែនដី ប្រែផែនដី។	១ ⟶
២. សង្វៃក	ខ. (ន.) អាកាសធាតុដែលព័ន្ធជុំវិញប្រឹថពី ហើយដែលតែងតែប្រួលប្រែជាប្រក្រតី។	២ ⟶
៣. កិត្តិយស	គ. (កិ.) លូកប្រវាយប្រតប់គ្នាច្របូកច្របល់ ច្របូកច្របល់គ្នាមិនដឹងថាជាអ្នកណា។	៣ ⟶
៤. ប្រទ្ឆក	ឃ. (ន.) សេចក្តីស្លុតចិត្ត ដំណើរតក់ស្លុត ការនឹកខ្លាចអំពើអាក្រក់ ការរំពឹងឃើញ។	៤ ⟶
៥. បរិយាកាស	ង. (កិ.) ប្រកាសពាក្យសច្ចៈ សំបុងសង្រ្ទេង ប្រតិស្ឋ អធិដ្ឋាន។	៥ ⟶
៦. សាន្តត្រាណ	ច. (ន.) យសសក្តិដែលល្បីទូទៅ កេរ្តិ៍ឈ្មោះដ៏រុងរឿង។	៦ ⟶
៧. ភ័ន្តប្រៃ	ឆ. (គុ.) ដែលមានការគ្រប់គ្រង ឬមានពំនាក់ដែលនាំឱ្យកើតសុខស្រួលហើយ។	៧ ⟶

II. ចូរប្អូនបំពេញចន្លោះខាងក្រោមដោយជ្រើសរើសពាក្យក្នុងប្រអប់មកដាក់ឱ្យបានត្រឹមត្រូវ

ចំណង	កាំបិត	ខ្មាំង	កិត្តិយស	ស្នេហា	មិត្ត

[...] "អូន! កុំមើលងាយបងៗមិនមែនជាមនុស្សចិត្តអន់រត់ពីកណ្តាប់ដៃ.....ទេ។ អូនជាខ្មាំងនឹងបងឥឡូវត្រូវការអូនហ៊ានយក.....មកបុកត្រង់ចុងដង្ហើមឱ្យបងស្លាប់ទៅ។ មិនគួរប្តីមកដោះលែងបងដោយលួចលាក់ទេ"។ នាងឱបដៃខ្ញុំដែលជាប់.....និយាយខ្សឹកខ្សួលថា៖ ចា៎! ប្អូនសូមទោសផងប្អូនជា.....នឹងបងដែលដោះលែងបងនោះ។ ជា.....មួយរបស់ប្អូនដោយបានជួយជីវិតអ្នក.....ម្នាក់"[...]។

III. ចូរប្អូនរៀនព្រឹត្តិការណ៍តាមលំដាប់លំដោយនៃខ្លឹមសារអំណាន

.....[...]មានន្ធបានចាកចេញក្រោមពោធិ៍កណ្តាលវាលស្រែឆ្ពោះទៅផ្ទះនាយអគ្គីដើម្បី សម្រាកព្យាបាលរបួស និងបានរត់គេចបីការតាមចាប់ខ្លួនរបស់ស្តេចក្រាញ់ផងដែរ[...]។

.....[...]យើងចេញដំណើរទៅ។ មិនយូរប៉ុន្មានកងទ័ពខ្មាំងដេញតាមជាប់ពីក្រោយ។ ឱលោកគ្រូអើយ!នាងនោះរត់មិនរួចទេព្រោះនាងពុំធ្លាប់រត់ពេលនោះសោះ។ ខ្មាំងក៏កាន់តែជិតមក ជិតមក[...]។

.....[...]បន្ទាប់ពីនោះមកនាយអគ្គីបាននិយាយពីដំណើររឿងដែលខ្លួនត្រូវពួកខ្មាំងចាប់បាន តែសំណាងល្អត្រូវបានកូនស្រីរបស់លោកមេកងជាអ្នករំដោះវិញ ដោយនាងយល់ឃើញថាជាខ្មែរដូចគ្នា ហើយនាងមិនចង់ឃើញសង្គ្រាមនោះទេ [...]។



មេរៀនទី១០ ពលរដ្ឋល្អ

១០.៥.អំណាន ៖ តារកិច្ចរបស់ពលរដ្ឋចំពោះមាតុភូមិ

I. ចូរប្អូនជ្រើសរើសពាក្យក្នុងប្រអប់យកមកបំពេញក្នុងល្បះខាងក្រោម

ជន្មានុជន	តុល្យភាព	ចងអាឃាត	អនក្ខរជន	បរមបុរាណ	យុគសម័យ

១. អ្នកមិនចេះអក្សរហៅថា.....។

២. ជនធំតូច គឺបណ្តាលជនទាំងធំទាំងតូចជា.....។

៣. ការកួចក្តាប់គ្នានូវគំនុំគុំកួន ការចងចិត្តគុំបម្រុងនឹងធ្វើព្យាបាទជា.....។

៤. អាយុពិភពលោក កាលគ្រាដំណើរកំណត់កាលរបស់ពិភពលោកហៅថា.....។

៥. ភាពស្មើគ្នា ស្របគ្នា ដូចគ្នាហៅថា.....។

៦. ដែលល្អប្រពៃកើតមានយូរមកហើយ ដែលឧត្តុង្គឧត្តមធ្លាប់មានពីព្រេងនាយហៅថា.....។

II. ចូរប្អូនជ្រើសរើសចម្លើយខាងក្រោមឱ្យបានត្រឹមត្រូវ

១. គ្រប់កាល:ទេស:តើពលរដ្ឋត្រូវធ្វើអ្វីដើម្បីតបស្នងចំពោះមាតុភូមិវិញ?

ក. រៀនតាមជំនាញខ្លួនស្រឡាញ់ ខ. ត្រូវមានភាពសាមគ្គីគ្នាជាធ្លុងមួយ

គ. ត្រូវផ្តល់ក្តីសង្ឃឹមសម្រាប់ជាតិ ឃ. ចម្លើយទាំង៣

២. តាំងពីសម័យកាលបុរាណមកមាតុភូមិបានបង្ហាញអ្វីខ្លះដល់ពិភពលោក?

ក. បង្ហាញធម្មជាតិ ខ. ប្រពៃណីទំនៀមទម្លាប់

គ. បង្ហាញពីទឹកចិត្តស្រឡាញ់ចំពោះទឹកដីខ្លួន ឃ. ចម្លើយទាំង៣

៣. ព្រះសង្ឃព្រះអង្គបានអប់រំផ្លែវចិត្តមនុស្សយើងឱ្យធ្វើអ្វី?

ក. មានចិត្តមេត្តា សន្តោសវៀរចាករឿងអាក្រក់ទាំងឡាយ

ខ. ត្រូវតែមានចិត្តស្រឡាញ់ជាតិសាសន៍ខ្លួនឯងឱ្យច្រើន

គ. បង្ហាញសេចក្តីល្អចំពោះមនុស្សដែលយើងបានស្គាល់

ឃ. ជួយអ្នកដទៃនៅពេលគេត្រូវការយើងទើបជាជំនួយដ៏ល្អ

៤. តើប្រជាពលរដ្ឋទាំងអស់ត្រូវមានភារកិច្ចអ្វីចំពោះប្រទេសជាតិ?

ក. ត្រូវចូលរួមលើកស្ទួយខាងកសិកម្ម ខ. ត្រូវបំពេញតួនាទីជាពលរដ្ឋល្អ

គ. ត្រូវបម្រើជាតិមាតុភូមិគ្រប់ៗគ្នា ឃ. ត្រូវមានការលះបង់

៥. ដើម្បីសម្រេចផលឱ្យបានល្អប្រទេសជាតិត្រូវពឹងផ្អែកលើពលរដ្ឋដូចនេះពលរដ្ឋត្រូវមានអ្វី?

ក. ត្រូវមានឆន្ទៈមុតស្រួច ខ. ប្រកាន់យុត្តិធម៌

គ. មានស្មារតីប្តូរផ្តាច់ ឃ. ចម្លើយទាំង៣

III. ចូរប្អូនសរសេរពាក្យ "**ត្រូវ**" ឬ "**ខុស**" នៅមុខល្អះមានអត្ថន័យទាក់ទងនឹងអត្ថបទអំណាន

១.....សិស្ស និស្សិត បញ្ញាវ័ន្ត បណ្ឌិតត្រូវចេះប្រើសមត្ថភាពខ្លួនផ្សព្វផ្សាយដល់មនុស្សទូទៅ ឱ្យបានស្គាល់នូវភាពថ្កុំថ្កើងរបស់ប្រទេសជាតិ។

២.....អាជីវករ ពាណិជ្ជករ សិប្បករធ្វើជំនួញត្រូវដោយមានផលចំណេញច្រើនលើសលប់។

៣.....ព្រះសង្ឃជាប្រទីបបំភ្លឺផ្លូវជន្មានុជនឱ្យជ្រះថ្លារួមគ្នា កសាងស្ពាន ថ្នល់ សាលារៀន។

៤.....កុមារ កុមារីត្រូវចូលសាលារៀន ស្តាប់ការទូន្មានរបស់របស់គ្រូបាធ្យាយ រៀនឱ្យពូកែ ដើម្បីក្លាយជាទំពាងស្នងឫស្សី។

៥. .....អ្នកត្រូវតែគិតប្រយោជន៍គ្រួសារជាងប្រយោជន៍ប្រទេសជាតិ ព្រោះគ្រួសារមានសារៈសំខាន់សម្រាប់ជួយអ្នកនៅពេលដែលអ្នកត្រូវការ។

ចប់